អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia

Chambres Extraordinaires au sein des Tribunaux Cambodgiens

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

---

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber

Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 10-Oct-2012, 15:59
CMS/CFO: Uch Arun

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង

**សាធារណៈ**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១២**

**ម៉ោង ០៩:០២ នាទី**

**សវនាការលើកទី១១៧**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍
*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែរ៉ន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វែនស៍ (បម្រុង)
*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

លោក ដាវ អានសាន

លោក ម៉ាតេអូ គ្រីប៉ា
*(Mr.Matteo CRIPPA)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក វ៉េង ហ៊ាត់

លោក ឃីត រេយន័រ (*Mr.Keith RAYNOR*)

លោក ថារីក អាប់ឌុលហ្លាក់
*(Mr. Tarik ABDULHAK)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក អេនឌ្រូ អ៊ីនូហ្ស៊ី *(Andrew IANUZZI)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ

*(Ms. Anta GUISSÉ)*

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

លោក ម៉ៃខល កាណាវាស

*(Mr.Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោក វ៉ែន ពៅ

លោកស្រី ស៊ីន សុវ៉ន

លោក វ៉ែន ពៅ

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី សួ សុទ្ធាវី

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ស៊ីលវៀ ខាតវ៉ាយធ៍ | អង់គ្លេស |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក ថារីក អាប់ឌុលឡាក់ | អង់គ្លេស |
| លោក សុន អរុណ | ខ្មែរ |
| លោក អេនឌ្រូ អ៊ីន្ធូហ្វ៊ី | អង់គ្លេស |
| លោក អាង ឧត្តម | ខ្មែរ |
| លោក ម៉ៃខល កាណាវាស | អង់គ្លេស |
| លោក គង់ សំអុន | ខ្មែរ |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក មាស វឿន (TCW-428) | ខ្មែរ |

# ខ្លឹមសារ

**ការសួរសំណួរទៅសាក្សី៖ លោក មាស វឿន** (TCW-428)
សួរបន្តដោយលោក សុន អរុណ ផ្ដើមពី៖ ........ ទំព័រ ៣
សួរដោយលោក អេនឌ្រូ អ៊ីនូហ្វ្ស៊ី ផ្ដើមពី៖ ........ ទំព័រ ៨
សួរដោយលោក ម៉ៃខល កាណាវាស ផ្ដើមពី៖ ........ ទំព័រ ២៤
សួរដោយលោក គង់ សំអុន ផ្ដើមពី៖ ........ ទំព័រ ៣០
សួរដោយកញ្ញា អង់តា ហ្គីសសេ ផ្ដើមពី៖ ........ ទំព័រ ៣៩

# កិច្ចដំណើរការនីតិវិធី

[០៩:០២:៣០]

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយនៅព្រឹកនេះគឺអង្គជំនុំជម្រះនឹងផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សី មាស វឿន សូមអញ្ជើញ!

សូមអញ្ជើញលោកស្រីមេធាវី!

[០៩:០៣:៥៨]

**កញ្ញា អង់តា ហ្គីសសេ៖**

ជម្រាបសួរលោកប្រធាន ជម្រាបសួរលោក លោកស្រីចៅក្រម ជម្រាបសួរភាគីទាំងអស់។ លោកប្រធាន ខ្ញុំសូមនិយាយដោយខ្លីទេ។ ខ្ញុំចង់ធ្វើការកត់សម្គាល់ខ្លីមួយពាក់ព័ន្ធទៅនឹងកំណត់ហេតុសវនាការកាលពីម្សិលមិញនេះ។ ម្សិលមិញនេះ ក្រោយពេលឈប់សម្រាក ពេលរសៀលលោកចៅក្រម ឡាវែន៍ បានលើកឡើងនូវឯកសារមួយ គឺ E3/233 -- (សូមទោស) 232 ដែលជាកំណត់ហេតុនៃកិច្ចប្រជុំការងារមូលដ្ឋានចុះថ្ងៃទី១៨ មីនា ឆ្នាំ៧៦ នៅពេលដែលគាត់បង្ហាញឯកសារមួយនេះខ្ញុំយល់ថា គាត់បានបញ្ជាក់ថា កុយ ធួន ទំនងជាបានចូលរួមនៅក្នុងកិច្ចប្រជុំនេះ។ ក៏ប៉ុន្តែនៅពេលដែលយើងពិនិត្យមើលបញ្ជីឈ្មោះអ្នកចូលរួមប្រជុំនោះ ឈ្មោះហៅក្រៅរបស់អ្នកចូលរួម ហើយនិងឈ្មោះហៅក្រៅរបស់សមមិត្ត ទូច នោះ គឺយើងអាចអានថា តេ-អូ-អ៊ុយ-សេ-អាស (Touch)។ ក៏ប៉ុន្តែទូចនេះមិនមែនជាឈ្មោះហៅក្រៅរបស់ កុយ ធួន នោះទេ។ តាមពិតទៅ គឺឈ្មោះ ធុច តេ-អាស-អ៊ុយ-សេ-អាយ (Thuch) បានត្រូវ។ ដូច្នេះ នេះជាការបញ្ជាក់ដ៏សំខាន់មួយដែលខ្ញុំត្រូវតែធ្វើ។ ហើយសម្រាប់អ្នកផ្សេងទៀត ដើម្បីឲ្យច្បាស់ទាំងអស់គ្នានោះ។ ខ្ញុំសូមឲ្យអង្គជំនុំជម្រះ និងភាគីទាំងអស់ពិនិត្យមើលឯកសារ E3/230 នៅក្នុងឯកសារនោះមានឈ្មោះហៅក្រៅទាំងពីរនេះ គឺមានទាំងសមមិត្ត

ទូច តេ-អាស -- តេ-អូ-អ៊ុយ-សេ-អាស ហើយនិងសមមិត្តធុច តេ-អូ -- តេ-អាស-អ៊ុយ-សេ-អាស ដែលជាឈ្មោះរបស់កុយ ធួន។ ហើយឈ្មោះ ទូច នោះគឺតាមពិតទៅជាឈ្មោះរបស់ ប៉ុក ចាយ ទេ។ ខ្ញុំសូមភ័យទោសផង ប្រហែលជាខ្ញុំអាចអានច្រឡំ។ ប៉ុក ចាយ គឺ ពេ -- តាមពិត ភោគ ឆាយ ៗ ប៉េ-អាស-អូ-កា-សេ-អាស-អា-អ៊ីការិច។

[០៩:០៦:០៦]

ដូច្នេះខ្ញុំគិតថា ការកត់សម្គាល់នេះមានសារៈសំខាន់ណាស់ ដើម្បីកុំឲ្យមានការយល់ច្រឡំឈ្មោះ ពីព្រោះថា ជួនកាលទៅយើងអាចមានការច្រឡំឈ្មោះរវាង ទូច និង ធុច នេះ។ សូមអរគុណលោកប្រធាន នេះជាការកត់សម្គាល់សម្រាប់ការលើកឡើងរបស់លោកចៅក្រម ឡានវែន៍ កាលពីម្សិលមិញ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។ ខ្ញុំចង់សួរមេធាវី អង់តា ហ្គីសសេ តើគាត់មានបានពិនិត្យមើលអក្ខរាវិរុទ្ធនៅក្នុងភាសាអង់គ្លេស ហើយនឹងឯកសារដើមជាភាសាខ្មែរដែរឬទេ?

**កញ្ញា អង់តា ហ្គីសសេ៖**

ពិតណាស់លោកចៅក្រម ឡាវែន៍ ខ្ញុំបានពិនិត្យមើលអក្ខរាវិរុទ្ធរួចហើយ។ ទូច គឺ តេ-អូ-អ៊ុយ-សេ-អាស ដែលមាននៅក្នុងភាសាខ្មែរនោះ គឺពិតជាឈ្មោះរបស់ ភោគ ឆាយ ទេ មិនមែនជាឈ្មោះហៅក្រៅរបស់ កុយ ធួន នោះទេ។ គឺច្បាស់ណាស់លោកចៅក្រម ជាភាសាខ្មែរគឺ ទូច មិនមែនធុច ទេ។ ហើយនៅពេលដែលយើងសរសេរជាភាសាបារាំង គឺសរសេរជាអង់គ្លេស គឺថាខុសគ្នាដាច់ហើយ រវាង ទូច និងធុច នេះ។

[០៩:០៧:២៦]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី សុន អរុណ!

**លោក សុន អរុណ៖**

សូមអរគុណ។ សូមគោរពអង្គសវនាការ សូមគោរពលោកប្រធានសាជាថ្មី និងសូមជម្រាបសួរលោក មាស វឿន។

**សួរបន្តដោយលោក សុន អរុណ៖**

**ស៖** បន្ទាប់ពីម្សិលមិញ ខ្ញុំបានសួរ ខ្ញុំនៅថ្ងៃនេះ ព្រឹកនេះ ខ្ញុំនឹងមានសំណួរប្រហែលជាបី ឬបួនប៉ុណ្ណឹងទៀតទេ។ ហើយបន្តពីហ្នឹងមានសហភាតារបស់ខ្ញុំនឹងមានសំណួរប្រហែលជា៤០មីនុតបន្ត។ ជាដំបូង ខ្ញុំសូមសួរលោកសាក្សីថា លោក មាស វឿន លោកដឹងទេថា ទីក្រុងភ្នំពេញត្រូវបានកាន់កាប់នៅថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥។ ពេលនោះលោកដឹងថា ខេត្តទាំងអស់ក្នុងទូទាំងប្រទេសខ្មែរទាំងមូលបានធ្លាក់ក្នុងកណ្តាប់ដៃខ្មែរក្រហមនៅថ្ងៃជាមួយគ្នា ឬថ្ងៃខុសគ្នា លោកអាចដឹងរឿងនេះទេ?

**លោក មាស វឿន៖**

**ឆ៖** បាទ ថ្ងៃរំដោះភ្នំពេញនោះ ហើយនៅក្នុងខេត្តទាំងអស់គឺ កំពង់ឆ្នាំង រំដោះក្រោយ។ ខ្ញុំដឹងតែខេត្តកំពង់ឆ្នាំងមួយទេ ដែលរំដោះក្រោយភ្នំពេញ។

[០៩:០៩:០៦]

**ស៖** អរគុណ។ ពេលដែលវ៉ៃចូលភ្នំពេញ កងពលមកពីគ្រប់ទិស ហ្នឹងបើតាមលោកបកស្រាយជូនតុលាការកន្លងហួសមកថ្មីៗនេះ។ កងទ័ព កងពលទាំងអស់មកចម្រុះវ៉ៃ -- ដើម្បីវ៉ៃភ្នំពេញ។ ចុះលោកដឹងទេថា មានកងទ័ពឯណាផ្សេងទៀតដែលបានវ៉ៃទៅតាមខេត្ត?

**ឆ៖** បាទ ខ្ញុំដឹងតែខេត្តកំពង់ឆ្នាំងមួយទេ ដែលមានកងទ័ពតំបន់៣២ វ៉ៃនៅកំពង់ឆ្នាំង។

**ស៖** បើអ៊ីចឹងខេត្តផ្សេងៗទៀតលោកមិនបាន -- មិនច្បាស់លាស់ទេ លោកអត់បានដឹងទេ មានន័យថាលោកអត់បានដឹងទេអ៊ីចឹងឬម៉េច?

**ឆ៖** បាទ អ៊ីចឹងហើយ។

**ស៖** ពេលលោក មាស វឿន ទៅកាន់កាប់ទឹកដីខេត្តកោះកុង ក្នុងឋានៈលោកជាអនុកងពលចាប់ពីថ្ងៃទី១៧ -- ចាប់ពីថ្ងៃទី១៧ ខែកក្កដា អ៎ ខែ៧ សូមទោស ចាប់ពីថ្ងៃទី -- ខែ៧ ឆ្នាំ១៩៧៦ ពេលនុំងលោកបានកាន់កាប់ទឹកដីនៅខេត្តកោះកុងប៉ុន្មានភាគ? ប៉ុន្មានភាគរយ? ហើយមានកោះប៉ុន្មានដែលលោកត្រួតត្រា?

[០៩:១១:៣៦]

**ឆ៖** បាទ ខ្ញុំចេញពីកំពតទៅគឺសំដៅទៅកោះកុងតែម្តង ហើយទៅដល់កន្លែងនោះ ខ្ញុំបានកាន់កាប់ប្រហែលជាមួយភាគ ក្នុងនោះពីត្រឹមកោះកុងក្រៅ ហើយនិងមានកោះតូចៗខ្លះដូចជា កោះ -- សំដៅ គឺកោះកុងក្រៅជាកោះមួយដែលធំហើយសំខាន់ជាងគេនៅក្នុងខេត្តកោះកុង។ ឯកោះតូចៗខ្លះ

ដែលនៅប្រជុំនៅក្នុងកោះកុងហ្នឹងមាន កោះស្ដេច កោះកាពិ កោះយ៉ កោះប៉ោ កោះស្រឡៅ ហើយកោះមួយទៀតនៅខាងលើគេហៅកោះ ភាសាអី គេហៅកោះ សាន់ថៅវ៉ា នៅក្នុងផែនទី ដែលជិតកោះប៉ោហ្នឹង។ ហើយកោះឆ្លាម កោះមួយដែលតូចមើលទៅឃើញស្មើនឹងទឹក ហើយនិងពាមក្រសោប។ ឯខ្ញុំបានចាំកោះនោះប៉ុណ្ណោះ។ សូមអស់។

**ស៖** អរគុណ។ ចុះដីប៉ុន្មានភាគរយនៃខេត្តកោះកុងទៀត អ្នកណា -- កងពលណាដែលគេកាន់កាប់? ហើយកោះមួយចំនួនដែលជាកោះធំៗ ដូចជាកោះត្រល់ កោះអាចម៍សេះ កោះធំៗដទៃទៀតហ្នឹង តើអ្នកណាអ្នកកាន់កាប់ខាងកងទ័ពខ្មែរក្រហមហ្នឹង?

**ឆ៖** បាទ អាហ្នឹងតាមខ្ញុំដឹងខ្លះ កោះហ្នឹងនៅក្នុងកងពល១១៣ ឯចាប់ពីកោះរ៉ុងទៅ ហើយកោះដែលឆ្ងាយៗពីកំពង់សោម មានកោះតាង កោះពូលូវៃ កោះព្រីង ហើយកោះសេះ ទាល់គ្នានឹងកោះត្រល់។ បានខ្ញុំចាំប៉ុណ្ណឹង។

[០៩:១៤:៤២]

**ស៖** កោះតូចៗនៅជិតៗកោះកុង គឺលោកកាន់កាប់ដូចរាយរាប់អំមិញជម្រាបតុលាការអ៊ីចឹង ចុះកោះធំៗទាំងប៉ុន្មានដែលលោកជម្រាបតុលាការអំមិញដែរ អ្នកណាអ្នកដែលកាន់កាប់កោះធំៗទាំងអស់នោះ?

**ឆ៖** បាទ កោះហ្នឹងអង្គាល់គេកាន់កាប់នៅក្នុងកងពលលេខ៣ហ្នឹង ដោយសារខ្ញុំស្គាល់មានឈ្មោះ រឿន តែគាត់ស្លាប់ហើយ គាត់រឬសស្លាប់ហើយ ហើយនិងឈ្មោះ មុត ហ្នឹងក្នុងកងពលលេខ៣ហ្នឹង។

**ស៖** ចុះខាងដីគោកទៅវិញ? ខាងកោះកុង លោកមាស មុត ដដែលអ៊ីចឹង ឬក៏អ្នកណាផ្សេងមេបញ្ជាការកងពល?

**ឆ៖** បាទ ខាងដីគោក ខ្ញុំមិនដឹងថា នៅខាងមូលដ្ឋានគេកាន់កាប់ ឬក៏មាស មុត ខ្ញុំអត់បានដឹងខាងណោះខ្ញុំអត់បានដឹងដែរទេ។

[០៩:១៦:៥១]

**ស៖** ពេលដែលលោកកាន់កាប់កោះតូចៗ ជិតៗកោះកុងទាំងប៉ុន្មានហ្នឹង ពេលហ្នឹងបើតាមលោកឆ្លើយជម្រាបភាគីមុនៗថា មានកងទ័ពថៃចូលមក -- ទូកថៃចូលមករំលោភទឹកដីយើងញឹកញាប់មកចាប់ត្រីក្ដី ចុះចំពោះ លោកដឹងទេថាលោកចំពោះកោះធំៗ ដែលលោកជម្រាបតុលាការអំមិញថា

លោកមាស មុត និងលោកណាផ្សេងម្នាក់ទៀតហ្នឹងកាន់កាប់។ លោកមានបានដឹងទេ ដែល ពេលដែលលោកនៅទុំង ថាតើមានកងទ័ពវៀតណាមចូលមករំលោភលើកោះទាំងប៉ុន្មានហ្នឹងញឹកញាប់ដែរឬទេ?

**ឆ៖** បាទ ខ្ញុំនៅកោះកុង ខ្ញុំបានឮថា កងទ័ពវៀតណាមបានចូលវ៉ៃយកកោះវ៉ៃ។ កោះវ៉ៃដែលក្រោមការគ្រប់គ្រងលោកមុត ហ្នឹង ហើយក៏មិនដឹងថាគេវ៉ៃរបៀបម៉េច ឬក៏គេការពាររបៀបម៉េចនោះខ្ញុំអត់បានដឹងច្បាស់លាស់ទេ។ ប៉ុន្តែដឹងថា វៀតណាមគេបើកកប៉ាល់ធំមក សំចតនៅពាក់កណ្តាលទឹកប្រហែលចម្ងាយតែបីគីឡូ ហើយគេបណ្តែតទូកតូចៗវ៉ៃសន្ធប់យកកោះពូលូវ៉ៃ កោះតាំង។ ត្រង់នេះហើយដែលខ្ញុំមិនបានដឹងច្បាស់ទេ ប៉ុន្តែគ្រាន់តែឮបងប្អូនខាងកងពលលេខបីគាត់និយាយប្រាប់។ កាលដែលវ៉ៃទុំង គឺពេលម៉ោង -- ពេលយប់ មិនដឹងជាម៉ោងប៉ុន្មានទេ ជិតព្រឹកហ្នឹង។ ប្រហែលជាម៉ោងបួនម៉ោងប្រាំព្រឹក។ បាទ ដឹងប៉ុណ្ណឹង។

**ស៖** សូមអរគុណ។ លោកបានឮខាងកងពលទី៣ប្រាប់លោកថា មានទ័ពវៀតណាមជើងទឹកកងទ័ពជើងទឹករបស់វៀតណាមវ៉ៃយក -- មកវ៉ៃកោះពូលូវ៉ៃ កោះតាំង អីជាដើម។ ក្រោយមកទៀតលោកមានដឹង មានឮគេប្រាប់តទៅទៀតថា វ៉ៃហើយគេដកចេញទៅវិញ ឬក៏គេកាន់កាប់កោះទាំងអស់នោះ?

[០៩:១៩:៤៣]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាន ខ្ញុំគិតថា ប្រហែលជាមានបញ្ហាបកប្រែ ប៉ុន្តែយើងមិនបានឮអំពីការនិយាយយោងទៅលើកោះដែលគាត់បាននិយាយនៅក្នុងចម្លើយពីមុននោះទេ។ យើងបានពិភាក្សាអំពី -- យើងមិនបានឮអំពីកោះតាង ដែលបានពិភាក្សាពីមុននោះទេ។ ដូច្នេះ មេធាវីគួរតែសួរ ថាតើមានការវាយប្រហារ ឬក៏មានប្រយុទ្ធគ្នានៅកោះពូលូវ៉ៃ និងកោះតាង ឬក៏អត់? មុននឹងឲ្យសាក្សីគាត់ឆ្លើយបន្តទៅទៀតនេះ។ សូមអរគុណ។

**លោក សុន អរុណ៖**

សំណួរទី១ របស់ខ្ញុំបានសួរគាត់ហើយ ពីរឿងកោះតាង ហើយគាត់បានថា គាត់មិនបានដឹងទេ -

- គាត់មិនបានឃើញនឹងភ្នែកទេ គាត់មិនបានវ៉ៃខ្លួនគាត់ទេ ប៉ុន្តែពួកងពលទី៣ ប្រាប់គាត់។ បានវ៉ៃគ្នា នៅកោះពូលូវ៉ៃ កោះមួយចំនួន និងកោះតាងផង។ ហេតុហ្នឹងបានខ្ញុំសួរបន្តថា តើវ៉ៃហើយ គេនៅកាន់កាប់កងទ័ពទាំងអស់ បរទេសទាំងអស់នៅកាន់កាប់ឬទេ ឬគេថយទៅវិញ? នេះ សំណួរខ្ញុំបន្តអ៊ីចឹង។

[០៩:២០:៥៧]

**ប្រធានអង្គជំនុំ៖**

សាក្សីឆ្លើយតបនូវសំណួរ!

**លោក មាស វឿន៖**

**ឆ៖** បាទ គេវ៉ៃហើយ គេកាន់កាប់កោះនោះដែរ ក៏ប៉ុន្តែពេលដែលគេដកទៅវិញ ខ្ញុំអត់បានដឹង។

**សួរដោយលោក សុន អរុណ៖**

**ស៖** ក្រៅពីកងទ័ពរបស់វៀតណាមមកវ៉ៃកោះធំៗទាំងប៉ុន្មាន ដែលលោកបានជម្រាបតុលាការរួចហើយនោះ រួចពីនោះទៅ លោកមានដឹងថា ប្រជាពលរដ្ឋវៀតណាម ឬអ្នកនេសាទត្រីវៀតណាម ឬកងទ័ពវៀតណាមបានមករស់នៅទឹកដីនោះ បន្តទៅទៀត ឬក៏ព័ត៌មានដែលលោកបានមក ឬក៏លោក -- ពីព្រោះលោកនៅក្នុងកាន់កាប់ខាងកោះហ្នឹងដែរ កោះជិតៗហ្នឹងដែរ លោកអាចដឹងទេថា ទឹកដីទាំងអស់ហ្នឹង កងទ័ពវៀតណាមនៅរហូត ឬក៏ថា ពេលណាមួយគេនឹងចេញទៅវិញ មុននឹងលោកបានប្តូរទីកន្លែងទៅនៅព្រះវិហារ?

**ឆ៖** បាទ ពេលដែលគេវ៉ៃកាន់កាប់កោះនុ៎ងហើយ គ្មានទេ គ្មានប្រជាជនវៀតណាមមកនៅម្តុំកោះដែលវ៉ៃបាននោះទេ។ មានតែទាហានវៀតណាមទាំងអស់ ហើយពេលៗដកទៅវិញនោះ ខ្ញុំមិនបានដឹងថា ថ្ងៃដក ឬក៏យ៉ាងណានោះ ខ្ញុំអត់បានដឹងទេ។

[០៩:២៣:០៩]

**ស៖** អរគុណ។ នៅក្នុងចម្លើយរបស់លោកសាក្សី ទៅចៅក្រមស៊ើបអង្កេតជាបន្តបន្ទាប់ លោកសាក្សីបាននិយាយប្រាប់ចៅក្រមស៊ើបអង្កេតថា -- អ៎! លោកស៊ើបអង្កេតជាញឹកញាប់ និងប៉ុន្មានថ្ងៃនៅក្នុងតុលាការនេះ លោកបានលើកឈ្មោះលោក នួន ជា ញឹកញាប់ដែរ ទាំងមានទាំងថា លោក នួន ជា បានចូលរួមជាមួយ សុន សេន អគ្គសេនាធិការទៅទៀត។ សំណួរនេះ ខ្ញុំបានសួរលោកពីម្សិលមិញម្តងរួចទៅហើយ ប៉ុន្តែខ្ញុំនៅមានចំណុចសួរបន្ថិចទៀត។ ខ្ញុំសួរថា តើលោកបានស្គាល់លោក នួន ជា ច្បាស់លាស់ទេ? ឬក៏បានស្គាល់មិនច្បាស់ គ្រាន់តែស្គាល់ធម្មតា ឬក៏ថាឮគេថាទេ?

**ឆ៖** បាទ នៅក្នុងឆ្នាំ៧៥ ចំពោះអ្នកខាងក្រោមៗ គេចង់ស្គាល់ដែរ អ្នកដឹកនាំ។ ក៏ប៉ុន្តែអ្នកខ្លះអត់បានស្គាល់រហូត។ ដូចជាត្រឹមថ្នាក់ខ្ញុំ មិនងាយនឹងបានស្គាល់គាត់ មិនងាយនឹងបានជួបមុខទេ។ ទាល់តែពេលណាដែលមានការប្រជុំក្នុងភូមិភាគ ឬក៏ចាំបាច់ បើគេហៅខ្ញុំ ក៏បានស្គាល់ តែបើគេអត់ហៅខ្ញុំ គឺអត់បានស្គាល់មុខគាត់ច្បាស់ទេ។ តែឮឈ្មោះ ឮ ហ្នឹងដែលខ្ញុំសូមឆ្លើយខ្លីប៉ុណ្ណេះ។

[០៩:២៥:០០]

**ស៖** អរគុណ។ នៅក្នុង៣ឆ្នាំ ៨ខែ ២០ថ្ងៃនេះ លោកដែលបានទៅធ្វើមហាសន្និបាត ឬក៏សន្និបាតជាមួយលោក នួន ជា ទេ?

**ឆ៖** បាទ បើសិនណាជាប្រធានកងពលខ្ញុំប្រាប់ ហ្នឹងខ្ញុំបានមក ហើយបើសិនជាប្រធានកងពលខ្ញុំមិនប្រាប់ទេ ឬក៏សភាពការណ៍តាមព្រំចាំបាច់ទេ ខ្ញុំមិនបានមកទេ បាទ។

**ស៖** សំណួររបស់ខ្ញុំចង់សួរថា លោកមានដែលបានមកធ្វើសន្និបាត ឬមហាសន្និបាត ឬក៏សន្និបាតជាមួយគាត់ទេ? លោកមានដែលបានទេ ក្នុង៣ឆ្នាំ ៨ខែ ២០ថ្ងៃនុ៎ង? ពីឆ្នាំ១៩៧៥ ដល់មកវា ១៩៧៩ លោកមានដែលបានធ្វើសន្និបាត -- មួយចូលរួមក្នុងការធ្វើសន្និបាតក្រោមការអត្ថាធិប្បាយរបស់លោក នួន ជា នោះ? លោកមានដែលទេ? គេដែលហៅទេ? ហើយមានដែល កងពលរបស់លោកមានដែលអនុញ្ញាតឲ្យលោកចូលរួមទេ?

[០៩:២៦:២៧]

**ឆ៖** បាទ ខ្ញុំបានពីរដង ដូចខ្ញុំបានបញ្ជាក់ គឺនៅលង្វែក ហើយនិងនៅកំពង់ស្ពឺ។ កាលដែលសន្និបាតនៅកំពង់ស្ពឺ កងពលខ្ញុំប្រាប់ថា សន្និបាតប៉ុន្មានថ្ងៃ? ដូចសន្និបាតប្រហែលជា១៥ថ្ងៃ។ អ៊ំមកសន្និបាតហ្នឹងអ្នកណាខ្លះ? គាត់ប្រាប់ខ្ញុំសួរថា មានកាលនោះហៅអ៊ំ ឆ្លើយតាមសំណួរដែលខ្ញុំដឹង គឺអ៊ំ ប៉ុល ពត, អ៊ំ នួន ជា គាត់មកពីរនាក់ ហើយនិង តាស៊ី។ តែដល់ពេលសន្និបាតពេលនោះឃើញតែពីរនាក់ ឃើញតែអ៊ំ ប៉ុល ពត ហើយនិង តាស៊ី ហើយនិងតាប៉ាល់។ ឯចំណែកអ៊ំ នួន ជា ខ្ញុំអត់បានឃើញ។ នេះដែលជាក់ស្តែង ពេលដែលៗពេលមកប្រជុំសន្និបាតផ្ទាល់។ ដូច្នេះការប្រជុំសន្និបាតនោះ មិនបានឃើញគាត់រហូត ឃើញតែបីនាក់ និងភូមិភាគបស្ចិមហ្នឹង តែពីរហ្នឹង ហើយនិងអ៊ំ ប៉ុល ពត ហើយនិងអ៊ំប៉ាល់។ បាទ ខ្ញុំឆ្លើយប៉ុណ្ណឹង។

**លោក សុន អរុណ៖**

សូមអរគុណលោកប្រធាន ខ្ញុំអស់សំណួរប៉ុណ្ណឹង សហភាតាខ្ញុំនឹងសួរបន្ត។ សូមអរគុណលោក

សាក្សី សហភាតាខ្ញុំសួរបន្តទៅទៀត។

[០៩:២៨:១៦]

**លោក អេនគ្រូ អ៊ីនូហ្ស៊ី៖**

សូមអរគុណលោក សុន អរុណ។ សូមអរគុណលោកប្រធាន សូមជម្រាបសួរអស់លោក លោកស្រីចៅក្រម សូមជម្រាបសួរលោកសាក្សី។ ខ្ញុំមានសំណួរពីរបីបន្ថែមទៀតនៅព្រឹកនេះ ខ្ញុំមានគោលដៅបញ្ចប់មុនពេលសម្រាកព្រឹកនេះ។ ហើយខ្ញុំគិតថា ខ្ញុំប្រហែលចំណាយពេល៤០ ឬក៏៤៥នាទី ហើយខ្ញុំនឹងនិយាយឲ្យបានយឺតដើម្បីងាយស្រួលដល់ការបកប្រែ។

**សួរដោយលោក អេនគ្រូ អ៊ីនូហ្ស៊ី៖**

**ស៖** ជាដំបូងខ្ញុំសូមបញ្ជាក់ទៅលើទីតាំងភូមិសាស្ត្រមួយចំនួន មុននឹងយើងចាប់ផ្ដើមចូលទៅក្នុងអង្គសេចក្ដី ដើម្បីបញ្ជាក់ឲ្យបានច្បាស់អំពីទីតាំងអាសយដ្ឋានរបស់លោក តើវានៅក្នុងថ្មដែកកេះ នៅភូមិថ្មដែកកេះ នៅខេត្តបន្ទាយមានជ័យ តើមែនដែរឬទេ?

**លោក មាស វឿន៖**

**ឆ៖** បាទ មែន។

**ស៖** សូមអរគុណលោកសាក្សី។ តើលោករស់នៅភូមិហ្នឹងអស់រយៈពេលប្រហែលប៉ុន្មានឆ្នាំមកហើយ?

**ឆ៖** បាទ ខ្ញុំរស់នៅភូមិហ្នឹងតាំងពីៗ ពីបោះឆ្នោត ជំនាន់បោះឆ្នោតអ៊ុនតាក់។

**ស៖** សូមអរគុណលោកសាក្សី។ ហើយមុនលោកមករស់នៅភូមិថ្មីដែកកេះហ្នឹង តើលោករស់នៅទីកន្លែងណាដែរ?

[០៩:២៩:៥៦]

**ឆ៖** បាទ ខ្ញុំរស់នៅនៅក្នុងជំរំលេខ៨ គឺជំរំតាង៉ុក ហើយចេញពីជំរំហ្នឹងមក ខ្ញុំមកនៅជំរំកងវ៉ា ចេញពីជំរំកងវ៉ាមក បានខ្ញុំទៅនៅថ្មពួក ហើយដោយថ្មពួកវាគ្មានដីនៅ ខ្ញុំកំណត់ទៅរកដីព្រៃនៅ ទៅថ្មដែកកេះ ភូមិថ្មដែកកេះថ្មី។

**ស៖** សូមអរគុណលោកសាក្សី។ ខ្ញុំឮលោកនិយាយថា ជំរំជនភៀសខ្លួនលេខ៨ តើនៅទីណាដែរ ជំរំភៀសខ្លួនដែល -- ជនភៀសខ្លួនដែលលោកនិយាយនុ៎ង?

**ឆ៖** បាទ ជំរំលេខ៨ ជំរំតាង៉ុក។ គេហៅជំរំតាង៉ុក នៅក្នុងដីថៃ។ រាក់ទេ នៅតាមព្រំដែន។

**ស៖** ពេលដែលលោកនិយាយអំពីព្រំដែន តើលោកសំដៅទៅលើព្រំដែនកម្ពុជា-ថៃ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ ត្រឹមត្រូវ។

[០៩:៣១:២៥]

**ស៖** សូមអរគុណលោកសាក្សី។ មុនពេលដែលលោកមករស់នៅសាយអេច ហ្នឹងគឺប្រហែលជាមុននឹងតើលោករស់នៅកន្លែងណាដែរ នៅពេលដែលលោកមុន -- ៣ខែមុនលោកមកហ្នឹង?

**ឆ៖** មុនខ្ញុំចូលជំរំដីថៃហ្នឹង ប្រហែលជាឆ្នាំ៨៣។ ៨៣ ខ្ញុំនៅបឹងត្រកួន បឹងត្រកួនជាប់ព្រំទល់ដែនថៃ ខេត្តតាស្សា។ បឹងត្រកួន ភ្នំឆត្រ។

**ស៖** តើវានៅទាល់មុខ ឬក៏នៅជិតព្រំដែនកម្ពុជា-ថៃផងដែរ តើមានដែរឬទេ?

**ឆ៖** បាទ ជាប់គ្នានឹងព្រំដែនថៃ-កម្ពុជា។

**ស៖** សូមអរគុណលោកសាក្សី។ ឥឡូវនេះ ផ្អែកទៅតាមការយល់ដឹងរបស់លោកទាំងការងារនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ទាំងក្រោយរបបកម្ពុជាប្រជាធិបតេយ្យ តើយើងអាចនិយាយបានទេថា លោកស្គាល់ច្បាស់អំពីព្រំដែនកម្ពុជា-ថៃនោះ?

[០៩:៣២:៥០]

**ឆ៖** បាទ ស្គាល់ច្បាស់ខ្លះ កន្លែងខ្លះស្គាល់ច្បាស់ កន្លែងខ្លះស្គាល់មិនច្បាស់ទេ។

**ស៖** សូមអរគុណលោកសាក្សី។ តើលោកធ្លាប់មកទីក្រុងបាត់ដំបងដែរឬទេ? មកទីរួមខេត្តបាត់ដំបងដែរឬទេ?

**ឆ៖** បាទ ធ្លាប់ដែលមក។

**ស៖** សូមអរគុណលោកសាក្សី។ ខ្ញុំមានសំណួរមួយចុងក្រោយទាក់ទងទៅលើតំបន់នេះ តើពីផ្ទះបច្ចុប្បន្នរបស់លោកមកម៉ាឡៃ ក្នុងស្រុកម៉ាឡៃហ្នឹងតើវាមានចម្ងាយប្រហែលប៉ុន្មានដែរពីផ្ទះលោកមកទីរួមស្រុកម៉ាឡៃនោះ?

**ឆ៖** បាទ បើគិតពីផ្ទះខ្ញុំមកព្រំដែនម៉ាឡៃឆ្ងាយ ប៉ុន្តែបើគិតពីផ្ទះខ្ញុំមកបឹង -- មកភ្នំឆត្រប្រហែលជា ១៥គីឡូមកដល់ព្រំដែនខ្មែរ-ថៃ ហើយបើគិតពីផ្ទះខ្ញុំទៅម៉ាឡៃវិញ ខ្ញុំមិនដឹងថាចម្ងាយប៉ុន្មានទេ ប្រហែលជិត ១០០គីឡូដែរដឹង។ ស្មានថាជិត ១០០ចុះ។

[០៩:៣៤:១២]

**ស៖** សូមអរគុណលោកសាក្សី។ តើលោកធ្លាប់មកស្រុកម៉ាឡៃ ឬក៏មកទីរួមស្រុកម៉ាឡៃដែរឬទេ?

**ឆ៖** បាទ ធ្លាប់មកតើ។

**ស៖** សូមអរគុណលោកសាក្សី។ ឥឡូវនេះ ខ្ញុំសូមបន្តទៅប្រធានបទថ្មី ខ្ញុំនឹងនិយាយយោងទៅលើទីតាំងភូមិសាស្ត្រនេះនៅពេលក្រោយ ប៉ុន្តែឥឡូវនេះខ្ញុំសូមប្តូរទៅប្រធានបទថ្មីមួយទៀត ដើម្បីនិយាយអំពីការយល់ដឹងរបស់លោក ហើយនិងចងក្រងទៅលើអ្វីដែលលោកបានដឹងទាក់ទងទៅនឹងរចនាសម្ព័ន្ធយោធានៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ តើខ្ញុំអាចនិយាយបានដែរឬទេ ថាការយល់ដឹងរបស់លោកមិនអាចយល់ដឹងរហូតទៅដល់កម្រិតភូមិភាគបាន? តើខ្ញុំនិយាយបែបនេះត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ។

**ស៖** សូមអរគុណលោកសាក្សី។ ហើយលោកបានបញ្ជាក់ជម្រាបមកយើងច្រើនដងហើយថា លោកមិនដឹងថា នួន ជា បានចូលការប្រជុំភូមិភាគ ឬក៏អត់ ហើយលោកក៏មិនដឹងថា នួន ជា ជាសមាជិកអគ្គសេនាធិការ ឬក៏អត់នោះ? ថាតើ -- ទោះបីថាលោកបាននិយាយខុសពីនេះនៅក្នុងចម្លើយរបស់លោកជាមួយសហចៅក្រមស៊ើបអង្កេតក៏ដោយ។ ដូច្នេះខ្ញុំមិនសួរសំណួរលោកបន្ថែមទៅលើផ្នែកទាំងអស់នេះទេ ប៉ុន្តែដើម្បីជាកំណត់ត្រា ខ្ញុំសូមចង្អុលបង្ហាញថា សំណួរមួយដែលបង្កឲ្យមានការយល់ច្រឡំកាលពីម្សិលមិញ គឺខ្ញុំនិយាយអំពីឯកសារ E3/424 គឺសំណួរលេខ៣ គឺនិយាយតាមពិតទៅ គឺមានសំណួរ៩ ហោចណាស់ក៏មានសំណួរ៩ដែរ ដែលខ្ញុំអាចជម្រាបបានថាមានករណីហោចណាស់ក៏២ដែលលើកឡើងដោយអ្នកសួរ។ ដូច្នេះដើម្បីជាកំណត់ត្រាប្រតិចារឹក ក៏ដូចជាការជម្រាបដល់អង្គជំនុំជម្រះក៏ដូចជាប្រិយមិត្តទាំងអស់ថា មានអ្វីដែលបានកើតឡើងគឺថា ខ្ញុំគិតថាអង្គជំនុំជម្រះហាក់ដូចជាពេញចិត្តជាមួយនឹងការច្នៃប្រឌិត ក៏ដូចជាអ្វីដែលបានផ្តល់នៅក្នុងសក្ខីកម្មទោះបីថា គេទទួលយកនូវចម្លើយតបនោះ ឬក៏អត់នោះក៏ដោយ។ ប៉ុន្តែអ្វីដែលខ្ញុំយល់ឃើញ គឺថាវាមិនមែនជាករណីបានកើតឡើងដែលថា កំណត់ហេតុស្តាប់ចម្លើយហ្នឹង វាឆ្លើយតបទៅនឹងអ្វីដែលបានកើតឡើងយ៉ាងពិតប្រាកដនោះឡើយ។ ឥឡូវនេះ ខ្ញុំសូមបន្ត--

[០៩:៣៦:៥១]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាន ខ្ញុំសូមជំទាស់ចំពោះសហភាតារបស់ខ្ញុំដែលផ្តល់សក្ខីកម្ម ក៏ដូចជាការស្នើនៅចំពោះមុខសាក្សី ហើយដែលធ្វើឡើងនៅក្នុងពេលដែលសាក្សីកំពុងមានវត្តមានបែបនេះ។ ប្រសិនបើមេធាវីចង់ចង្អុលបង្ហាញអំពីផ្នែកណាមួយ ដើម្បីកំណត់ត្រាប្រតិចារឹក គឺគាត់អាចមានជម្រើសផ្សេងទៀត ដើម្បីធ្វើ។ ដូច្នេះខ្ញុំគិតថា ចំណុចនេះ ខ្ញុំចង់ឲ្យនិយាយយោងទៅលើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ចុះថ្ងៃ៣១ ខែមីនា ឆ្នាំ២០១១ ដែលអង្គជំនុំជម្រះបានណែនាំដល់ភាគី ដើម្បីឲ្យអនុវត្តទៅលើការងារក្នុងករណីបែបនេះ។ គឺខ្ញុំសូមអភ័យទោស មិនមែន២០១១ ទេ គឺ២០១២។ សេចក្តីសម្រេចបានដាក់នៅលើឯកសារ E3/142 ហើយអង្គជំនុំជម្រះបានជម្រាបអំពីចំណុចដែលថា "អង្គជំនុំជម្រះនឹងពិភាក្សាតាមករណី នៅពេលដែលមានការជំទាស់ទៅលើសក្ខីកម្មរបស់សាក្សី។ ហើយបន្តមកទៀតបាននិយាយ អង្គជំនុំជម្រះនឹងសម្រេចទៅលើការចោទប្រកាន់ ទៅលើការលើកឡើងនានា ទាក់ទងទៅនឹងការខុសគ្នារវាងការថតសំឡេងសាក្សី និងការសរសេរនូវចម្លើយសាក្សី ហើយនិងសម្រេចទៅលើភាពខុសគ្នានៃអង្គសេចក្តីទាក់ទងទៅនឹងសវនាការនេះ។

[០៩:៣៨:២៣]

ហើយបន្ថែមតទៅទៀត ភាគីនានាដែលបានលើកឡើងពីការជំទាស់ ត្រូវតែបញ្ជាក់ឲ្យបានច្បាស់លាស់នៅលើភាពមិនស៊ីសង្វាក់គ្នា ហើយនិងត្រូវមានការជូនដំណឹងឲ្យបានទាន់ពេលវេលាមកអង្គជំនុំជម្រះ ដើម្បីឲ្យអង្គជំនុំជម្រះដឹងអំពីការចោទប្រកាន់ ក៏ដូចជាបង្ហាញនូវឯកសារដែលខ្លួនបានធ្វើការចោទប្រកាន់ទាក់ទងទៅបញ្ហានេះ"។ នេះគឺជាអ្វីដែលយើងទាំងអស់គ្នាត្រូវគោរពតាម ហើយប្រសិនបើមេធាវីមានការយល់អំពីភាពមិនត្រឹមត្រូវនៃកំណត់ហេតុស្តាប់ចម្លើយសាក្សី មេធាវីត្រូវដាក់ឲ្យបានទាន់ពេលវេលា។ ហើយខ្ញុំគិតថា នេះគឺជាអ្វីដែលយើងគួរតែធ្វើ។ ហើយខ្ញុំសង្ឃឹមថា មេធាវីនឹងដាក់សំណួរដែលត្រឹមត្រូវទៅលើសាក្សី ហើយមិនត្រូវធ្វើអ្វីដូចដែលគាត់បានធ្វើក្នុងពេលកន្លងមកហើយនេះទេ។

ដូច្នេះហើយ ក្នុងពេលជាមួយគ្នានេះ ខ្ញុំគិតថាយើងគួរតែគោរពទៅតាមសេចក្តីសម្រេចរបស់អង្គជំនុំជម្រះទាក់ទងទៅនឹងវិធីសាស្ត្រដែលយើងត្រូវធ្វើ។

[០៩:៣៩:២៥]

**លោក អេនគ្រូ អ៊ីន្ទូហ្វ៊ី៖**

ខ្ញុំសូមឆ្លើយតបយ៉ាងសង្ខេបថា ខ្ញុំនឹងបន្តទៅសំណួរបន្ទាប់របស់ខ្ញុំ។ ខ្ញុំក៏មានសេចក្តីសម្រេចនេះ

ក្នុងដែរបស់ខ្ញុំផងដែរ ហើយខ្ញុំយល់ស្របទៅលើផ្នែកនៃសេចក្ដីសម្រេច ខ្ញុំយល់ស្របថាវាជាការសំខាន់ដែលយើងត្រូវធ្វើការពិនិត្យទៅលើភាពអាចជឿទុកចិត្តបាននៃសាក្សី ក៏ដូចជាអ្វីដែលគាត់បានឆ្លើយតបទៅនឹងសហចៅក្រមស៊ើបអង្កេត។ ប៉ុន្តែខ្ញុំក៏សូមបញ្ជាក់ដើម្បីជាកំណត់ត្រាផងដែរថា នេះគឺជាបន្ទុកក្នុងការបង្ហាញភាពអាចជឿជាក់បានដែលត្រូវធ្វើឡើងដោយមេធាវីការពារក្ដី។ នេះគឺជាការពិតយ៉ាងជាក់ស្ដែង។ ហើយអង្គជំនុំជម្រះក៏មានកាតព្វកិច្ចដើម្បីបង្ហាញនូវភាពៗ តម្លាភាពក៏ដូចជាភាពជឿទុកចិត្តបាន ដូច្នេះខ្ញុំយល់អំពីបញ្ហាទាំងអស់នេះ។ យើងមិនមានពេលវេលាគ្រប់គ្រាន់ យើងមិនមានម៉ោង មិនមានពេលច្រើនដើម្បីស្ដាប់ទៅលើកំណត់ត្រាជាខ្សែអាត់ដែលមានរយៈពេលរាប់សិបម៉ោង។ ដូច្នេះ ហើយដោយសារតែមានការផ្លាស់ប្ដូរកាលវិភាគ ក៏ដូចជាការផ្លាស់ប្ដូរសាក្សី ដូច្នេះយើងខ្ញុំមិនមានពេលវេលាឲ្យបាន -- ដូច្នេះខ្ញុំយល់ថា ប្រសិនបើយើងអាចជួយដល់អង្គជំនុំជម្រះបាន យើងនឹងជួយ។ ហើយខ្ញុំនឹងព្យាយាមបង្ហាញទៅលើបញ្ហា ដែលមានទាក់ទងទៅនឹងចម្លើយរបស់សាក្សីនៅពេលដែលគាត់ចាប់ផ្ដើមលើការប្រើចម្លើយនេះ។ ដូច្នេះខ្ញុំសូមបន្តទៅផ្នែកបន្ទាប់របស់ខ្ញុំ។

**សួរដោយលោក អេនគ្រូ អ៊ីនូហ្ស៊ី៖**

**ស៖** ឥឡូវនេះលោកសាក្សី នៅពេលដែលយើងនិយាយអំពីសំណួរ ខ្ញុំចង់និយាយអំពីតួនាទី និងកាតព្វ -- និងតួនាទីរបស់លោកនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ តាមចម្លើយរបស់លោក ជាពិសេសអ្វីដែលលោកបានជម្រាបដល់អង្គជំនុំជម្រះ ចំពោះខ្ញុំ ខ្ញុំយល់ឃើញថា លោកមានតួនាទី -- លោកដូចជាជោគជ័យនៅក្នុងការងារ ព្រោះលោកចាប់ផ្ដើមពីទាហានសាមញ្ញឆ្នាំ៧១ ហើយក្លាយទៅជាប្រធានក្រុមនៅឆ្នាំ៧២ ហើយឡើងទៅជាប្រធានវរសេនាតូចឆ្នាំ៧៣ ហើយទៅជាវរសេនាធំ៧៥ ហើយបន្ទាប់មកលោកបានបំពេញតួនាទីសំខាន់នៅក្នុងការរំដោះភ្នំពេញ ហើយគេបញ្ជូនលោកទៅភូមិភាគនិរតី ហើយទៅភូមិភាគបន្តទៀតនៅឆ្នាំ៧៦ ហើយក្លាយទៅជាអនុប្រធានកងពលធំឆ្នាំ -- នៅឆ្នាំ៧៦ផងដែរ។ ប្រសិនបើខ្ញុំនិយាយខុស សូមលោកកែខ្ញុំ។

[០៩:៤២:០០]

ផ្អែកទៅតាមអ្វីដែលលោកបានជម្រាបយើង គឺលោកបាននិយាយអំពីទំនាក់ទំនងជាមួយនឹងខាងមជ្ឈិម។ ពីឆ្នាំ៧៥ ដល់ ឆ្នាំ៧៨ លោកប្រតិបត្តិការក្នុងនាមជាមេបញ្ជាការដែលជោគជ័យនៅក្នុងភូមិភាគរបស់លោក ហើយលោកមិនបាន -- ថាតើខ្ញុំនិយាយបែបនេះត្រឹមត្រូវដែរឬទេទាក់ទងទៅនឹងប្រវត្តិការងាររបស់លោកពីឆ្នាំ៧៥ ដល់ ៧៨ នោះ?

**លោក មាស មឿន៖**

**ឆ៖** បាទ។ ចំណុចខ្លះដែលខ្ញុំបានចាំ ហើយចំណុចខ្លះដែលខ្ញុំមិនបានចាំ ប៉ុន្តែការ -- ភារកិច្ចរបស់ខ្ញុំ ចំណុចខ្លះដែលខ្ញុំមិនបានជាប់នឹងកិច្ចការងារថ្នាក់ដឹកនាំខ្ពស់ៗប៉ុន្មានទេ ភាគច្រើន ខ្ញុំដឹកនាំ អ៎! ភ្ជាប់កិច្ចការងារចំពោះ -- ជាមួយនឹងកងពលច្រើន ហើយពិសេស ខ្ញុំបានតែទទួលកិច្ចការងារពីកងពលច្រើនជាងដែលគាត់នាំមកប្រាប់ខ្ញុំតែប៉ុណ្ណឹងឯងបាទ។ ហើយក្នុងនោះមានចំណុចខ្លះដែលគាត់បានប្រាប់ ហើយពិសេសគាត់ប្រាប់មិនឱ្យស្ទូវដើរចោលកន្លែងសមរភូមិ។ នេះតាមខ្ញុំចាំបានមានប៉ុណ្ណឹង។

[០៩:៤៣:៤២]

**ស៖** សូមអរគុណលោកសាក្សី។ ខ្ញុំមានសំណួរមួយទៀតទាក់ទងទៅនឹងចំណុចនេះ តើលោកទទួលខុសត្រូវយ៉ាងណា តើលោកមានការអនុវត្តបែបណាដែលលោកមានការដំឡើងឋានៈឆាប់រហ័សនៅក្នុងជួរកងទ័ពបែបនេះ តើវាមានហេតុផលអ្វី ឬក៏មូលហេតុអ្វីដែរ?

**ឆ៖** បាទ ការពិតខ្ញុំមិនមែនឡើងរហ័សទេ ខ្ញុំឡើងយឺត។ មុននឹងខ្ញុំបានគេចាត់តាំងឱ្យខ្ញុំធ្វើអនុហ្នឹង ខ្ញុំស្ទើរថារបួសសព្វសាច់អស់ហើយ បានជាគេឱ្យខ្ញុំបានទៅទទួលតំណែងនោះ។ ហើយក្នុងការតំណែងនោះ ក៏ខ្ញុំមិនទាន់មានពេញសិទ្ធិថា ហើយជាអនុត្រឹមត្រូវប៉ុន្មានទេ ក៏ប៉ុន្តែគាត់គ្រាន់តែឱ្យជំនួស និងជំនួយការខ្លះឱ្យគាត់ ពីព្រោះគាត់រងរបស់គាត់ម្នាក់នោះ គាត់ត្រូវការឈឺ ឬក៏រហូតដល់គាត់ធ្វើការអត់កើតដោយរបួសដែរនោះ។ មានតែប៉ុណ្ណឹងឯងដែលការងារដែលត្រូវឡើងជាអនុនោះ ហើយសំខាន់ដែលខ្ញុំបាន បាននៅគ្រប់គ្រងនៅខាងកោះកុងបានជាប់លាប់ មិនសូវបានចេញទៅណាមកណាហ្នឹងគេ។ ហ្នឹងគឺបើតាមការដែលគេឱ្យខ្ញុំឡើងជាអនុកងពលនៅពេលនោះ។ ហើយក៏បានខ្លីទៀត មិនមែនបានច្រើនឆ្នាំទេបាទ គឺចប់៧៥ មកដល់៧៦ អីហ្នឹងក៏មិនទាន់មានឈ្មោះនាមអីទទួលខុសត្រូវខ្ពង់ខ្ពស់ប៉ុន្មានទេ។ ទទួលខុសត្រូវតែមួយទឹកដីខេត្តកោះកុងតែមួយផ្នែកតូច ប្រហែលជាមួយភាគតូចប៉ុននុ៎ងឯងបាទ។

**ស៖** សូមអរគុណលោកសាក្សី។ ឥឡូវនេះ ខ្ញុំព្យាយាមស្វែងយល់អ្វីដែលលោកចង់និយាយ តើខ្ញុំនិយាយត្រឹមត្រូវដែរឬទេថា ទោះបីជាលោកមានតួនាទីខ្ពស់ក្នុងនាមជាអនុបញ្ជាការកងពល ប៉ុន្តែ លោកនិយាយថា លោកមិនមានការទទួលខុសត្រូវច្រើន តើខ្ញុំនិយាយអ៊ីចឹងត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ ត្រឹមត្រូវ។

[០៩:៤៦:១៩]

**ស៖** សូមអរគុណលោកសាក្សី។ ឥឡូវនេះយើងនិយាយអំពីអ្វីដែលលោកបានពិភាក្សាជាមួយ

ចៅក្រមឡាវែន៍ កាលពីម្សិលមិញ។ ហើយលោកនិយាយអំពីលោកមាស មុត តើលោកចាំថាលោកបានពិភាក្សាអំពីលោកមាស មុត ជាមួយនឹងចៅក្រមកាលពីម្សិលមិញដែរឬទេ?

**ឆ៖** បាទ ម្សិលមិញគាត់លើកពីមាស មុត អូ៎! ខ្ញុំដឹងថា ខ្ញុំគ្រាន់តែឮទេ ខ្ញុំគ្រាន់ខ្ញុំស្គាល់ ដឹងតែតាមុតៗ តែនាមគាត់ខ្ញុំមិនដឹងទេ។ ដឹងតែតាមុតៗប៉ុណ្ណឹង។ ប៉ុន្តែគាត់លើកម្សិលមិញ ដឹងតែតាមុត បាទ។

**ស៖** សូមអរគុណលោកសាក្សី។ ចុះៗបុគ្គលម្នាក់ទៀត ឈ្មោះស៊ូ ម៉េត ឬក៏ហៅម៉េត តើលោកស្គាល់គាត់នោះដែរឬទេ? គឺឈ្មោះស៊ូ ម៉េត?

**ឆ៖** បាទ ក្នុងហ្នឹងខ្ញុំមិនបានដឹងទេ មិនដឹងជា -- ប៉ុន្តែឮឈ្មោះមិនដែលបានជួបគ្នាទេ ប៉ុន្តែនៅក្នុង -- មិនដឹងនៅក្នុងកងពលណាទេ ប៉ុន្តែថា មិនដឹងថាឈ្មោះ -- ដឹងតែឈ្មោះ តែមិនដែលជួបគាត់ទេ ព្រោះកិច្ចការងារកងខុសគ្នា ហើយទទួលកិច្ចការងារខ្ពស់ៗជាងខ្ញុំ ខ្ញុំមិនដឹងថាគាត់នៅដល់កន្លែងណា ឬក៏នៅកងណាទេ ក្នុងពេលនោះ។ ខ្ញុំដឹងតែអ្នកដែលនៅជាប់នឹងខ្ញុំ ខ្ញុំដឹងតែ -- ខ្ញុំស្គាល់ឈ្មោះប៉ុណ្ណឹង មិននៅជាប់ខ្ញុំមិនដឹងទេ។ មិនដែលជួបមុខផងបាទ។

**ស៖** អរគុណលោកសាក្សី។ ដូច្នេះ តាមដែលលោកនិយាយ គឺថាជាភស្តុតាងរបស់លោកគឺថា ទោះបីលោកមានការងារដ៏ជោគជ័យនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យក៏ដោយ ក៏លោកមិនដឹងថាតើស៊ូ ម៉េត មានតួនាទីអ្វីនោះដែរ។ តើលោកចង់ជម្រាបប្រាប់មកអង្គជំនុំជម្រះថាបែបនេះមែនដែរឬទេ?

[០៩:៤៨:៣៧]

**ឆ៖** បាទ ឮតែឈ្មោះ ឮ។ ប៉ុន្តែដល់កិច្ចការងារ មិនដឹងគាត់ទទួលខាងអី ខ្ញុំឮតែឈ្មោះអីចឹង មែន។

**ស៖** សូមអរគុណលោកសាក្សី។ សំណួរចុងក្រោយទៅលើចំណុចនេះ តើនៅពេលដែលលោកធ្វើការប្រៀបធៀបនៅក្នុងឋានានុក្រមយោធា តើលោកក្នុង ស្ថិតក្នុងកម្រិតបែបណាធៀបជាមួយនឹងលោក មាស មុត តើលោកនៅពីលើ នៅពីក្រោម ឬក៏នៅកណ្តាល? តើលោកអាចប្រៀបធៀបបានទេ អំពីឋានៈតួនាទីរបស់លោក ធៀបជាមួយនឹងលោក មាស មុត នោះ?

**ឆ៖** អូ៎! បាទខ្ញុំមិនឋានៈដល់លោក មុត នោះទេ។ ខ្ញុំក្រោមលោក មុត ឆ្ងាយណាស់។ ក្រោមតាំងពីការគ្រប់គ្រងលើខ្ញុំ តាមភូមិភាគគេគ្រប់គ្រងខ្ញុំ លោកមាស មុត ការគ្រប់គ្រងរបស់គាត់ គាត់កងពល ឯនៅក្នុងខាងទឹក ទទួលខុសត្រូវខាងកប៉ាល់ ខាងអីផង។ អាហ្នឹងខ្ញុំនៅក្រោមឆ្ងាយណាស់។

[០៩:៥០:០០]

**ស៖** សូមអរគុណលោកសាក្សី។ ឥឡូវនេះ ខ្ញុំសូមបន្តទៅបុគ្គលមួយរូបទៀត គឺឈ្មោះ តាម៉ុក។ ហើយលោកបានរៀបរាប់អំពី តាម៉ុក ទាក់ទងទៅនឹងតួនាទីរបស់គាត់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ដូច្នេះ ខ្ញុំអាចនិយាយបានថា លោកស្គាល់ តាម៉ុក ច្បាស់លាស់។ តើលោកស្គាល់ តាម៉ុក ច្បាស់លាស់ដល់កម្រិតណាដែរ?

**ឆ៖** បាទ ខ្ញុំបានស្គាល់ តាម៉ុក តាំងពីគាត់ចូលព្រៃ។ ហើយគាត់ជ្រើសរើសខ្ញុំហ្នឹង ឲ្យការពារអ្នកដឹកនាំកម្មាភិបាលនៅក្នុងព្រៃក្នុងអីហ្នឹង។ ហេតុដូច្នេះស្គាល់ជាមួយ តាម៉ុក យូរឆ្នាំ។ ដឹងថា តាម៉ុក ហ្នឹងជាអ្នកដឹកនាំការតស៊ូហ្នឹង ហើយឃើញគាត់ដើរគ្រប់កន្លែងទាំងអស់។ កន្លែងត្រង់ណា ក៏ឃើញ តាម៉ុក ហើយកន្លែងត្រង់ណាក៏ តាម៉ុក។ ត្រង់នេះ ដែលខ្ញុំបានស្គាល់ តាម៉ុក ច្បាស់។ ពីព្រោះខ្ញុំចេញពីស្រុក ទៅចូលព្រៃ គឺស្គាល់ តាម៉ុក មុនគេបង្អស់អស់។ មុនគេ ទាំងយុវជន ស្គាល់ តាម៉ុក រហូត ដល់ទល់គ្នានឹង៧៥ បានខ្ញុំ -- គាត់មិនសូវជាប់ជាមួយខ្ញុំទេ ព្រោះខ្ញុំនៅព្រៃ ព្រោះគាត់នៅ *(ឮមិនច្បាស់)* គាត់ដើរគ្រប់កន្លែង ហើយខ្ញុំនៅតែព្រៃ។ បាទ ប៉ុណ្ណឹងឯង។

[០៩:៥១:៤៨]

**ស៖** សូមអរគុណ។ សូមអរគុណលោកសាក្សី។ តើខ្ញុំបើកមីក្រូហ្វូនខ្ញុំឮដែរទេ? ថាជាបញ្ហាផ្ទាល់ខ្លួនរបស់ខ្ញុំនោះទេ សូមអរគុណ។ ខ្ញុំសូមអាននូវអត្ថបទរបស់សាក្សីមួយទៀត ដែលខ្ញុំសូមមិនបង្ហាញឈ្មោះរបស់គាត់នោះទេ។ គឺសាក្សីនោះ បាននិយាយពាក់ព័ន្ធទៅនឹង តាម៉ុក ហើយខ្ញុំសូមធ្វើការដកស្រង់ លោកសាក្សី ទាក់ទង -- នៅៗពាក់កណ្ដាលនៃទំព័រនោះ លោកនិយាយអំពីភូមិភាគមួយ ហើយលោកបានដកស្រង់ថា "មេដឹកនាំភូមិភាគ ហាក់ដូចជាមេកន្ទ្រាញ"។ តើលោកអាចនិយាយតាមពាក្យរបស់លោក តើពាក្យថា ស្ដេចត្រាញ់ ហ្នឹង វាមានន័យបែបណាដែរ? ចម្លើយ "ស្ដេចត្រាញ់ ដែលខ្ញុំនិយាយនោះ គឺនិយាយទៅលើ តាម៉ុក។ ព្រោះថា នៅពេលនោះ គាត់សម្លាប់កម្មាភិបាលមកពីខាងពាយព្យ -- ខាងៗនិរតី។ គឺថាគាត់នាំយកកម្មាភិបាលពីខាងនិរតីយកមកសម្លាប់" ហើយខ្ញុំសូមបញ្ចប់ការដកស្រង់របស់ខ្ញុំ។ សំណួរដែលខ្ញុំចង់សួរលោកសាក្សីនៅពេលនេះ គឺថាតើលោកយល់ស្របដែរឬទេ ផ្អែកទៅតាមអ្វីដែលលោកបានដឹង ថា តាម៉ុក គាត់មានអាកប្បកិរិយាដូចជាស្ដេចត្រាញ់បែបនេះ? ហើយក្នុងន័យជាភាសាអង់គ្លេស គឺចង់និយាយថា "គឺជាមេទាហានដែលមានសិទ្ធិអំណាច និងអំណាចយ៉ាងខ្លាំងក្លា"។ តើលោកយល់ស្របដែរឬទេ ថា តាម៉ុក មានសិទ្ធិអំណាច ក៏ដូចជាភាពផ្ដាច់ការ ដូចជា

ស្ដេចត្រាញ់នៅក្នុងយោធានោះ? លោកសាក្សីកុំអាលទាន់ឆ្លើយសំណួរអី។

[០៩:៥៣:៥០]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមិនចង់ជាកាត់ទេ ប៉ុន្តែខ្ញុំចង់ឲ្យមានការផ្ដល់ឯកសារយោងទៅលើចម្លើយរបស់សាក្សីនេះ។ ជាពិសេសគឺឯកសារ គឺលេខERN ដើម្បីឲ្យយើងខ្ញុំអាចពិនិត្យមើលទៅអ្វីដែលគាត់យោង។

**លោក អេនគ្រូ អ៊ីន្ទូហ្ស៊ី៖**

សូមអភ័ទោស។ នេះគឺជាប្រតិចារឹកថ្ងៃ៣០ ខែកក្កដា ឆ្នាំ២០១២ នៅទំព័រទី៣២ ជួរទី១៥,១៦ គឺឯកសារដែលមានលេខ--

**អ្នកបកប្រែ៖**

លោកប្រធាន ស្នើសុំឲ្យគាត់និយាយនូវលេខឯកសារឡើងវិញ។

[០៩:៥៤:៣៣]

**ប្រធានអង្គជំនុំ៖**

លោកមេធាវី បង្ហាញពីលេខឯកសារឡើងវិញ ព្រោះអ្នកបកប្រែស្ដាប់មិនទាន់ ហើយបកមិនទាន់ទេ។

**លោក អេនគ្រូ អ៊ីន្ទូហ្ស៊ី៖**

សូមអរគុណលោកប្រធាន។ គឺឯកសារដែលមានលេខ E1/99.1 គឺជាកំណត់ត្រាប្រតិចារឹកថ្ងៃ ៣១ កក្កដា ២០១២ ហើយខ្ញុំដកចេញពីទំព័រ៣៦ ជួរទី៦ទៅ៧ គឺជាសក្ខីកម្ម ខ្ញុំគិតថាខ្ញុំចង់សាក្សីឆ្លើយសិន មុននឹងបន្តទៅទៀត។

**សួរដោយលោក អេនគ្រូ អ៊ីន្ទូហ្ស៊ី៖**

**ស៖** លោកសាក្សី តើលោកយល់ស្របដែរឬទេថា តាម៉ុក ជាមេដឹកនាំយោធា ដែលមានស្វ័យ --- ដែលមានអំណាច ក៏ដូចជា១ស្វ័យភាពខ្លាំងក្លាបែបនេះ?

**លោក មាស វឿន៖**

**ឆ៖** បាទ បើតាមខ្ញុំធ្លាប់នៅជាមួយគាត់ហ្នឹង ហើយរហូតតាំងពីឆ្នាំ១៩៧៤ -- ៦៨ ហើយមកទាល់គ្នា៧៥ ហើយខ្ញុំមិនដឹងថាពាក្យពេចន៍ស្ដេចត្រាញ់យ៉ាងម៉េចទេ ក៏ប៉ុន្តែ តាម៉ុក មានអំណាច ៗខ្ពស់ ហើយផ្ដាច់ការ ហើយជាក់ស្ដែងគាត់ចង់ដកអ្នកណា បញ្ចូលអ្នកណា អាចបានតាមចិត្តរបស់គាត់។ ហើយជាក់ស្ដែងគាត់ប្រើខ្ញុំ ប្រើឲ្យទៅណា ទៅហ្នឹង ហើយខ្ញុំមិនអាចប៊ានប្រកែកទេ កាលនៅជាក្រុមកងការពារនោះ។ ប្រើទាំងយប់ទៅទាំងយប់ ដើរមួយយប់ដាច់ជើងខោអស់។ នេះដែលគឺថា រហូតដល់មានអំណាច៧៥ រឹតតែមានអំណាចខ្លាំងទៀត ហៅថា "អំណាចផ្ដាច់ការ"។ ដកៗអ្នកដឹកនាំ ឬដកទាហានណា ឬដាក់ទាហានណា អាហ្នឹងស្រេចនៅលើគាត់ ហ្នឹងតាមគំនិតខ្ញុំពិនិត្យពិចារណា។ ក៏ប៉ុន្តែទៅកន្លែងណាឃើញតែ តាម៉ុក, ទៅកន្លែងណាឃើញ តាម៉ុក ហើយរហូតដកកម្លាំងរបស់គាត់ខ្លះ គាត់ដកយកទៅធ្វើការ ដកយកមកអប់រំ ដកយកមកកលត់ដំ អាហ្នឹងគឺនៅលើ តាម៉ុក។ នេះតាមខ្ញុំឃើញខ្ញុំដឹងប៉ុណ្ណឹង ក៏ប៉ុន្តែខ្ញុំពី៧៥ រហូតដល់អត់បានជួប តាម៉ុក ទៀតទេ ខ្ញុំមិនបានទាក់ទងអីទៅ តាម៉ុក ទៀតទេ ខ្ញុំបានតែទាក់ទងតែកងពលខ្ញុំប៉ុណ្ណឹង បាទ។

[០៩:៥៧:៣៦]

**ស៖** សូមអរគុណលោកសាក្សី សូមអរគុណមន្ត្រីតុលាការ ដែលបានផ្ដល់កាសមកឲ្យខ្ញុំ។ ខ្ញុំសូមបន្តទៅទៀតលោកសាក្សី។ នៅពេលនេះខ្ញុំចង់សួរបញ្ហាអង្គហេតុពីរបីទៅលោកសាក្សី--

*(មានបញ្ហាបច្ចេកទេស)*

[០៩:៥៨:២៣]

**ប្រធានអង្គជំនុំ៖**

លោកមេធាវីអាចអញ្ជើញបន្តបាន!

**លោក អេនគ្រូ អ៊ុីន្ទូហ្ស៊ី៖**

សូមអរគុណលោកប្រធាន។ អ៊ីចឹងខ្ញុំបន្តទៅទៀតបាន សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

នៅៗទេ មិនទាន់ -- នៅមានបញ្ហានៅឡើយ។

[០៩:៥៨:៤២]

*(មានបញ្ហាបច្ចេកទេស)*

[១០:០១:២០]

**ប្រធានអង្គជំនុំ៖**

បាទ ដំណើរការជួសជុលប្រព័ន្ធសំឡេងទំនងជាត្រូវប្រើ ត្រូវចំណាយពេល -- ត្រូវការពេលវេលាយូរ។

[១០:០២:២៤]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីអាចចាប់ផ្ដើមបានហើយ! បាទ សូមអញ្ជើញបន្តការតាំងសំណួរសាក្សី!

**លោក អេនគ្រូ អ៊ីនូហ្សី៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក អេនគ្រូ អ៊ីនូហ្សី៖**

**ស៖** លោកសាក្សី ឥឡូវនេះដូចដែលខ្ញុំបានលើកឡើង គឺថាខ្ញុំបង្ហាញហេតុផលមួយចំនួនទៅលោក ហើយសូមឲ្យលោកពន្យល់ ឬក៏ផ្ដល់ជាមតិយោបល់ណាមួយ ហើយសូមលោកសាក្សីចងចាំថាខ្ញុំសួរនេះគឺយោងទៅលើចំណេះដឹងផ្ទាល់ខ្លួនរបស់លោក តែបទពិសោធន៍ផ្ទាល់ខ្លួនក្នុងនាមលោកជាកងទ័ព ហើយសូមឲ្យលោកពន្យល់ទៅតាមការយល់ដឹងផ្ទាល់របស់លោក។ បាទ សូមលោកកុំស្មានសូមលោកកុំនិយាយដោយការទាយ ឬក៏ស្មាននោះ គឺជម្រាបឲ្យត្រង់ៗតាមចំណេះដឹងផ្ទាល់ខ្លួនតែម្ដង។ ទី១ លោកសាក្សី តើលោកដឹងទេថា តាម៉ុក និង មាស មុត ត្រូវបានគេយល់ថាមានទំនាក់ទំនងផ្ទាល់ជាមួយនឹងមជ្ឈិមបក្សពាក់ព័ន្ធទៅនឹង -- តើលោកលោកបានដឹងអីចឹងទេ ពាក់ព័ន្ធទៅនឹងការសម្លាប់កម្មាភិបាលរបស់គាត់នោះ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក អាប់ឌុលឡាក់ ថារីក៖**

សំណួរនេះ លោកប្រធាន ខ្ញុំគិតឃើញថា មិនសមស្របទេ វាខ្វះខាតនូវសមាសធាតុ ធាតុមួយចំនួនធំក្នុងការកំណត់ហ្នឹង គឺថាសួរថា តើដោយអ្នកណា? ហើយសម្លាប់ពេលណាអីយ៉ាងដូច្នេះ យោង

ទៅលើឯកសារណា? ដូច្នេះមេធាវីការពារក្តី ត្រូវតែយោងទៅលើឯកសារណាមួយឲ្យបានច្បាស់លាស់ មុននឹងគាត់ស្រង់យកព័ត៌មាននេះមកប្រើប្រាស់សាកសួរទៅដល់សាក្សីរូបនេះ។

[១០:០៩:២៨]

**លោក អេនគ្រូ អ៊ីនួហ្ស៊ី៖**

លោកប្រធានខ្ញុំសូមឆ្លើយដោយសង្ខេបទេ។ ខ្ញុំសូមបន្ថែមដើម្បីជាប្រតិចារឹកនេះ គឺជាគំនិតយោបល់វាកើតមានហើយក្រៅពីឯកសារ គឺខ្ញុំយល់ថា អង្គជំនុំជម្រះគឺចង់ឲ្យមានការយោងទៅលើឯកសារនេះ គឺសាក្សីហើយ សាក្សីស្គាល់តាម៉ុក សាក្សីស្គាល់ មាស មុត ហើយគាត់ធ្លាប់ជាអតីតមេបញ្ជាការកងទ័ព។ ជាការពិតគឺគាត់នឹងអាចប្រាប់ព័ត៌មានរបស់យើងបានហើយ ខ្ញុំសួរទៅលើចំណេះដឹងនិងបទពិសោធន៍ផ្ទាល់ខ្លួនរបស់គាត់តែម្តង។ បើទោះបីខ្ញុំសួរនេះពិត ឬក៏មិនពិត ត្រឹមត្រូវ ឬក៏មិនត្រឹមត្រូវ ត្រូវនឹងការយល់ដឹងរបស់គាត់ឬយ៉ាងណានោះទេ គឺអាស្រ័យទៅលើសាក្សី ពីព្រោះគាត់ត្រូវមកផ្តល់សក្ខីកម្ម។

គំនិតយោបល់ពាក់ព័ន្ធទៅនឹងព័ត៌មាន ទៅនឹងមនុស្សដែលខ្ញុំលើកឡើងនោះ គឺថាយើងមានព័ត៌មានអាចសួរបានហើយ ក្រៅពីឯកសារ។ ដូច្នេះ យើងអាចតាក់តែង ឬក៏រៀបចំការយល់ដឹងខាងក្រៅពីឯកសារ ដើម្បីចង់ឲ្យសាក្សីផ្តល់សក្ខីកម្ម។ យើងនឹងថ្លឹងថ្លែងទៅលើទម្ងន់ ឬក៏និយាយពីតម្លៃនៃសក្ខីកម្មនេះ។ ដូច្នេះអាស្រ័យទៅលើអង្គជំនុំជម្រះជាអ្នកសម្រេច។

យើងមានឯកសារសម្រាប់សប្តាហ៍ក្រោយ។ ប្រហែលជាពេលនោះ គឺជាពេលដែលយើងត្រូវនិយាយគ្នាអំពីឯកសារហើយ យើងនៅមានសវនាការអំពីឯកសារនៅសប្តាហ៍ក្រោយ។ តែពេលនេះគឺយើងត្រូវសួរព័ត៌មានទៅសាក្សីផ្ទាល់តែម្តង ព្រោះសាក្សីមានវត្តមាននៅចំពោះមុខតុលាការ។

[១០:០៦:០១]

*(ចៅក្រមពិភាក្សាគ្នា)*

[១០:១០:៥៨]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះប្រគល់ភារៈជូនទៅលោកស្រី ស៊ីលវៀ ខាតវ៉ាយថ៍ ដើម្បីសម្រេចទៅលើបញ្ហាដែលលើកឡើងដោយ -- សំណួរដែលសួរឡើងដោយមេធាវីការពារក្តីលោកនួន ជា ហើយនិងមានការតវ៉ាជំទាស់ពីតំណាងសហព្រះរាជអាជ្ញា។

សូមអញ្ជើញលោកស្រីចៅក្រម!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។ អង្គជំនុំជម្រះយល់ព្រមថា សំណួរទាំងឡាយណាដែលមិនបានយោងទៅលើឯកសារណាមួយ ឬក៏យោងទៅលើចម្លើយសាក្សីណាមួយនៅចំពោះមុខតុលាការនេះ គឺថា មិនអាច -- ដែលតុលាការមិនបានដឹង មិនបានសាកសួរគឺថា មិនអាចទទួលយកបានទេ។ គំនិតយោបល់ដែលការលើកឡើងនេះ គឺថាមិនអាចធ្វើទៅបានទេ គឺតុលាការដំណើរការនីតិវិធីដែលយោងទៅលើភស្តុតាង ដោយយោងទៅលើចម្លើយសាក្សីដែលបានផ្តល់ពីមុនៗមក ដែលធ្លាប់បានផ្តល់នៅចំពោះមុខតុលាការនេះរួចហើយ ឬក៏ឯកសារទាំងឡាយដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ ដើម្បីយកមកធ្វើជាមូលដ្ឋានក្នុងការតាំងសំណួរទាំងឡាយទៅលើសាក្សី។

[១០:១២:៣៥]

សេចក្តីណែនាំពីជនជាប់ចោទមិនអាចមានទម្ងន់បាននោះទេលើកលែងតែសាក -- ជនជាប់ចោទ គឺថាលះបង់សិទ្ធិដោយរក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតប ហើយដែលត្រូវមេធាវីតាំងសំណួរទៅលើបញ្ហាប្រធានបទទាំងនោះ។

ដូច្នេះ សំណួរទាំងឡាយណាដែលយោងទៅលើៗបញ្ហាទ្រឹស្តីដែលគិតថា មិនមែនជាលក្ខខណ្ឌមួយសមស្រប ហើយមិនអាចយកបាន ដើម្បីយកមកធ្វើដល់ -- ជាសេចក្តីសម្រេចនេះ ដូច្នេះលោក អ៊ីន្ទូហ្ស៊ី យើងយល់ឃើញថា សំណួររបស់ -- សំណួរលោកអាចយោងទៅលើឯកសារណាមួយ លោកអាចតាំងសំណួរទៅលើសាក្សីនេះបាន បើមិនដូច្នោះទេ លោកត្រូវតែដូរចូលទៅប្រធានបទផ្សេង។

[១០:១៣:៣០]

**លោក អេនគ្រូ អ៊ីន្ទូហ្ស៊ី៖**

សូមអរគុណលោកស្រីចៅក្រម ខាតវ៉ាយថ៍។ ខ្ញុំធ្វើជាមេធាវីយូរហើយ ប៉ុន្តែខ្ញុំយល់ឃើញថា--

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

លោក អ៊ីន្ទូហ្ស៊ីៗ

**លោក អេនគ្រូ អ៊ីន្ទូហ្ស៊ី៖**

យើងមានតុលាការនេះត្រូវការកត់ត្រានៅលើក្រដាសនៅក្នុងប្រតិចារឹក។ តើលោកស្រីចៅក្រមតើនៅលើផែនដីនេះ ដែលលោក លោកស្រីរកឃើញថាមានលក្ខខណ្ឌគតិយុត្តិណាដែលអាចមកគាំទ្រ

នូវអ្វីដែលលោកស្រីលើកឡើងនេះ?

[១០:១៤:១០]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញបន្តទៀត បន្តសំណួរផ្សេងទៀត បើសិនជាលោកនៅមានសំណួរ។ បើអស់សំណួរហើយ គឺលោកអាចផ្តល់វេទិកាជូនទៅក្រុមមេធាវីដទៃទៀត។

**លោក អេនគ្រូ អ៊ីនូហ្សី៖**

សូមអរគុណលោកប្រធាន។ ខ្ញុំត្រូវបានបង្ខំឱ្យបោះបង់ចោលនូវសំណួរប្រាំ ដែលខ្ញុំត្រូវសួរតទៅទៀត។ អង្គជំនុំជម្រះកំពុងតែចាប់បង្ខំខ្ញុំឱ្យខ្ញុំបោះបង់សំណួរប្រាំ ពាក់ព័ន្ធចោល។

**ប្រធានអង្គជំនុំ៖**

បើលោកគ្មានសំណួរទៀតទេ សូមលោកអង្គុយចុះ! យើងផ្តល់វេទិកាទៅឱ្យក្រុមមេធាវីការពារក្តីផ្សេងទៀត។

[១០:១៥:០១]

**លោក អេនគ្រូ អ៊ីនូហ្សី៖**

សូមអរគុណលោកប្រធាន។ ខ្ញុំប្រហែលជាមានសំណួរនៅបីទំព័រទៀត ដែលត្រូវសួរបន្ត។ ខ្ញុំនឹងខិតខំប្រឹងប្រែងឱ្យចប់មុនពេលសម្រាកនៅពេលខាងមុខបន្តិចទៀតនេះ។

**សួរដោយលោក អេនគ្រូ អ៊ីនូហ្សី៖**

**ស៖** លោកសាក្សី ទាក់ទងទៅនឹងសេចក្តីសម្រេចចុងក្រោយរបស់អង្គជំនុំជម្រះនេះ ដែលត្រូវយោងទៅលើឯកសារ។ លោកសាក្សី លោកបានលើកឡើងពីមុនថា លោកបានមកពិនិត្យ មកធ្វើទស្សនកិច្ចនៅទីរួមខេត្តបាត់ដំបង។ ឥឡូវខ្ញុំសូមលើកឡើងអំពីព្រឹត្តិការណ៍ ដែលកើតឡើងនៅក្នុងទីក្រុងទីរួមខេត្តបាត់ដំបងនោះ ខ្ញុំសូមសួរសំណួរដូចតទៅនេះ៖

ខ្ញុំសូមយោងទៅលើឯកសារ E5 សូមដកស្រង់ "យើងខ្ញុំបាននិយាយជាមួយចៅក្រម និល គឺនិល ណុន គាត់ថាគាត់ពាក់ព័ន្ធទៅនឹងបញ្ហានេះ គឺថាគាត់ត្រូវតែការពារទៅដល់វិជ្ជាជីវៈរបស់ខ្លួន។ គាត់ទទួលស្គាល់ថា គាត់ -- លោកចៅក្រម និល ណុន គឺថាបានទទួលយកសំណូក ប៉ុន្តែក្រោយតែពេលរឿងនោះបញ្ចប់ហើយទេ--

[១០:១៦:១៥]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះបានសម្រេចបញ្ហានេះដាច់ស្រេចហើយ។ ហើយលោកក៏បានប្តឹងឧទ្ធរណ៍ ប្តឹងសារទុក្ខរួចហើយដែរ លើបញ្ហាអស់នេះ។ បញ្ហាមួយ គឺអង្គជំនុំជម្រះបានសម្រេចរួចហើយ លោកមិនអាចលើកឡើងដដែលៗរបៀបនេះបានទេ។ អង្គជំនុំជម្រះមិនអនុញ្ញាតឲ្យធ្វើដូច្នោះទេ។ ហើយយើងបានស្តាប់ច្រើននូវសំណួររបស់លោក។ សំណួរជាច្រើនដែលលោកចាប់ផ្តើមសួរសាក្សី ជាសំណួរមិនពាក់ព័ន្ធទៅនឹងអង្គហេតុចោទប្រកាន់ទៅលើកូនក្តីរបស់លោកទេ។ យើងព្យាយាមដើម្បីប្រឹងប្រែងស្តាប់នូវការតាំងសំណួររបស់លោកតាំងពីដំបូង ដើម្បីយល់គំនិតរបស់លោក។ ប៉ុន្តែឃើញថា ទីចុងបញ្ចប់លោកបានផ្លាស់ប្តូរមានការពាក់ព័ន្ធទៅនឹងអង្គហេតុ អ៊ីចឹងហើយបានយើងអនុញ្ញាតឲ្យលោកសួរ។

លោករៀបចំសំណួរទាំងឡាយដែលពាក់ព័ន្ធទៅនឹងអង្គហេតុ ដែលចោទប្រកាន់ គឺសារធាតុទៅលើកូនក្តីរបស់លោក!

**លោក អេនគ្រូ អ៊ីន្ទូហ្វ៊ី៖**

សូមអរគុណលោកប្រធាន។ ដើម្បីជាប្រតិចារឹក គឺថាយើងខ្ញុំមិនបានប្តឹងសារទុក្ខទៅលើចំណុចនេះទេ។

[១០:១៧:៥៩]

**ប្រធានអង្គជំនុំ៖**

យើងមិនអនុញ្ញាតឲ្យលោកលើកបញ្ហានេះទេ។ លោកអាចតាំងសំណួរដេញដោលទៅលើអង្គហេតុ ដែលអង្គជំនុំជម្រះកំណត់ឲ្យធ្វើសវនាការសម្រាប់វគ្គពីរ និងអង្គហេតុផ្សេងទៀត ដែលសាក្សីនេះបានដឹង។

**លោក អេនគ្រូ អ៊ីន្ទូហ្វ៊ី៖**

សូមអរគុណលោកប្រធាន។ ក្នុងករណីនេះ ខ្ញុំសូមបន្តទៅប្រធានបទថ្មី។

**សួរដោយលោក អេនគ្រូ អ៊ីន្ទូហ្វ៊ី៖**

**ស៖** លោកសាក្សី លោកដឹង -- លោកនៅចាំឈ្មោះតាជាម ទេ?

**លោក មាស វឿន៖**

**ឆ៖** បាទ ចាំ។ តាជាម គាត់មិនទទួលអីផង ឬក៏ ជាម ណា? ណានៅក្នុងណា? ខ្ញុំដឹងតែឈ្មោះជាម ប៉ុន្តែជាមគ្រាន់មានច្រើនដែរ។

**ស៖** សូមបន្តទៅទៀត ខ្ញុំសូមបញ្ជាក់ចំណុចនេះ។ ឈ្មោះណាដែលលោកកំពុងតែនិយាយទៅសំដៅនេះ? លោកកំពុងនិយាយឈ្មោះ តាជាម មែនទេ?

**ឆ៖** អ្ហ៎! តាជាម លោកបញ្ជាក់ថា តាជាម ហ្នឹងគាត់នៅកន្លែងណា? ដឹងថាឈ្មោះ ជាម ប៉ុន្តែ ជាម វាច្រើន ដែលខ្ញុំមិនអាចដឹងថា ឈ្មោះ ជាម ហ្នឹង, ដឹង ជាម នៅកន្លែងណាដែលខ្ញុំ ខ្ញុំចង់ដឹងត្រង់ហ្នឹង។

[១០:១៩:៤៦]

**ស៖** សូមអរគុណលោកសាក្សី។ បុគ្គលដែលខ្ញុំសួរនេះគឺឈ្មោះភី ភួន ១ហៅ ជាម នេះគឺ ឬក៏ឈ្មោះ រ៉ចាម តុន នេះ។ លោកស្គាល់ឈ្មោះនេះតែម្តង ឬក៏លោកស្គាល់ តាជាម ណាផ្សេង?

**ឆ៖** បាទ ខ្ញុំស្គាល់ ជាម ផ្សេង។ ខ្ញុំស្គាល់តែឈ្មោះ ជាម ផ្សេងទៀត ប៉ុន្តែគាត់នៅ១ សព្វថ្ងៃគាត់នៅ ជាម ហ្នឹង ប៉ុន្តែគ្រាន់មិនមែនឈ្មោះ ជាម ហ្នឹងមិនដឹង។

**ស៖** សូមអរគុណលោកសាក្សី។ ខ្ញុំអស់សំណួរទៅលើចំណុចនេះហើយ ឈ្មោះនេះហើយ។ សំណួរចុងក្រោយ មុននឹងខ្ញុំអង្គុយចុះ។ លោកសាក្សី ដឹងទេតាមចំណេះដឹងរបស់លោក ដែលថាមានហេតុផលមួយក្នុងបណ្តាហេតុផលជាច្រើន ដែលពាក់ព័ន្ធទៅដល់តុលាការក្រុងភ្នំពេញបានកាត់លោក ម៉ម សូណង់ដូ នោះ ដោយសារថាវិទ្យុផ្សាយសំឡេងរបស់គាត់ គឺបានញុះញង់សាធារណជន ពាក់ព័ន្ធទៅនឹងពាក្យបណ្តឹងប្តឹងជំទាស់ទៅនឹងនាយករដ្ឋមន្ត្រី ហ៊ុន សែន?

[១០:២១:០៩]

**ប្រធានអង្គជំនុំ៖**

សំណួរនេះ មិនពាក់ព័ន្ធជាមួយនឹងអង្គហេតុនេះ បន្តិចបន្តួចទាល់តែសោះ។

សាក្សីមិនបាច់ឆ្លើយនឹងសំណួរប្រភេទនេះទេ!

**លោក អេនគ្រូ អ៊ីនូហ្វ៊ី៖**

សូមអរគុណលោកប្រធាន។ សូមបញ្ចប់ត្រឹមហ្នឹង។ តុលាការព្រហ្មទណ្ឌអន្តរជាតិ ត្រូវបានចោទប្រកាន់--

**ប្រធានអង្គជំនុំ៖**

យើងបានប្រាប់លោកច្រើនដងហើយ យើងមិនបណ្តែតបណ្តោយឲ្យលោកឡើងធ្វើអត្ថាធិប្បាយអីផ្សេងៗ តាមតែលោកចង់នោះទេ។ យើងបានផ្តល់វេទិកាឲ្យលោកតាំងសំណួរដេញដោលចំពោះសាក្សី

ពាក់ព័ន្ធនឹងអង្គហេតុទាំងឡាយ ដែលអង្គជំនុំជម្រះកំណត់យក -- លើកយកមកធ្វើសវនាការពិភាក្សាដេញដោល នៅក្នុងសំណុំ -- ក្របខ័ណ្ឌក្នុងសំណុំរឿង០០២/០១ លើកលែងតែសាក្សីឯណាដែលអង្គជំនុំជម្រះកំណត់ថា អាចសួរនៅគ្រប់អង្គហេតុទាំងអស់ ពាក់ព័ន្ធនឹងសំណុំរឿង០០២ ទាំងមូលប៉ុណ្ណោះ។

[១០:២២:២១]

**លោក អេនច្រូ អ៊ីន្ទហ្វ៊ី៖**

សូមអរគុណលោកប្រធាន។ សំណួររបស់ខ្ញុំមិនទាន់ចប់នៅឡើយទេ ខ្ញុំសូមយោងទៅលើលោក វ៉ូជី ដែលគឺថា គឺថាអាចគ្រាន់តែថាជាអ្នកជាតន្ត្រីករមួយដ៏ជំនាញល្បីល្បាញមិនមែនជាមេធាវីដែលល្បីនោះទេ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក អៀង សារី ដើម្បីមានឱកាសក្នុងតាំងការសំណួរដេញដោលចំពោះសាក្សីរូបនេះ។

[១០:២៣:០៩]

**លោក ម៉ៃខល កាណាវ៉ាស៖**

សូមជម្រាបសួរលោកប្រធាន ជម្រាបសួរលោក លោកស្រីចៅក្រម អស់លោក លោកស្រីសាធារណជនទាំងក្នុង ទាំងបណ្តាគ្រប់ -- ក្រៅបន្ទប់សវនាការ។

**សួរដោយលោក ម៉ៃខល កាណាវ៉ាស៖**

**ស៖** លោកសាក្សី ជាមួយនឹងសហភាតារបស់ខ្ញុំលោក អាង ឧត្តម ខ្ញុំមានសំណួរមួយចំនួនតូចសួរទៅលោក។ ខ្ញុំសូមយោងទៅលើចម្លើយរបស់លោកនៅថ្ងៃ០៣ ខែមីនា ២០១០ គឺឯកសារ E3/80។ ខ្ញុំយោងទៅលើចម្លើយដែលនៅត្រង់ទំព័រជាភាសាខ្មែរ ERN00486472, ERN ជាភាសាបារាំង 00509787 ដល់ 88, ERN អង់គ្លេស 00491657។ មានការតាំងសំណួរទៅកាន់រូបលោក នៅខាងដើមទំព័រដែលសួរថា “ចម្លើយរបស់ ជូ ជេត ហៅ ស៊ី” ហើយបន្ទាប់មក គឺនៅក្នុងចម្លើយនេះគេបានដកសម្រង់សម្តីពីចម្លើយសារភាព។ “តើចម្លើយសារភាពនេះ ដែលបានបង្ហាញជូនលោក --” គេគ្រាន់តែអានឲ្យលោកស្តាប់ ឬក៏អ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតអានឲ្យលោកស្តាប់ ឬក៏លោក -- បាទ គេគ្រាន់តែបង្ហាញឯកសារនេះ ចម្លើយសារភាពនេះទៅលោក ឬក៏អានឲ្យលោកស្តាប់? បាទ ខ្ញុំចង់ឲ្យលោកឆ្លើយនូវចំណុចនេះតែម្តង។

**លោក មាស វឿន៖**

**ឆ៖** បាទ គេគ្រាន់តែអានតើ! អានឲ្យស្ដាប់។

**ស៖** តើអ្នកស៊ើបអង្កេតមានអានចម្លើយសារភាពណាផ្សេងទៀត អ្នកស៊ើបអង្កេតដែលតំណាងឲ្យការិយាល័យសហចៅក្រមស៊ើបអង្កេត ដែលមានបុគ្គលិកបរទេស ហើយគឺដោយសារថាច្បាប់ហាមឃាត់មិនឲ្យប្រើប្រាស់ចម្លើយសារភាពណា ដែលបានទទួលបានដោយការធ្វើទារុណកម្មនោះទេ។ ដូច្នេះខ្ញុំសួរថាតើគេមានអានចម្លើយសារភាពដទៃទៀតណា ឲ្យលោកស្ដាប់ទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក អាប់ឌុលឡាក់ ថារីក៖**

ខ្ញុំសូមជំទាស់ទៅនឹងសំណួរ ដែលមេធាវីការពារក្ដីបានប្រើក្នុងការប្រើប្រាស់ឯកសារក្នុងពេលសម្ភាសស្ដាប់ចម្លើយសាក្សីនោះ។ ដើម្បីជាការយោង ហើយដោយយោងទៅលើការងាររបស់សហចៅក្រមស៊ើបអង្កេត គឺទាក់ទងទៅនឹងការសាកសួរសាក្សី គឺថាមិនពាក់ព័ន្ធទៅនឹងបញ្ហានោះទេ។ មេធាវីការពារក្ដី គឺថាគាត់គួរសួរសំណួរផ្ទាល់ៗទៅសាក្សីតែម្ដង សំណួរដែលពាក់ព័ន្ធទៅនឹងអង្គហេតុដែលសាក្សីអាចនឹងដឹងផ្ទាល់ៗតែម្ដង។

[១០:២៦:៣៤]

**លោក ម៉ៃខល កាណាវាស៖**

ខ្ញុំគ្រាន់តែឆ្លើយតបទៅនឹងចំណុចនេះ។ ចំណុចនេះគឺកើតឡើងពីម្សិលមិញ នៅពេលចៅក្រមមួយរូបគាត់បានយោងទៅលើចម្លើយសារភាពដែរ។

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** លោកសាក្សី តើអ្នកស៊ើបអង្កេតមានយោងទៅលើចម្លើយសារភាពណាទៅដល់លោកទេ ក្នុងពេលសម្ភាសលោកនៅពេលនុ៎ង ឬក៏ក្នុងពេលសម្ភាសលើកណាផ្សេងទៀតទេនោះ? តើមានបង្ហាញឯកសារណាមួយទៅលោកទេ?

**លោក មាស វឿន៖**

**ឆ៖** បាទ គាត់មិនបានអានឯកសារណា ដែលចម្លើយរបស់ តាស៊ី ទេ គាត់អានតែសេចក្ដី

វាយការណ៍ខាងក្រោមត្រឹមតំបន់អីខ្លះ ហើយនិងឯកសារខ្លីៗ ស្តីពីការកម្ទេចខ្មាំងប៉ុណ្ណោះឯង ហើយក្រៅពីហ្នឹងឯកសារច្រើនទៀត គាត់អត់បានអានឲ្យខ្ញុំស្តាប់ទេ។

[១០:២៧:៤០]

**ស៖** បើសិនណាលោកពិនិត្យមើលចម្លើយរបស់លោកនៅទំព័រទី១ ដើមដំបូងនៅម៉ោងដប់ម្ភៃនាទីព្រឹក។ បើមើលទំព័រចុងក្រោយ គឺថាការសម្ភាសនេះត្រូវបានបញ្ចប់នៅម៉ោងដប់ប្រាំពីរ និងសាមសិបនាទី ប្រហែលជាសម្ភាសអស់រយៈពេល៧ម៉ោង ១០នាទី។ យើងមានខ្សែអាត់ថតសំឡេងដែរ ដែលបានថតសំឡេងប្រហែលជា ២ៗម៉ោង ៤០នាទី។ នៅក្នុងខ្សែអាត់ដែលខ្លីយ៉ាងនេះ ហើយបាត់បង់ម៉ោងដ៏ច្រើនអ៊ីចេះ លោកអាចជម្រាបមកអង្គជំនុំជម្រះបានទេ ថាតើអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតគាត់ធ្វើអី រយៈដ៏ច្រើនម៉ោងដែលៗលើសពីការថតខ្សែអាត់នេះ?

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាន យើងខ្ញុំសូមជំទាស់ទៅនឹងសំណួរនេះ។

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញ!

[១០:២៩:០០]

**លោក អាប់ឌុលឡាក់ ថារីក៖**

សំណួរនេះគឺជាការធ្វើការសន្មត ដែលថាក្នុងខ្សែអាត់ហ្នឹង គឺបាត់ពេលវេលាអស់ដល់ទៅ៥ម៉ោងឯណោះ។ ដូច្នេះគួរតែត្រូវពន្យល់ថា តើវាខុសគ្នាយ៉ាងម៉េចរវាងពេលវេលា ដែលចំណាយក្នុងការកត់ត្រា និងពេលវេលាចំណាយក្នុងការថតខ្សែអាត់នេះ? ដូច្នេះសំណើរបស់តំណាងសហព្រះរាជអាជ្ញា គឺថាត្រូវតែសួរទៅលើអង្គហេតុ ដើម្បីឲ្យសាក្សីរូបនេះ គាត់ឆ្លើយ។

**លោក ម៉ៃខល កាណាវាស៖**

លោកប្រធាន យើងខ្ញុំមិនមានសិទ្ធិអីស៊ើបអង្កេតទាំងមូលនោះទេ។ ខ្ញុំៗមានចម្លើយរបស់សាក្សីដែលចាប់ផ្តើមៗសួរនៅពេលណា ហើយកិច្ចសម្ភាសន៍ស្តាប់ចម្លើយសាក្សីបញ្ចប់នៅពេលណា? ខ្ញុំមានខ្សែអាត់ថតសំឡេង ដែលខ្សែអាត់នោះ គឺថាចំណាយពេលអស់តែ២ម៉ោង ៤០នាទី។ ដូច្នេះ សាក្សីរូបនេះអាចនឹងប្រាប់ខ្ញុំថា តើរយៈពេល ៥ម៉ោងជាងទៀតនេះ រយៈពេល ៥ម៉ោងហ្នឹងតើគាត់ធ្វើអី

ដោយសារវាមិនមាន ៥ម៉ោងនេះ គឺមិនមាននៅក្នុងខ្សែអាត់នោះទេ។ ខ្ញុំមិនដឹងថា ហេតុអ្វីបានជាតំណាងសហព្រះរាជអាជ្ញាគាត់ខ្លាចមិនបានស្ដាប់សាក្សីឆ្លើយទៅវិញដូច្នេះនោះ។

[១០:៣០:២១]

*(ចៅក្រមពិភាក្សាគ្នា)*

[១០:៣១:៣៩]

**ប្រធានអង្គជំនុំ៖**

បាទ សេចក្ដីជំទាស់ និងការបង្ហាញហេតុផលនៃសេចក្ដីជំទាស់របស់តំណាងសហព្រះរាជអាជ្ញាមានលក្ខណៈសមស្រប។ ការសួរដេញដោលឯណាក្នុងបំណងដូចគ្នា និងសំដៅមោឃៈកិច្ចដំណើរការនីតិវិធីដែលធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេត គឺវាមិនត្រឹមត្រូវតាមវិធានផ្ទៃក្នុង ក៏ដូចជាច្បាប់ស្ដីពីនីតិវិធីព្រហ្មទណ្ឌកម្ពុជានោះទេ។ ឥឡូវនេះ មានវត្តមានសាក្សីនៅចំពោះមុខហើយ ប្រសិនបើមានអង្គហេតុណាច្បាស់លាស់ ឬក៏ចង់ដឹង ឬក៏មានភស្តុតាងមិនស៊ីសង្វាក់គ្នា គឺមេធាវីអាចតាំងសំណួរដេញដោលបានហើយ។

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមិនចង់ឲ្យមានការពន្យល់ទេ ប្រហែលជានេះជាជំហររបស់លោកប្រធាន និងលោកចៅក្រមដទៃទៀតនេះ គឺថាមិនជាខុសគ្នា។ យើងខ្ញុំមានសិទ្ធិត្រូវតាំងសំណួរទាំងឡាយណាទៅកាន់សាក្សី។ លោកសាក្សីពីម្សិលមិញគឺ--

[១០:៣៣:០០]

**ប្រធានអង្គជំនុំ៖**

យើងក៏មានសិទ្ធិមិនអនុញ្ញាតសាក្សីឆ្លើយ ឬមិនឲ្យភាគីសួរបានដែរ។ ប្រសិនបើសួរឯណាមិនរួមវិភាគទានក្នុងការស្វែងរកការពិត ឬក៏សំណួរខុសច្បាប់។ មានសំណួរមិនពាក់ព័ន្ធ ឬក៏សំណួរច្រំដែលជាដើម។

**លោក ម៉ៃខល កាណាវាស៖**

លោកប្រធាន ខ្ញុំអត់ចង់ជជែកវែកញែកពីចំណុចនេះទេ។ សំណួរដែលសួរទៅសាក្សីនេះ គឺយើងចង់ដឹងអំពីចម្លើយ -- តម្លៃនៃចម្លើយរបស់សាក្សីរូបនេះ។ នីតិវិធីនៅក្នុងតុលាការនេះប្រហែលជាមិនមែនជានីតិវិធីនៅតុលាការកម្ពុជាទេ ប៉ុន្តែតុលាការនេះត្រូវបានឧបត្ថម្ភថវិកាដោយសហគមន៍អន្តរជាតិ

ត្រូវតែអនុវត្តនូវបទដ្ឋានអន្តរជាតិ។

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** លោកសាក្សីពីម្សិលមិញយើងខ្ញុំបានទទួលនូវប្រតិចារឹក គឺ D369/7.2 នៃកិច្ចសម្ភាសន៍ស្ដាប់ចម្លើយរបស់លោក ហើយប្រហែលជារយៈពេល ១ម៉ោង ២៧នាទី ៦វិនាទី គឺជាសំណួរដែលត្រូវបានសួរឡើងដោយអ្នកស៊ើបអង្កេតជាតិ ដែលគេបង្ហាញឯកសារទង់បដិវត្តទៅឱ្យលោកមើលនៅពេលព្រឹក។ ប៉ុន្តែនៅក្នុងខ្សែអាត់អត់មានការនិយាយយោងទៅដល់ទង់បដិវត្តនេះទេ។ អត់មានលើកឡើងនិយាយអំពីទង់បដិវត្តនេះនោះទេ។ មុនពេលថតសំឡេងនោះ តើអ្នកស៊ើបអង្កេតបានសួរទៅលោក ហើយបានបង្ហាញឯកសារមួយចំនួនក៏ដូចជាទង់បដិវត្តក្នុងការរៀបចំ ក្នុងការតាំងសំណួរទៅលោក និងឱ្យលោកឆ្លើយដើម្បីធ្វើការថតខ្សែអាត់សំឡេងនេះ?

[១០:៣៥:០៩]

**លោក មាស វឿន៖**

**ឆ៖** សូមលោកបញ្ជាក់ម្ដងទៀត។

**ស៖** បាទ លោកសាក្សីមុននឹងសួរ -- អ្នកស៊ើបអង្កេតសួរទៅលោកនៅថ្ងៃទី៣ ខែមីនា ២០១០ នោះ តើលោកមានការនិយាយគ្នា សន្ទនាគ្នាជាមួយអ្នកស៊ើបអង្កេត ហើយអ្នកស៊ើបអង្កេតមានបង្ហាញឯកសារទង់បដិវត្តទៅលោក ឬក៏ឯកសារណាផ្សេងទៀតដែរឬទេ មុននឹងចាប់ផ្ដើមថតសំឡេងរបស់លោកនៅក្នុងខ្សែអាត់នេះ?

**ឆ៖** បាទ កាលដែលគាត់ទៅដល់កន្លែងផ្ទះខ្ញុំនុ៎ង គាត់បានសម្ភាសខ្ញុំហ្នឹង ក៏ប៉ុន្តែគាត់អានឯកសារខ្លះប្រាប់ខ្ញុំដែរ។ ឯទង់បដិវត្តដូចជា ខ្ញុំភ្លេច ខ្ញុំមិនបានចាំ តែខ្ញុំចាំបានតែប៉ុណ្ណឹង បានតែគាត់អានឯកសារខ្លីៗខ្លះឱ្យខ្ញុំស្ដាប់។ ហើយមួយចំនួនធំ ខ្ញុំភ្លេចទៅ ខ្ញុំអត់បានចាំ។ បាទ ប៉ុណ្ណឹងឯង។

[១០:៣៦:៥៩]

**ស៖** បាទ សូមអរគុណលោក។ នៅក្នុងពេលគេសម្ភាសលោក តើមានអ្នកណាម្នាក់អង្គុយក្បែរលោក គឺមានស្ត្រីម្នាក់អង្គុយក្បែរលោក ដើម្បីជួយឆ្លើយដល់លោកដែរឬទេ?

**ឆ៖** បាទ មានគ្រួសារខ្ញុំក៏នៅជិតហ្នឹង។ គ្រួសារខ្ញុំក៏មិនសូវបានជួយឆ្លើយទេ ប៉ុន្តែគ្រាន់បានស្ដាប់ ហើយជួយរំឭកខ្ញុំខ្លះពីការសម្ភាសហ្នឹង ដែលតាមគាត់ដឹងខ្លះ។ បាទ មានប៉ុណ្ណឹង។

**ស៖** សូមអរគុណលោកសាក្សី។

**លោក ម៉ៃខល កាណាវ៉ាស៖**

ខ្ញុំអស់សំណួរ ហើយលោកប្រធាន។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក ២០នាទីចាប់ពីពេលនេះតទៅ រហូតដល់ម៉ោង១១ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកដល់សាក្សី និងមេធាវីប្រឹក្សាសាក្សីនៅក្នុងបន្ទប់រង់ចាំសម្រាប់សាក្សី ហើយនិងឲ្យអញ្ជើញគាត់ឲ្យមកកាន់កន្លែងផ្តល់សក្ខីកម្មនេះវិញនៅវេលាម៉ោង១១។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:៣៨ នាទី ដល់ម៉ោង ១១:០២ នាទី)*

[១១:០២:១២]

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ដើម្បីមានឱ -- មេធាវីការពារក្តីលោក អៀង សារី នៅមានសំណួរទៀតទេ? អំមិញចប់ហើយ មេធាវីជាតិមានទេ?

**លោក អាង ឧត្តម៖**

ជម្រាបសួរលោកប្រធាន។ លោក ម៉ៃខល បានបញ្ជាក់ច្បាស់ហើយថា យើងអស់សំណួរហើយ។ សូមអរគុណ។

[១១:០៣:១៨]

**ប្រធានអង្គជំនុំ៖**

បាទ ផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក ខៀវ សំផន!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ សូមគោរពក្រុមប្រឹក្សាជំនុំជម្រះ! សូមគោរពអង្គសវនាការទាំងមូល!

ខ្ញុំបាទសូមជម្រាបសួរលោក មាស រឿន។ ខ្ញុំបាទឈ្មោះ គង់ សំអុន ជាមេធាវីរបស់លោក ខៀវ សំផន។ ខ្ញុំមានសំណួរមួយចំនួនដើម្បីសាកសួរលោក ហើយសូមឲ្យលោកជួយសហការឆ្លើយនឹងសំណួរតាមអ្វីដែលលោកបានដឹង បានឮ បានឃើញ ក្នុងនាមជាសាក្សីសម្រាប់រឿងក្តីនេះ។

**សួរដោយលោក គង់ សំអុន៖**

**ស៖** ជាមុនដំបូង ខ្ញុំមានសំណួរទាក់ទងទៅនឹងព្រឹត្តិការណ៍ដែលលោកបានចូលរួមនៅក្នុងការតស៊ូ សម័យមុនរដ្ឋប្រហារឆ្នាំ១៩៧០។ ខ្ញុំដឹង -- លោកបានជម្រាបជូនក្រុមប្រឹក្សាជំនុំជម្រះកន្លងមកថា លោកបានចូលរួមតស៊ូក្នុងព្រៃ ដោយសារបញ្ហាទម្លាក់គ្រាប់បែក ឆេះផ្ទះរបស់លោក ហើយ -- (សូមអធ្យាស្រ័យ) ខ្ញុំសូមឲ្យលោកជួយជម្រាបដោយផ្ទាល់វិញថា តើលោកមានមូលហេតុអ្វីដែលនាំឲ្យលោកចូលតស៊ូនៅក្នុងឆ្នាំ១៩៦៧ នោះ? សូមលោកជួយបញ្ជាក់។

[១១:០៥:០២]

**លោក មាស រឿន៖**

**ឆ៖** បាទ ក្នុងឆ្នាំ១៩៦៨ ក្នុងពេលនោះ ខ្ញុំបានមានមេកម្មាភិបាលបានប្រាប់ខ្ញុំ ហើយអប់រំខ្ញុំឲ្យខ្ញុំដឹងយល់ពីប្រទេសរបស់ខ្លួន ក្នុងចំណោមប្រទេសពុំទាន់ឯករាជ្យ ហើយការអប់រំរបស់កម្មាភិបាលជំនាន់នុំងធ្វើដោយស្ងាត់ស្ងៀមមិនជានេះទេ គឺអប់រំដោយមនុស្សម្នាក់ ពីរនាក់តាមរយៈយុវជន ហើយយុវនារីធ្វើស្ងាត់ៗតាមភូមិ ជួនកាលអប់រំនៅពេលយប់ស្ងាត់ៗដើម្បីឲ្យយល់ដឹងអំពីរបបក្នុងរបបជំនាន់សម្តេចគ្រប់គ្រងហ្នឹង។ ដូច្នេះ កាលណាដែលយល់ហើយបានគាត់ឲ្យខ្ញុំម្នាក់ហ្នឹងទៅប្រាប់បន្តយុវជនម្នាក់ទៀត ដើម្បីឲ្យដឹងយល់បន្តៗគ្នា។ ដូច្នេះ គ្មានបានធ្វើចំហទេ ធ្វើក្នុងលក្ខណៈសម្ងាត់ បាទ។

**ស៖** បាទ សូមអរគុណ។ តើលោកដឹងថា អង្គការដែលចាត់តាំងឲ្យមកជួបនឹងលោក អប់រំលោកហ្នឹង ជាអង្គការអ្វីដែរទេ?

**ឆ៖** បាទ អង្គាល់នុំងមិនមានថាអង្គការអ្វីទេ គឺគេអត់ប្រាប់ថាឈ្មោះជាអង្គការអ្វីទេ គឺជាចលនាៗតស៊ូរបស់យើង ដើម្បីឲ្យយើងមានគំនិត មានស្មារតីតស៊ូដើម្បីរំដោះប្រទេសឲ្យរួចពីអាណានិគមនិយមរបស់បារាំង។

[១១:០៧:២៥]

**សៈ** នៅពេលដែលលោកចូលដំបូងនោះ តើលោកបានជួបជាមួយនឹងលោក ខៀវ សំផន ភ្លាម ឬមួយក៏មានរយៈពេលណាមួយដែលលោកបានជួបមួយលោក ខៀវ សំផន នៅឆ្នាំ១៩៦៨ហ្នឹង?

**ឆ៖** បាទ ក្នុងពេលដែលឆ្នាំ១៩៦៨ហ្នឹង ពេលមុនដំបូង គឺមិនទាន់បានជួបគាត់ទេ ប្រហែលជាឆ្នាំ១៩៦៩ ឬក៏ពាក់កណ្ដាល ខ្ញុំមិនចាំថ្ងៃខែ ពេលនោះខ្ញុំបានស្ដាប់វិទ្យុរបស់ភ្នំពេញមានការប្រជុំសមាជទៅ ហើយស្ដាប់ទៅឮលោក ខៀវ សំផន មានការទំនាស់ជាមួយនឹងសម្ដេច សីហនុ ហើយដល់ពេលនោះក៏លោក -- ប្រហែលជាលោករស់នៅមិនបាននៅទីក្រុងភ្នំពេញ ក៏លោកចេញមកក្រៅមក ហើយកម្មាភិបាលប្រាប់ខ្ញុំឲ្យទៅទទួលគាត់តាមផ្លូវលេខ៤ ជិតម្ដុំដោះកញ្ជរ ខាងកើតពេជ្រនិលហ្នឹង ពេលប្រហែលជាម៉ោង៧ដប់ជាង ជិតដប់មួយយប់ គាត់ចេញមកតាមផ្លូវហ្នឹង ហើយគាត់ចូលព្រៃ។ ហើយខ្ញុំបានទៅទទួលកម្មាភិបាលដែលខ្ញុំទទួលនៅកន្លែងហ្នឹងនាំចូលព្រៃអត់នៅភូមិទេ នៅក្នុងព្រៃ។

[១១:០៩:០៦]

**សៈ** លោកនិយាយថា ចូលព្រៃ អត់នៅក្នុងភូមិ ហើយមានកម្មាភិបាលឲ្យទៅទទួលហ្នឹង កម្មាភិបាលដែលលោកនិយាយហ្នឹងជាអ្នកណាដែរ? ហើយពេលដែលលោកទៅទទួលហ្នឹងជាពេលណាពិតប្រាកដដែរ បើលោកបានដឹង?

**ឆ៖** បាទ កម្មាភិបាលហ្នឹងឈ្មោះ មឿន គាត់នៅភូមិតាឡាត់ តែឥឡូវមិនដឹងគាត់ស្លាប់ឬរស់យ៉ាងណាទេ ខ្ញុំមិនបានជួបគាត់ទេ។ ហើយពេលវេលាយប់ ហើយមិនដឹងថាម៉ោងប៉ុន្មាន ខ្ញុំមិនដឹងថាម៉ោងប៉ុន្មាន ប៉ុន្តែពេលយប់បាទ។

**សៈ** ខ្ញុំចង់សួរបញ្ជាក់ថា ពេលហ្នឹងគឺពេលដែលលោក ខៀវ សំផន ចាកចេញភ្លាមៗ ឬក៏មានរយៈពេលមួយរយៈហើយ? ឧទាហរណ៍ថា លោក ខៀវ សំផន គាត់បានចាកចេញយូរហើយ បានមកជួបលោកដែលមានកម្មាភិបាលឲ្យទៅទទួលនោះ។

**ឆ៖** បាទ យូរបន្តិចដែរ។

**សៈ** ពេលហ្នឹង លោកមានតួនាទីជាអ្វីដែរ?

**ឆៈ** បាទ ពេលនុ៎ង ពួកយុវជនខ្ញុំមានតួនាទីការពារគាត់ ហើយនាំផ្លូវ ឲ្យទៅរកកន្លែងណាដែលមិនអាចខ្មាំងរកគាត់ឃើញ។

[១១:១០:៤៩]

**សៈ** បាទ សូមអរគុណ។ សូមលោកបញ្ជាក់ពីតួនាទីរបស់លោក ក្នុងនាមជាអ្នកនាំផ្លូវ ជាអ្នកការពារ ជាអ្នកយកគាត់ទៅលាក់កន្លែងណា ដែលមិនឲ្យខ្មាំងរកឃើញហ្នឹង លោកមានឋានៈជាអ្វីនៅក្នុងជួរចលនាតស៊ូរបស់លោកនោះ?

**ឆៈ** បាទ ខ្ញុំតួនាទីជាយុវជន ហៅ យុវជនស្នេហាជាតិនៅជនបទ។

**សៈ** បាទ សូមអរគុណ។ ចុះការទំនាក់ទំនងរបស់លោក ក្នុងនាមជាយុវជនស្នេហាជាតិជាមួយនឹងលោក ខៀវ សំផន នុ៎ង មានកម្រិតណាដែរ? លោកអាចបញ្ជាក់បានទេ?

**ឆៈ** បាទ ខ្ញុំមិនអាចបញ្ជាក់បានទេ ពីព្រោះខ្ញុំមិនទាន់បានការទទួលការអប់រំនយោបាយអត់ទាន់ច្បាស់។

**សៈ** អ៊ីចឹង មានន័យថា នៅពេលនោះ គឺលោកមិនមានទំនាក់ទំនងការងារជិតដិតជាមួយលោក ខៀវ សំផន ទេ។ លោកស្ថិតនៅក្នុងក្រុមយុវជនការពារ ក្នុងចំណោមយុវជនដទៃទៀត តើអ៊ីចឹងមែនទេ?

**ឆៈ** បាទ យុវជនដទៃទៀតក៏មកចូលរួមជាមួយគ្នាដែរ ក៏ប៉ុន្តែពេលដែលយកគាត់ទៅដល់កន្លែងដែលយើងទុកដាក់ហើយ យើងចេញមកធ្វើការងារខាងក្រៅ ដើម្បីឃាមល្បាតការពារផ្លូវ ការពារអី ដែលនៅជាមួយ ខ្ញុំអត់បាននៅជាមួយទេ បាទ។

[១១:១២:៥២]

**សៈ** ក្នុងចម្លើយរបស់លោកពីខាងដើម លោកបានលើកអំពី តាម៉ុក ដែលជាអ្នកដឹកនាំនៅក្នុងការគ្រប់គ្រងបុគ្គលមួយចំនួន ដែលរួមមានលោក ខៀវ សំផន ផងដែរនោះ។ លោកអាចបញ្ជាក់បានទេថាការដឹកនាំ ការគ្រប់គ្រងរបស់ តាម៉ុក នៅក្នុងពេលនោះ វាជាលក្ខណៈយុទ្ធសាស្ត្រ ឬមួយក៏ជាលក្ខណៈគេចខ្លួន?

**ឆៈ** បាទ ការដឹកនាំរបស់ពីកម្មាភិបាលដែលគ្រប់គ្រងខ្ញុំហ្នឹងទៅ តាមឿន ទៅ គឺតពី តាមឿន ទៅ តាម៉ុក។ ឯ តាម៉ុក ហ្នឹង គាត់អ្នកដែលរៀបចំណែនាំសួរមុននឹងគាត់ឲ្យយកខ្ញុំ ឬក៏យកលោក ខៀវ សំផន ទៅកន្លែងណា គាត់ពិគ្រោះជាមួយនឹង តាមឿន។ ពីព្រោះ តាមឿន គាត់ជាអ្នកស្គាល់ព្រៃ ភូមិ

សាស្ត្រ កន្លែងត្រង់ណាដែលខ្លាំងត្រូវដើរ កន្លែងត្រង់ណាដែលខ្លាំងមិនត្រូវដើរ មានសុវត្ថិភាពគាត់។ ហើយគាត់ពិភាក្សាទៅ ហើយខ្ញុំគ្រាន់តែជួយដឹកនាំការពារជូនគាត់ដល់កន្លែងហើយ ខ្ញុំនឹងធ្វើការងារខ្ញុំដោយឡែកវិញ បាទ។

**សៈ** ខ្ញុំចង់សួរបញ្ជាក់ថា ការដឹកនាំដែលលោកមានប្រសាសន៍នេះ ជាការជូនដំណើរក្នុងក្រុមទៅជាមួយគ្នា ឬមួយក៏ជាការដើរការពារល្បាតឆ្ងាយពីលោក ខៀវ សំផន នៅពេលនោះ?

[១១:១៤:៥៧]

**ផៈ** បាទ ដើរទៅជាមួយគ្នា។

**សៈ** អម្បាញ់មិញលោកមានប្រសាសន៍អំពី តាម៉ុក គាត់ទទួលបន្តការពារលោក ខៀវ សំផន និងអ្នកដទៃទៀតពី តាមឿន។ លោកអាចបញ្ជាក់ពេលណាដែរទេ? ចាប់ពីពេលណាមក?

**ផៈ** បាទ ពេលដែលលោក ខៀវ សំផន ចូលព្រៃ ថ្ងៃគាត់ចេញមកដល់ព្រៃ។

**សៈ** លោកចង់មានប្រសាសន៍ថា ជាថ្ងៃដំបូងដែលលោក ខៀវ សំផន ចូលព្រៃ ឬមួយក៏មិនមែនទេ?

**ផៈ** បាទ ថ្ងៃហ្នឹងហើយ ថ្ងៃលោក ខៀវ សំផន ចូលព្រៃ ប៉ុន្តែមិនដឹងជាថ្ងៃណា ដឹងតែឆ្នាំៗ។

**សៈ** បាទ ខ្ញុំចង់ធ្វើការបញ្ជាក់អ៊ីចេះ ព្រោះមុននឹងបន្តិច លោកបានឆ្លើយថា លោកបានជួបលោក ខៀវ សំផន ហ្នឹងគឺមួយរយៈក្រោយពីលោក ខៀវ សំផន បានចូលព្រៃទៅហើយ ហើយលោកធ្វើការជាមួយ តាមឿន ដែលជាអ្នកគ្រប់គ្រងរបស់លោក។ ហើយបន្ទាប់មកទើបមាន តាម៉ុក មកទទួលទៀត។ អ៊ីចឹងបានន័យថា តាម៉ុក ទទួលការពារជូនលោក ខៀវ សំផន គឺក្រោយ តាមឿន ទេ អ៊ីចឹងមានន័យថាមិនមែនពេលដែលលោក ខៀវ សំផន ចូលព្រៃភ្លាមទេ។ ហើយអម្បាញ់មិញលោកមានប្រសាសន៍ថា ទទួលលោក ខៀវ សំផន ភ្លាម។ អ៊ីចឹងវាអាចធ្វើឲ្យមានការច្រឡំទៅលើអង្គហេតុនេះ លោកអាចបញ្ជាក់សាជាថ្មីបានទេ ទាក់ទងនឹងចំណុចនេះ?

[១១:១៦:៥៧]

**ផៈ** បាទ ខ្ញុំបញ្ជាក់អ៊ីចេះ តាមឿន -- តាម៉ុក ចូលព្រៃ ហើយ តាមឿន ហ្នឹងទទួលបញ្ជាពី តាម៉ុក ហើយ តាម៉ុក ហ្នឹង អ៎! តាមឿន ទទួលបញ្ជាពី តាម៉ុក ហើយ តាមឿន ហ្នឹងបានមករៀបចំមកទទួលលោក ខៀវ សំផន។ ដូច្នេះការដែលនេះ -- ការដែលរៀបចំហ្នឹងគឺ តាម៉ុក គាត់ចូលព្រៃដែរហើយ។

**ស៖** បាទ សូមអរគុណ។ អម្បាញ់មិញខ្ញុំសូមឲ្យលោកបញ្ជាក់ពីរយៈពេលដែល តាម៉ុក ទទួលការពារលោក ខៀវ សំផន ហ្នឹង គឺថាពីពេលលោក ខៀវ សំផន ចូលមកភ្លាម ចូលព្រៃភ្លាម ឬមួយក៏មួយរយៈពេលបន្ទាប់ពី តាមឿន ទទួលផ្តល់ការការពារនោះមួយរយៈ ហើយទើប តាម៉ុក ចូលមកទទួលបន្ត?

**ឆ៖** បាទ តាម៉ុក ចូលព្រៃហើយ បានលោក ខៀវ សំផន ចេញមក។

[១១:១៨:០៨]

**ស៖** បាទ អ៊ីចឹងលោក ខៀវ សំផន ដែលពេលដែលគាត់ចូលព្រៃហ្នឹង ចូលក្នុងព្រៃភ្លាមជួបលោក -- ជួប តាម៉ុក ហ្នឹងភ្លាម ឬក៏មិនទាន់ជួបទេ ហើយជួប តាមឿន មុន?

**ឆ៖** បាទ ជួប តាមឿន មុន ហើយនិងពួកខ្ញុំដែលការពារហ្នឹងមុនគេ បាននាំទៅដល់កន្លែង តាម៉ុក។

**ស៖** អ៊ីចឹងសូមបញ្ជាក់ឡើងវិញ អ៊ីចឹងបានន័យថា នៅពេលដែលលោក ខៀវ សំផន ចូលព្រៃហ្នឹង ជួប តាមឿន ហើយជួបនឹងក្រុមការពាររបស់លោក ហើយបានលោកនាំទៅជួប តាម៉ុក។ អ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** បាទ អ៊ីចឹង។

**ស៖** បាទ សូមអរគុណ។ តើលោកដឹងថាលោក ខៀវ សំផន គាត់ធ្វើជាអ្វីដែរនៅក្នុងព្រៃហ្នឹង គាត់មានឋានៈជាអ្វីដែរ? លោកអាចបញ្ជាក់បានទេ?

[១១:១៩:១៣]

**ឆ៖** បាទ នៅពេលនោះគាត់អត់បានធ្វើអ្វីទេ គាត់នៅធម្មតា ដើម្បីគេចឲ្យផុតពីការរករឿងរបស់គាត់ពីភ្នំពេញទៅ។

**ស៖** បាទ សូមអរគុណ។ លោកដឹងថាមូលហេតុអីបានជាលោក ខៀវ សំផន រត់គេចចូលព្រៃពីការរករឿងដែលលោកមានប្រសាសន៍អម្បាញ់មិញនេះទេ?

**ឆ៖** បាទ ខ្ញុំពេលនោះ ខ្ញុំមិនបានសួរសាកគាត់ទេ ក៏ប៉ុន្តែខ្ញុំស្តាប់វិទ្យុៗ ដែលសម្តេច សីហនុ បានជេរគាត់ ហើយនិងរកគាត់រហូតដល់រកកាត់ក្បាលគាត់។ អង្កាល់ណោះ ខ្ញុំមិនចាំទេ គ្រាន់ថានរណារកឃើញ ខៀវ សំផន ឬ ហ៊ូ នឹម ឬ ហ៊ូ យន់ អីគាត់ សម្តេចឲ្យប្រាក់លើកទឹកចិត្តប៉ុន្មានទេ ប្រហែលជា ៧លាន ខ្ញុំចាំមិនច្បាស់ និង គាត់ទំនាស់រឿងអី ខ្ញុំមិនដឹង តែខ្ញុំស្តាប់តាមតែវិទ្យុ។

**ស៖** បាទ សូមអរគុណ។ ចុះលោកមានដឹងព្រឹត្តិការណ៍អ្វីផ្សេងទៀត ក្រៅពីការប្រកាសនិងផ្តល់រង្វាន់ចំពោះការផ្តល់ដំណឹងអំពីវត្តមានរបស់លោក ខៀវ សំផន។ លោកមានដឹងអ្វីទៀតពាក់ព័ន្ធទៅនឹងការរត់គេចខ្លួនរបស់លោក ខៀវ សំផន នេះទេ?

[១១:២១:២៤]

**ឆ៖** ខ្ញុំបានដឹងតែលោក ហ៊ូ យន់ ក្នុងពេលដែលលោក ខៀវ សំផន ចេញហើយបានទៅជួបលោក ហ៊ូ យន់ ប៉ុន្តែលោក ហ៊ូ យន់ ខ្ញុំអត់បានទទួលគាត់ទេ។ ក៏ប៉ុន្តែខ្ញុំបាននាំគាត់ទៅដល់ទីកន្លែងសុវត្ថិភាពក្នុងព្រៃ ដើម្បីគេចឲ្យផុតពីការរករឿងហេតុពីខ្មាំងសត្រូវ ហើយនិងលោក ហ៊ូ នឹម ខ្ញុំមិនបានទទួលទេ។ ក៏ប៉ុន្តែបានជូនទៅដល់អាកន្លែងណាដែលមានសុវត្ថិភាព ហើយឲ្យគាត់រស់នៅបាន ទៅកន្លែងនុំងបាទ។

**ស៖** បាទ សូមអរគុណ។ អម្បាញ់មិញលោកបានមានប្រសាសន៍អំពីប្រាក់រង្វាន់ចំពោះការផ្តល់ព័ត៌មានទាក់ទងទៅនឹងលោក ខៀវ សំផន ឬ ហ៊ូ នឹម, ហ៊ូ យន់ ហ្នឹង។ ខ្ញុំមានសំណួរថា ហេតុអីបានជាលោកមិនបានផ្តល់ព័ត៌មាននេះទៅដល់រដ្ឋាភិបាលភ្នំពេញនៅពេលនោះ បើលោកបានដឹងពីវត្តមានរបស់លោក ខៀវ សំផន នោះ?

[១១:២២:៤៣]

**ឆ៖** ក្នុងរឿងហ្នឹង ខ្ញុំមិន -- រដ្ឋអំណាចគេតឹងតែងណាស់ក្នុងនុំង គេស៊ើបអង្កេតកាលណាយើងនិយាយទៅវាមានការចោទប្រកាន់ពីរឿងធ្វើនយោបាយអីចេះអីចុះទៅ ខ្ញុំមិនអាចប៊ានផ្តល់ទៅតាមដំណើរដែលវិទ្យុសម្តេចប្រកាសនោះទេ។ គ្រាន់តែថា ខ្ញុំឮដែលលោក ខៀវ សំផន គាត់ថា អីចេះ គាត់ថា “ការសម្តេចរករឿង ហើយទាមទារតម្លៃខ្លួនគាត់ ឬក្បាលគាត់ហ្នឹង ហើយគាត់ប្រាប់ថា មិនអីទេអា្ហ! មកដល់ព្រៃហើយ”។ អាហ្នឹងគាត់បានពោលពាក្យតែមួយម៉ាត់ប៉ុណ្ណឹងឯង។

**ស៖** បាទ សូមអរគុណ។ លោកនៅជាមួយលោក ខៀវ សំផន ពីឆ្នាំណាដល់ឆ្នាំណា ចុងក្រោយបំផុត ជាអ្នកការពារនោះ?

[១១:២៣:៥៤]

**ឆ៖** បាទ ខ្ញុំការពារគាត់ពីឆ្នាំ១៩៧០ -- ៦៨ មកដល់ ៧០។ មកដល់ឆ្នាំ៧០ រដ្ឋប្រហារ។

**ស៖** បាទ សូមអរគុណ។ ក្រោយរដ្ឋប្រហារលោកមានទំនាក់ទំនងអ្វីជាមួយលោក ខៀវ សំផន ទៀតទេ?

**ឆ៖** បាទ ក្រោយរដ្ឋប្រហារមក គឺដាច់រហូតអត់ដែលបានជួបគាត់ទេ។ ខ្ញុំធ្វើទ័ព ចូលក្នុងកងទ័ព គេហៅ កងទ័ពចល័តមុនដំបូង គេហៅកងទ័ពចល័តហ្នឹង គឺបានប្រហែលជា ១០០នាក់ទេ ហើយឈប់បានទៅជាមួយគាត់ហើយ។

**ស៖** បាទ សូមអរគុណ។ កាលពីថ្ងៃទី០៤ ខែតុលា កន្លងទៅនេះលោកបានឆ្លើយនឹងសំណួរពាក់ព័ន្ធទៅនឹងការបញ្ជូនព័ត៌មានពីសមរភូមិ និងបុគ្គលមួយចំនួនទៅលោក ខៀវ សំផន ដែលគេសួរថា “តើការបញ្ជូនព័ត៌មាននោះដោយរបៀបណា?” ហើយលោកបានឆ្លើយថា ខ្ញុំសូមអានជូននៅត្រង់ទំព័រ៤ ជាភាសាខ្មែរ ក្នុងមុនម៉ោង ០៩:១២ នាទី លោកបានឆ្លើយថា “បាទ ការបញ្ជូនដំណឹងព័ត៌មាននេះតាមវិទ្យុ ហើយតាមប្រដាប់ តាមលេខ១ប្រដាប់ គេហៅអីខ្ញុំភ្លេច អាចទូរស័ព្ទ តេអូ ឬតេអូ”។ បាទ ខ្ញុំចង់សួរលោកថា ហេតុអីបានជាលោកដឹងអំពីការបញ្ជូនព័ត៌មានផ្សេងៗពីសមរភូមិទៅលោក ខៀវ សំផន តាមរយៈតេអូនេះជាដើមនេះ។ តើការឆ្លើយរបស់លោកនេះ វាជាការសន្និដ្ឋានពីមធ្យោបាយបញ្ជូនព័ត៌មានជាទូទៅ ឬមួយក៏លោកបានដឹងច្បាស់អំពីការបញ្ជូនព័ត៌មានទាំងអស់នេះ? សូមលោកជួយឆ្លើយ។

[១១:២៦:៣១]

**ឆ៖** សូមបញ្ជាក់លោកពីឆ្នាំប៉ុន្មាន?

**ស៖** បាទ ក្នុងព្រឹត្តិការណ៍នេះគឺមុនឆ្នាំ៧៥ គឺនៅពេលដែលមានការប្រយុទ្ធគ្នា ក្រោយរដ្ឋប្រហារ មុនឆ្នាំ៧៥ និងក្រោយរដ្ឋប្រហារ។

**ឆ៖** បាទ ក្រោយរដ្ឋប្រហារ មុនឆ្នាំ៧៥ នៅពេលនុ៎ងក្នុងចម្លើយរបស់ខ្ញុំ ខ្ញុំនៅកន្លែងណា? ខ្ញុំអត់បានដឹងថា ខ្ញុំឆ្លើយសំណួរហ្នឹងនៅក្នុងកន្លែងណា ខ្ញុំមិនបានចាំកន្លែង។ សូមលោកបញ្ជាក់កន្លែងបន្តិចដើម្បីឲ្យខ្ញុំតប។

**ស៖** បាទ សូមអរគុណ។ សំណួរនេះគឺទាក់ទងទៅនឹងព្រឹត្តិការណ៍ដែលកើតឡើងនៅក្នុងខែមករា ឆ្នាំ១៩៧៣ ដែលសំណួរត្រូវបានតាំងឡើងសួរអំពីតួនាទីរបស់លោក ខៀវ សំផន ថាធ្វើអីៗហ្នឹង ហើយក្រោយមកក៏បានបន្តសួរទាក់ទងទៅនឹងមធ្យោបាយនៃការផ្តល់ព័ត៌មានពីសមរភូមិទៅលោក ខៀវ សំផន ដោយកាលនោះលោក ខៀវ សំផន មានការតែងតាំងជាអគ្គមេបញ្ជាការ។ អ៊ីចឹងហើយបានធ្វើឲ្យការសន្និដ្ឋានមួយថា មានការផ្តល់ព័ត៌មានពីសមរភូមិទៅអគ្គមេបញ្ជាការ គឺទៅលោក ខៀវ សំផន នេះ។ ក្នុងចម្លើយរបស់លោកនេះ អត់បានបញ្ជាក់ទីកន្លែងទេ។ ដូច្នេះសូមលោកឆ្លើយតាមលទ្ធភាពដែលលោកអាចចាំបាន។

[១១:២៨:៥៣]

**ឆ៖** បាទ ខ្ញុំក្រោយពីឆ្នាំ៧០ ឬក៏មុនឆ្នាំ៧០ ខ្ញុំអត់បានរាយការណ៍អ្វីទៅលោក ខៀវ សំផន ទេ។ ដល់ឆ្នាំ៧៥ ដែលខ្ញុំបានចេញទៅ គេផ្លាស់ខ្ញុំទៅតំបន់១០៣ គឺព្រះវិហារនោះ អាហ្នឹងខ្ញុំបានរាយការណ៍ គាត់បានសរសេរសារទូរលេខមកឲ្យខ្ញុំមួយ ស្តីពីរឿងសភាពការណ៍ក្រុមគ្រួសាររបស់គាត់។ ដូច្នេះក្នុងពេលប្រយុទ្ធនោះ ខ្ញុំអត់បានរាយការណ៍ជូនគាត់ទេ។ ខ្ញុំៗសូមបញ្ជាក់កន្លែងហ្នឹងប៉ុណ្ណឹង។

**ស៖** បាទ សូមអរគុណ។ បាទ ទាក់ទងទៅនឹងតួនាទីរបស់លោក ខៀវ សំផន នៅមុនឆ្នាំ ១៩៧៥ និងក្រោយរដ្ឋប្រហារឆ្នាំ១៩៧០ តើលោកមានដឹងឋានៈអ្វីខ្លះ? តួនាទីអ្វីខ្លះ កិច្ចអ្វីខ្លះដែលលោក ខៀវ សំផន បានធ្វើទេ តាមរយៈជាសាធារណៈ?

**ឆ៖** បាទ កាលណោះខ្ញុំមិនដឹងភារកិច្ចរបស់គាត់ធ្វើអ្វីទេ។ ក៏ប៉ុន្តែ ការស្តាប់វិទ្យុមួយ គេហៅវិទ្យុរណសិរ្សរួបរួមជាតិកម្ពុជានុ៎ង ជំនាន់ហ្នឹងខ្ញុំឮខ្លះ ឮថា ខៀវ សំផន គាត់ប្រធានរណសិរ្សរួបរួមជាតិកម្ពុជា។ ឯការរៀបចំចាត់តាំងគាត់យ៉ាងណានោះ ខ្ញុំមិនបានដឹងទេ។ ស្តាត់តែតាមវិទ្យុ។

[១១:៣០:៥៧]

**ស៖** បាទ សូមអរគុណ។ នៅក្នុងសវនាការកាលពីថ្ងៃទី០៤ ខែតុលាដដែល នៅម៉ោង ០៩:៣៤:៥៨ វិនាទី ត្រង់បន្ទាត់ទី១៤ ជាភាសាខ្មែរ។ សំណួរសួរថា "តាមអ្វីដែលលោកយល់ ថាតើលោក ខៀវ សំផន មានតួនាទីអ្វីដែរនៅពេលនោះ?" លោកឆ្លើយថា "បាទ ពេលនោះគាត់ បើខ្ញុំអត់បានជួបគាត់ទេ ប៉ុន្តែខ្ញុំស្តាប់តាមវិទ្យុ គាត់ជាប្រធានរណសិរ្សរួបរួមជាតិកម្ពុជាប្រជាធិបតេយ្យ"។ ចុះអម្បាញ់មិញនេះលោកបានឆ្លើយថា គាត់ជាប្រធានរណសិរ្សរួបរួមជាតិកម្ពុជា ដោយមិនបានបញ្ជាក់អំពីពាក្យថាប្រជាធិបតេយ្យនៅខាងក្រោយទេ។ តើពីរនេះវាខុសគ្នាយ៉ាងម៉េច ឬមួយក៏លោកអាចពន្យល់បន្ថែមបាន?

**ឆ៖** បាទ កាលនុ៎ងខ្ញុំមិនបានបញ្ជាក់អស់កម្ពុជាប្រជាធិបតេយ្យមែនហើយអង្កាល់នោះបាទ។

**ស៖** លោកច្បាស់ទេថា លោក ខៀវ សំផន ជាប្រធានរណសិរ្សរួបរួមជាតិកម្ពុជាប្រជាធិប-តេយ្យ ដែលលោកមានប្រសាសន៍អម្បាញ់មិញនេះ?

**ឆ៖** បាទ បាន។

**ស៖** បាទ សូមអរគុណ។ ក្រៅពីប្រធានរណសិរ្សរួបរួមជាតិកម្ពុជា តើនៅក្នុងចន្លោះពេលក្រោយរដ្ឋប្រហារឆ្នាំ១៩៧០ ដល់មុនឆ្នាំ១៩៧៥ នោះមានអង្គការអ្វី ស្ថាប័នអ្វីដែលតស៊ូនៅក្នុងព្រៃនោះ

ដែរទេ?

**ឆ៖** បាទ កាលនុំងដូចគ្នានដឹងថាអង្គការអ្វីទេ។ ដឹងតែអង្គការតស៊ូ ប្រាប់ថា ការតស៊ូតែអ៊ីចឹងឯង -- អ៊ូ! អត់មានប្រាប់ថា អង្គការអ្វី ឬនាមអ្វី គឺអត់មានទេ។

**ស៖** បាទ សូមអរគុណ។ តើលោកអាចបញ្ជាក់បានទេថា រណសិរ្សរួបរួមជាតិកម្ពុជាប្រជាធិបតេយ្យ -- (សូមទោស) រណសិរ្សរួបរួមជាតិកម្ពុជាប្រជាធិបតេយ្យ ដែលលោកមានប្រសាសន៍នេះមានន័យដូចម្តេចដែរ? ជាស្ថាប័នអីយ៉ាងម៉េចដែរ? លោកអាចបញ្ជាក់បានទេ?

[១១:៣៤:៣៨]

**ឆ៖** បាទ តាមការដឹងយល់ ពិចារណាខ្លួនឯងថា រណសិរ្សរួបរួមជាតិកម្ពុជាប្រជាធិបតេយ្យនោះ គឺសំដៅការប្រមែប្រមូលកម្លាំងគ្រប់ស្រទាប់ទាំងអស់ ដើម្បីរួមគ្នាតស៊ូរំដោះជាតិ ប៉ុណ្ណោះឯង។

**ស៖** បាទ សូមអរគុណ។ តើលោកដឹងថាអ្នកណាជាមេដឹកនាំធំបំផុត នៅក្នុងរណសិរ្សរួបរួមជាតិកម្ពុជា ប្រជាធិបតេយ្យដែលលោកមានប្រសាសន៍នេះ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក អាប់ឌុលឡាក់ ថារីក៖**

សំណួរត្រូវបានសួរ ហើយឆ្លើយ ហើយសាក្សីបានឆ្លើយរួចហើយតាមការដឹងរបស់គាត់។ លោក ខៀវ សំផន គឺជាប្រធានរបស់ហ្នុង។

[១១:៣៦:១០]

**លោក គង់ សំអុន៖**

ក្នុងចលនានេះ តាមអង្គហេតុវាមានការដឹកនាំដោយឡែក។ អ៊ីចឹងហើយបានខ្ញុំត្រូវតាំងសំណួរទៅសាក្សីទៀត ដើម្បីបញ្ជាក់ថាតើមានអ្នកណានៅលើពីលើលោក ខៀវ សំផន នេះទៀតទេ ក្នុងចលនានេះ?

**ប្រធានអង្គជំនុំ៖**

បាទ សេចក្តីជំទាស់មិនត្រឹមត្រូវទេ មិនមានប្រសិទ្ធភាព។ សាក្សីឆ្លើយតបទៅនឹងសំណួររបស់លោកមេធាវី!

**លោក មាស វឿន៖**

**ឆ៖** បាទ ខ្ញុំដឹងថា ក្នុងរដ្ឋប្រហារ រដ្ឋប្រហាររួចហើយ ក្នុងនុំងគឺមានកម្លាំងដែលរួបរួមការតស៊ូហ្នឹងគឺសម្ដេច សីហនុ។

**សួរដោយលោក គង់ សំអុន៖**

**ស៖** បាទ សូមអរគុណ។ តើលោកមាន -- ក្នុងនាមជាយោធាម្នាក់នៅក្នុងសម័យមុនរំដោះឆ្នាំ១៩៧៥ ដែលលោកបានធ្វើការតស៊ូកន្លងមកនេះ តើក្រុមចលនារបស់លោកមានទំនាក់ទំនងអ្វីជាមួយនឹងចលនារបស់សម្ដេច សីហនុ នោះដែរទេ?

[១១:៣៨:០២]

**ឆ៖** បាទ ក្នុងឆ្នាំ៧០ មានការ មានកម្លាំងរួបរួមជាមួយនឹងចលនាតស៊ូខ្មែរ គឺមានវៀតណាម។ វៀតណាមដែលចូលមកឆ្នាំ៧០ ហ្នឹងដែរ។

**ស៖** បាទ សូមអរគុណ។ ប៉ុន្តែខ្ញុំចង់ឲ្យលោកឆ្លើយបញ្ជាក់ទាក់ទងទៅនឹងក្រុមយោធារបស់លោក និងសម្ដេច នរោត្តម សីហនុ ថាតើមានទំនាក់ទំនងគ្នាយ៉ាងដូចម្ដេចដែរ ក្នុងពេលសង្គ្រាមនោះ ឬមុនក្នុងចន្លោះឆ្នាំ១៩៧០ ក្រោយរដ្ឋប្រហាររហូតមកដល់ឆ្នាំ១៩៧៥ មុនរំដោះ៧៥?

**ឆ៖** បាទ ក្នុងនុំងខ្ញុំដឹងថា ពេលដែលឆ្នាំ៧០រដ្ឋប្រហារហើយ ខ្ញុំមាន -- គ្មានការទំនាក់ទំនងអីជាមួយសម្ដេចទេ ព្រោះព្រះអង្គគាត់ លោកនៅឆ្ងាយ ប៉ុន្តែព្រះអង្គបានអំពាវនាវពីស្រុកបារាំងមកឲ្យកូនចៅឲ្យការខំតស៊ូដើម្បីរំដោះជាតិ ព្រោះ លន់ នល់ រដ្ឋប្រហារឌឹហើយ ដូច្នេះខ្ញុំក៏មានទឹកចិត្តក្នុងការតស៊ូហ្នឹងដើម្បីទាមទារយកស្ដេច ឲ្យស្ដេចមកកាន់អំណាចវិញបាទ។

**ស៖** បាទ សូមអរគុណលោក មាស វឿន។ សូមអរគុណប្រធាន -- លោកប្រធាន។ ខ្ញុំបាទអស់សំណួរហើយ។ សូមសហភាគាបន្ត បាទ សូមអរគុណ។

[១១:៤០:២៥]

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ជម្រាបសួរលោក មាស វឿន ខ្ញុំឈ្មោះ អង់តា ហ្គីសសេ ខ្ញុំជាសហភាគាអន្តរជាតិរបស់លោក -- មេធាវីលោក ខៀវ សំផន ហើយខ្ញុំមានសំណួរមួយចំនួនចោទសួរទៅកាន់លោក។ ខ្ញុំសូមរំឭកដូចលោកស្រាប់ហើយ គឺថាលោកមានវត្តមាននៅទីនេះ ហើយយើងមានអ្នកបកប្រែនៅទីនេះ។ ដូច្នេះខ្ញុំសូមឲ្យលោកធ្វើតាមដែលអាចទៅបាន គឺថានិយាយឲ្យយឺតបំផុត ហើយខ្ញុំក៏ធ្វើព្យាយាមនិយាយយឺត

ដើម្បីឆ្លើយនិងសួរគ្នា ស្តាប់គ្នាបាន។ គេសួរលោកច្រើនមកហើយ ហើយខ្ញុំគិតថា លោកអស់កម្លាំងហើយ ដូច្នេះ ខ្ញុំសូមឲ្យលោកមានភាពអត់ធ្មត់ ហើយខ្ញុំជាមេធាវីចុងក្រោយគេហើយ ដែលសួរសំណួរទៅកាន់លោកនេះ។ ហើយខ្ញុំនឹងត្រឡប់មកនិយាយអំពីចំណុចមួយចំនួន ដែលលោកបានលើកឡើងជាមួយនឹងភាគីផ្សេងៗទៀត ដែលបានសួរទៅលោក ដើម្បីទទួលបាននូវការបំភ្លឺមួយចំនួន។

ដើម្បីត្រឡប់ទៅនិយាយអំពីអ្វី ដែលលោកបាននិយាយទៅកាន់សហភាតារបស់ខ្ញុំអម្បាញ់មិញនេះ លោកបានលើកឡើងជាមួយគាត់ពីការអំពាវនាវរបស់ព្រះអង្គម្ចាស់សីហនុពីបរទេស អំពាវនាវទៅកាន់ប្រជាជន ដើម្បីតស៊ូប្រឆាំងទៅនឹងទាហាន លន់ នល់។ សំណួររបស់ខ្ញុំទី១ គឺទាក់ទងទៅនឹងរយៈពេលក្រោយរដ្ឋប្រហារ គឺថាក្រោយឆ្នាំ១៩៧០ ហើយខ្ញុំចង់ដឹងថា នូវអ្វីដែលលោកបានសង្កេតឃើញទាក់ទងទៅនឹងការប្រឡូកចូលរបស់ប្រជាជនទៅក្នុងព្រៃម៉ាគី តើមាន -- តើលោកមានឃើញថា មានមនុស្សច្រើនដែរឬទេ ដែលចូលទៅព្រៃម៉ាគីនោះ នៅសម័យនោះ?

**លោក មាស វឿន៖**

**ឆ៖** បាទ កាលព្រះអង្គបានអំពាវនាវពីស្រុកបារាំង គឺប្រជាជននៅតាមខេត្ត ជាពិសេសខេត្តដែលខ្ញុំដឹងគឺ ខេត្តកំពង់ស្ពឺ ហើយនិងខេត្តបាត់ដំបងនោះ គឺព្រះអង្គបានអំពាវនាវឲ្យចូលព្រៃតស៊ូ រំដោះដើម្បីឱមកនៅក្នុងស្រុកខ្មែរវិញបាន។ ក្នុងនុំងប្រជាជនចេញច្រើន ពិសេសគឺ ខ្ញុំនៅតាមស្រុកខ្ញុំ ខេត្តកំពង់ស្ពឺនេះ ប្រជាជនចេញច្រើន ធ្វើកងទ័ពច្រើន ហ្នឹងមួយ។ ហើយនៅខេត្តបាត់ដំបង តាម -- យើងទាក់ទងតាមផ្លូវព្រៃ ទាក់ទងគ្នាតាមផ្លូវព្រៃទៅ គឺខេត្តបាត់ដំបងដែលចេញច្រើនប្រហែលជា -- ហើយក្នុងនោះប្រហែលជា៣០.០០០នាក់ ដែលពេលចេញទៅភ្នំវាយចាប។ ខាងខ្ញុំចេញទៅធ្វើកងទ័ព។ នេះហើយដែល ការដែលព្រះទ័យអំពាវនាវរបស់សម្តេច សីហនុ។ នេះដែលខ្ញុំបានដឹងប៉ុណ្ណឹង។

[១១:៤៤:០៤]

**ស៖** សូមអរគុណលោកសាក្សី។ តើលោកមានចាំពាក្យដែលគេប្រើ ដែលសម្តេច សីហនុ ប្រើនៅពេលដែលគាត់ធ្វើអំពាវនាវនោះដែរឬទេ?

**ឆ៖** បាទ សម្តេចមិនមានព្រះឱង្ការប្រើអីយ៉ាងម៉េច។ ព្រះអង្គបានតែអំពាវនាវកូនចៅសម្រាប់ធ្វើការតស៊ូ ពាក្យប៉ុណ្ណឹង ហើយខ្ញុំចាំបានប៉ុណ្ណឹង។

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតអានទៅកាន់សាក្សីនូវផ្នែកមួយនៃឯកសារ D359/1/1.1 ដែល

ចេញមកពីបណ្ណសារអាល្លឺម៉ង់ដែលហៅ ព្រះរាជសារ និងសេចក្តីប្រកាស សេចក្តីថ្លែងការណ៍ឱឡារិករបស់សម្តេច នរោត្តម ប្រមុខរដ្ឋកម្ពុជាចុះថ្ងៃទី២៣ មីនា ឆ្នាំ១៩៧០។ បើសិនជាលោកប្រធានអនុញ្ញាតខ្ញុំសូមអានផ្នែកមួយ ហើយនឹងខ្ញុំផ្តល់ ERN លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

ចុះៗលេខ ERN? សូមលោកមេធាវី លោកស្រីមេធាវីផ្តល់នូវលេខ ERN ទាំងបីភាសា។

**កញ្ញា អង់តា ហ្គីសសេ៖**

ERN ជាភាសាបារាំងគឺ 00535853 នៅកថាខណ្ឌទី៥ នៃទំព័រនោះ។ ERN ជាភាសាខ្មែរគឺ00851605 ហើយបន្តទៅដល់លេខ06 លេខចុងក្រោយ, ERN ជាភាសាអង់គ្លេសគឺ 00852374។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។

[១១:៤៧:០០]

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** លោកសាក្សី ខ្ញុំសូមអានសម្រង់ទីមួយនៃឯកសារនេះ ដែលជាសេចក្តីថ្លែងការណ៍របស់សម្តេច សីហនុ នៅថ្ងៃទី០៣ អ៎! ២៣មីនា ឆ្នាំ១៩៧០ ហើយសម្រង់ដូចតទៅនេះ៖ “ ខ្មែរ-- ប្រជាជនខ្មែររាប់ម៉ឺននាក់នៅក្នុងប្រទេសកម្ពុជា ហើយនិងរាប់លាននាក់នៅក្រៅប្រទេស គាត់នឹងលើកទង់បះបោរប្រឆាំងនឹង បនប្រតិកិរិយា លន់ នល់, សិរិមតៈ, ចេង ហេង ប្រឆាំងនឹងពួកចក្រពត្តិអាមេរិកជាមួយចៅហ្វាយរបស់ពួកគេ នាពេលខាងមុខនេះ។ ខ្មែរស្នេហាជាតិទាំងអស់នឹងកម្ទេចបនក្បត់ ផ្សំគំនិតចៅហ្វាយអាមេរិកាំងឲ្យអស់ពីទឹកដីយើង។ ក្រោយពីជ័យជម្នះ អ្នកស្នេហាជាតិយើងនឹងកសាងកម្ពុជាថ្មីដែលអំណាចនឹងស្ថិតនៅ ជានិច្ចក្នុងកណ្តាប់ដៃប្រជាជន សង្ខាតធ្វើការ ចម្រើននិយម ឧស្សាហ៍ព្យាយាម និងស្អាតស្អំ ធានានូវអនាគតភ្លឺចិញ្ចែងចិញ្ចាចដល់មាតុភូមិយើងប្រកបដោយយុត្តិធម៌សង្គមសមភាព ភាតរភាពសង្គម រវាងខ្មែរនិងខ្មែរ” សូមបញ្ចប់ការដកស្រង់។ លោកសាក្សី សំណួរខ្ញុំទី១គឺថាតើសម្រង់នេះ ធ្វើឲ្យលោកនឹកឃើញដល់ការអំពាវនាវ ឬសេចក្តី ថ្លែងការណ៍របស់សម្តេច សីហនុនៅពេលនោះដែរឬទេ?

**លោក មាស វឿន៖**

**ឆ៖** បាទ ខ្ញុំដែលស្ដាប់បានខ្លះ ហើយភ្លេចខ្លះ។

[១១:៤៨:៥៧]

**ស៖** ខ្ញុំយល់លោកសាក្សី ព្រោះថាពេលវេលាវាកន្លងផុតទៅជាច្រើនឆ្នាំមកហើយ។ មានសំណួរមួយទៀតទាក់ទងនឹងចំណុចនេះដែរ គឺថាទាក់ទងទៅនឹងខ្លឹមសារផ្នែកដែលខ្ញុំទើបតែអាន អម្បាញ់មិញនេះ តើលោកមានចាំទេ នៅសម័យនោះ នៅក្នុងចលនាបដិវត្តន៍នោះ អ្វី-- ការនិយាយទាក់ទងទៅនឹងអ្នកធ្វើរដ្ឋប្រហារ ដូច លន់ នល់, សិរិមតៈ, ចេង ហេង នោះ តើការនិយាយនៅក្នុងពាក្យស្លោកនោះវាដូចគ្នានឹងអ្វីដែលសម្ដេច សីហនុ ប្រកាសថ្លែងការណ៍ដែរឬទេ? តើវាដូចគ្នាដែរឬទេ ការឃោសនាហ្នឹង និងអ្វីដែលមាននៅក្នុងពាក្យស្លោកហ្នឹងដូចគ្នាដែរឬទេ?

**ឆ៖** បាទ ដូចខ្លះដែរ។

**កញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំសូមអានសម្រង់មួយទៀតនៃសេចក្ដីថ្លែងការណ៍នេះដដែល គឺឯកសារ D359/1.1.1.1 ERN ជាភាសាបារាំងគឺ 00535855, ERN ជាភាសាខ្មែរគឺ 00851607, ERN ជាភាសាអង់គ្លេស គឺ 00852375។ លោកប្រធាន ខ្ញុំសូមអនុញ្ញាតអានសម្រង់ទី២ លោកប្រធាន។

[១១:៥០:៥១]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។ សូមអញ្ជើញ!

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** សូមអរគុណលោកប្រធាន។ ខ្ញុំសូមអានសម្រង់ទី២នេះ។ លោកសាក្សី "នៅក្នុងក្របខ័ណ្ឌនៃការតស៊ូនេះ ខ្ញុំសូមអំពាវនាវដល់បងប្អូនជនរួមជាតិ ទាំងយោធា និងស៊ីវិល ដែលមិនអាចទ្រាំទ្រនឹងការជិះជាន់យ៉ាងអយុត្តិធម៌របស់ពួកក្បត់ ហើយមានសេចក្ដីក្លាហាន និងសេក្ដីស្នេហាមាតុភូមិ ចង់រំដោះជាតិឲ្យចូលព្រៃតស៊ូប្រឆាំងខ្មាំងសត្រូវរបស់យើង។ ប្រសិនបើបងប្អូនមានអាវុធ និងមានចំណេះដឹងខាងយោធា ខ្ញុំនឹងបញ្ជូនគ្រាប់រំសេវ និងអាវុធថ្មីៗក្នុងរយៈពេលសមស្រប។ ប្រសិនបើជាបងប្អូនគ្មានអាវុធ ប៉ុន្តែចង់រៀនសូត្រខាងយោធា ខ្ញុំនឹងចាត់វិធានការចាំបាច់ បញ្ជូនបងប្អូនទៅសាលាយោធារបស់រណសិរ្សរួបរួមជាតិកម្ពុជា ដែលមានទីតាំងនៅឆ្ងាយពីបន្ទាយ និងភូមិរបស់បងប្អូន ដើម្បីកុំឲ្យខ្មាំងទៅ

ដល់ ឬក៏រកសាលានោះឃើញ" សូមបញ្ចប់ការដកស្រង់។

សំណួរខ្ញុំ សំណួរទី១ របស់ខ្ញុំលោកសាក្សី គឺថា ចង់ដឹងថាតើលោកមានចាំផ្នែកនៃសេចក្តីថ្លែងការណ៍នេះរបស់សម្តេច សីហនុ ដែរឬទេ?

**លោក មាស វឿន៖**

**ឆ៖** បាទ ចំណុចនេះ ខ្ញុំមិនបានចាំទេ ព្រោះអី ខ្ញុំមិនបានវិទ្យុស្តាប់។

**ស៖** សូមអរគុណ។ អម្បាញ់មិញនេះ លោកបាននិយាយថា លោកបានឮការអំពាវនាវរបស់សម្តេច សីហនុ ពីបរទេស។ តើលោកអាចបញ្ជាក់ចម្លើយនេះរបស់លោកបានដែរឬទេ?

[១១:៥៣:២០]

**ឆ៖** បាទ ពេលណា ខ្ញុំបានវិទ្យុស្តាប់ ខ្ញុំស្តាប់បាន ប៉ុន្តែដល់ពេលមិនមានការស្តាប់វិទ្យុ ខ្ញុំមិនបានចាំ។

**ស៖** មិនថ្វីទេលោកសាក្សី។ សំណួរទាក់ទងនឹងអ្វីដែលខ្ញុំទើបតែអាននេះ គឺថា ចង់ដឹងថា នៅពេលដែលលោកចូលក្នុងកងទ័ពនៅឆ្នាំ១៩៧០ ពីព្រោះថា នេះជាកាលបរិច្ឆេទដែលលោកបានប្រាប់ថាលោកក្លាយជាយោធានៅពេលហ្នឹង។ តើលោកធ្លាប់បានជួបយោធា ដែលចូលធ្វើបដិវត្តន៍នៅក្នុងពេលនោះដើម្បីគាំទ្រដល់សម្តេច សីហនុ តើលោកធ្លាប់ជួបអ្នកដែលថា ចូលរួមធ្វើយោធានេះ បន្ទាប់ពីមានការអំពាវនាវរបស់សម្តេច សីហនុ ដែរឬទេ?

**ឆ៖** បាទ ដែលថា ខ្ញុំមានចូលហ្នឹងឯង ខាងប្រជាជន យុវជនហ្នឹងចូលធ្វើទាហានច្រើនបាទ។

**ស៖** ទាក់ទងប្រធានបទនេះ ខ្ញុំមានចំណុចមួយទៀតត្រូវលើកឡើង។ ដោយសារនៅក្នុងការអំពាវនាវនេះគឺថា អំពាវនាវទៅកាន់អ្នកធ្លាប់ធ្វើទាហានហើយ តើលោកមានបានជួបអ្នក អតីតយោធាលន់ នល់ ដែលមកចូលមកក្នុងកងទ័ពបដិវត្តន៍ទេ បន្ទាប់ពីសម្តេច សីហនុ បានធ្វើការអំពាវនាវនេះ?

**ឆ៖** បាទ ក្នុងសេចក្តីអំពាវនាវរបស់សម្តេចហ្នឹង ខ្ញុំបានឃើញកងទ័ពមួយអង្គភាព ប៉ុន្តែមិនដឹងអង្គភាពប៉ុន្មានទេ គាត់ដឹកនាំស័ក្តិ៤ ប្រហែលជាជិត ប្រហែលជា១០០នាក់ ក៏មកចូលរួមក្នុងឆ្នាំ១៩៧០, ៧១ អីហ្នឹង ប្រហែលខ្ទង់៧១ តែខ្ញុំមិនបានចាំច្បាស់។ បាទ ប៉ុណ្ណឹង។

[១១:៥៦:១២]

**ស៖** សូមអរគុណលោកសាក្សីដែលបានបំភ្លឺត្រង់ចំណុចនេះ។ ឥឡូវនេះ ខ្ញុំសូមចូលទៅប្រធានបទផ្សេងទៀត។ ដូច្នេះ យើងឈប់និយាយអំពីរយៈកាលឆ្នាំ៧០ ឆ្នាំ៧៥ ហើយ ហើយយើងនឹងទៅ

និយាយអំពីរយៈកាលពី ចាប់ពីឆ្នាំ១៩៧៨ គឺថា ពេលដែលលោកបានប្រាប់ថា លោកបានចាកចេញពីទីក្រុង -- ពីខេត្តកោះកុង ទៅខេត្តព្រះវិហារ។ ខ្ញុំសូមត្រឡប់មកនិយាយអំពីព្រឹត្តិការណ៍នៅរយៈពេលនេះគឺថា នៅថ្ងៃទី០៤ ខែតុលា គឺថាម៉ោងពីរជាង លោកបាននិយាយថា បានចាកចេញពីកោះកុង ទៅស្រែអំបិល ហើយពីស្រែអំបិលនេះ គឺថាលោកជិះឡានទ្រុងមកភ្នំពេញ ហើយបន្ទាប់មកទៀត លោក -- បន្ទាប់ពីចេញពីកោះកុងតាមកាណូតមកនុ៎ង លោកបានទៅសៀមរាប សំដៅទៅសៀមរាប។ នេះគឺជាខ្សែដំណើររបស់លោក។ សំណួរខ្ញុំនោះចង់ដឹងថា តើនៅពេលដែលលោកចេញពីកោះកុង តើមុននឹងជិះកាណូតទៀតនោះ តើលោកដឹងថាគេនឹងចាត់តាំងឲ្យលោកធ្វើអីទេ ពេលបន្ទាប់មកទៀតនោះ?

**ឆ៖** បាទ មុនៗនឹងខ្ញុំចេញដំណើរពីកោះកុងមក ជួបនឹងកងពលខ្ញុំហ្នឹង អត់ទាន់មានដំណឹងអ្វីទេ គាត់ផ្ដាំថា ឲ្យខ្ញុំមកជួបខ្ញុំនៅវាលរេញ ហើយចាំខ្ញុំ ធ្វើដំណើរជាមួយខ្ញុំទៅភ្នំពេញបាទ។

[១១:៥៨:៤៨]

**សៈ** តើអ្នកណាជាបញ្ជាឲ្យលោកចាកចេញពីកោះកុង?

**ឆ៖** បាទ ប្រធានកងពលខ្ញុំ តាសឿង។

**សៈ** ហើយលោកទទួលបញ្ជាពី សឿង នេះ តាមមធ្យោបាយណាដែរ?

**ឆ៖** សារទូរលេខដែលគេវៃ។

**សៈ** ហើយនៅក្នុងទូរលេខដែលលោកបានទទួលនោះ គេឲ្យលោកទៅណា ដោយពិតប្រាកដនោះគេបញ្ជាឲ្យលោកទៅណា?

**ឆ៖** បាទ ក្នុងសារទូរលេខហ្នឹងគ្រាន់តែប្រាប់ថា ឲ្យខ្ញុំមកប៉ុណ្ណឹងសិន មកជួបគាត់សិន។

**សៈ** ហើយការណាត់ជួបនុ៎ង ត្រូវណាត់ជួបនៅឯណាដែរ?

**ឆ៖** បាទ ការណាត់ជួបនៅវាលរេញ ព្រៃនប់ វាលរេញ។

**សៈ** សូមអរគុណលោកសាក្សី។

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំចង់ចូលប្រធានបទថ្មីមួយទៀត តើពេលនេះគឺថា ត្រូវសម្រាកសិន ឬយ៉ាងម៉េចលោកប្រធាន?

[១២:០០:៤០]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណច្រើន ហើយតើលោកស្រីចៅក្រម ត្រូវការពេលវេលាប្រហែលប៉ុន្មានទៀត ក្នុងការតាំងសំណួរចំពោះសាក្សីរូបនេះ?

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំឥឡូវនេះ គឺថា ខ្ញុំសួរបានប្រហែលជា៣០ភាគរយហើយៗ អ៊ីចឹង ខ្ញុំត្រូវការរយៈពេលប្រហែលជាខ្ទង់១ម៉ោង ១ម៉ោងកន្លះ ទៀតលោកប្រធាន។ អ៊ីចឹង ខ្ញុំគិតថា ថ្ងៃនេះខ្ញុំនឹងអាចបញ្ចប់ការចោទសំណួរបានហើយលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទៗអរគុណ។

[១២:០១:២០]

*(ចៅក្រមពិភាក្សាគ្នា)*

[១២:០៤:៥៥]

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះ ដល់ពេលត្រូវត្រូវសម្រាកដើម្បីពិសាថ្ងៃត្រង់ហើយ ប៉ុន្តែមុននឹងសម្រាកហ្នឹងសូមជម្រាបជូនដល់ភាគី និងសាធារណជនថា នៅរសៀលនេះអង្គជំនុំជម្រះនឹងបន្តស្តាប់សក្ខីកម្ម សាក្សី មាស វឿន ដែលនឹងសួរដេញដោលមេធាវីអន្តរជាតិការពារក្តីលោក ខៀវ សំផន ជាបន្ត។ ហើយបើសិនជានៅមានពេលសេសសល់នោះ គឺអង្គជំនុំជម្រះនឹងដំណើរការចាត់ឲ្យក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូង អាននូវបណ្តាកថាខណ្ឌពាក់ព័ន្ធជាមួយនឹងអង្គហេតុ ទីកន្លែងសម្លាប់ទួលពោធិ៍ជ្រៃ ដើម្បីបញ្ចប់នូវបណ្តាអង្គហេតុទាំងឡាយ ដែលអង្គជំនុំជម្រះកំណត់យកមកធ្វើសវនាការនៅក្នុងសំណុំរឿង០០២/០១ ហើយនឹងបានពង្រីកវិសាលភាពបន្ថែមតាមសំណើសុំរបស់តំណាងសហព្រះរាជអាជ្ញា។

សូមអញ្ជើញលោកមេធាវី!

[១២:០៦:០១]

**លោក អេនឌ្រូ អ៊ីនូហ្ស៊ី៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមានចំណុច៤ តូចៗ ដែលខ្ញុំចង់លើកយកមកនិយាយ។ ខ្ញុំគិតថា ខ្ញុំប្រុងនឹងធ្វើនៅរសៀលនេះ ខ្ញុំស្នើសុំប្រហែលជា៤-៥នាទី ខ្ញុំនឹងប្រឹក្សាជាមួយកូនក្តីរបស់ខ្ញុំ ក្រោយ

ពេលសម្រាកអាហារថ្ងៃត្រង់រួច។ ហើយខ្ញុំនឹងពិភាក្សាជាមួយគាត់នៅពេលឈប់សម្រាកថ្ងៃត្រង់ ព្រោះគាត់មិនចង់លះបង់សិទ្ធិ មិនចូលរួមនៅពេលដែលមានការអាននៅផ្នែកនៃដីកាដំណោះស្រាយ។ ហើយនេះគឺជាសំណើសុំទី១ ដែលខ្ញុំចង់បញ្ជាក់ គឺខ្ញុំចង់ជម្រាបថា លោក នួន ជា មានការឈឺក្បាល ឈឺខ្នង ឈឺចង្កេះ មិនអាចផ្ចង់អារម្មណ៍ ហើយដោយសារហេតុផលនេះគាត់ចង់ស្នើសុំសម្រាកនៅរសៀលនេះនៅក្នុងបន្ទប់ឃុំឃាំងខាងក្រោម។ ប៉ុន្តែយើងដោយសារតែមានការនិយាយអំពីការអានផ្នែក នៃដីកានោះទើបយើងនឹងពិភាក្សាជាមួយគាត់នៅពេលឈប់សម្រាក អាហារថ្ងៃត្រង់នេះ។

ហើយចំណុចបន្ទាប់ទៀត ដែលខ្ញុំចង់និយាយគឺ ទី១ ខ្ញុំចង់ឲ្យបញ្ជាក់ ខ្ញុំបាននិយាយនៅព្រឹកនេះ គឺខ្ញុំបាននិយាយត្រឹមត្រូវទៅលើឯកសារអ្វីដែលខ្ញុំបានយោង គឺនៅក្នុងឆ្នាំ១៩៤៩ នៅប៉ាស៊ីហ្វិក ខាងត្បូង ហើយ--

**ប្រធានអង្គជំនុំ៖**

បញ្ហាហ្នឹងដូចចប់ហើយ អង្គជំនុំជម្រះដូចជាបានសម្រេចបញ្ចប់នូវការលើកឡើងរបស់លោករួចហើយកាលពីព្រឹកមិញ។ ឥឡូវនេះ ដល់ពេលម៉ោងសម្រាកពិសាថ្ងៃត្រង់ តើលោកមានបញ្ហាអីទេ?

ពេលនេះ យើងមិនអនុញ្ញាតឲ្យលោកនិយាយអ្វីផ្សេងទៀតទេ លើកលែងតែលោកស្នើពាក់ព័ន្ធជាមួយនឹងលោក នួន ជា ឈឺក្បាលវិលមុខ មិនអាចអង្គុយបាន។ យើងនឹងស្តាប់ពិចារណាលើបញ្ហានេះតែមួយមុខគត់ប៉ុណ្ណោះ។

[១២:០៨:០១]

**លោក អេនគ្រូ អ៊ីនូហ្ស៊ី៖**

សូមអរគុណលោកប្រធាន។ បញ្ហានេះ គឺវាពាក់ព័ន្ធនឹងកូនក្តីរបស់ខ្ញុំ គឺយើងកំពុងតែមានសំណើដែលត្រូវប្រុងធ្វើគឺថា លោក នួន ជា ស្នើសុំឲ្យមានការបញ្ចេញមតិយោបល់បន្តិចបន្តួច ហើយខ្ញុំគិតថាខ្ញុំបានបញ្ជាក់កាលពីសប្តាហ៍មុន ហើយលោកប្រធានបានបញ្ជាក់ថា នឹងផ្តល់ពេលវេលាណាមួយនៅពេលព្រឹកណាមួយ--

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះបានសម្រេចរួចហើយ ហើយទំនងជានៅព្រឹកស្អែក អង្គជំនុំជម្រះនឹងផ្តល់វេទិកាជូនទៅលោក នួន ជា ដើម្បីធ្វើសេចក្តីថ្លែងតបទៅនឹងបណ្តាកថាខណ្ឌទាំងឡាយ ដែលក្រឡាបញ្ជីបានអាននូវវេលាចុងក្រោយនេះ។ នេះជាសិទ្ធិរបស់គាត់ ដែលមានចែងនៅក្នុងវិធានផ្ទៃក្នុង។ ដោយហេតុនេះ

ហើយបានជាអង្គជំនុំជម្រះមានបំណងអានជម្រាបលោកថា អានន្ទូវបណ្តាកថាខណ្ឌដែលចោទប្រកាន់អង្គហេតុចោទប្រកាន់លើបន្ទុកលើជនជាប់ចោទបន្ថែមទៀត ដើម្បីឲ្យការដែលគាត់បានដឹង ហើយគាត់បានត្រៀមខ្លួន ដើម្បីធ្វើសេចក្តីថ្លែងការណ៍តប លើអង្គហេតុទាំងអស់ ដែលអង្គជំនុំជម្រះអាន ក្នុងន័យគឺបណ្តាអង្គហេតុដែលអង្គជំនុំជម្រះ កំណត់យកធ្វើសវនាការក្នុងសំណុំរឿង០០២/០១ តែម្តង។

[១២:០៩:២៧]

**លោក អេនគ្រូ អ៊ីនូហ្ស៊ី៖**

សូមអរគុណលោកប្រធាន។ ដោយសារចំណុចនេះហើយគឺថា ខ្ញុំនឹងទំនាក់ទំនងជាមួយនឹងខាងអង្គជំនុំជម្រះសាលាដំបូង ប្រហែលជាទាក់ទងជាមួយនឹងមន្ត្រីជាន់ខ្ពស់ ហើយខ្ញុំនឹងពិភាក្សាជាមួយកូនក្តីរបស់ខ្ញុំថាតើលោក នួន ជា នឹងលះបង់សិទ្ធិ ឬក៏មិនលះបង់សិទ្ធិនៅរសៀលនេះ? តើអាចទទួលយកបានទេចំពោះសំណើរបស់ខ្ញុំ? ឬមួយក៏ខ្ញុំអាចប្រឹក្សាជាមួយគាត់ក្នុងពេលឥឡូវនេះ គឺសូម ខ្ញុំសូមពេលតែ ១នាទី ប៉ុណ្ណោះ។

[១២:១០:00]

**ប្រធានអង្គជំនុំ៖**

អញ្ជើញ!

**លោក អេនគ្រូ អ៊ីនូហ្ស៊ី៖**

សូមអរគុណ។ លោក នួន ជា បានស្នើសុំលះបង់សិទ្ធិមិនចូលរួមនៅរសៀលនេះ។ ដូច្នេះអ្វីដែលយើងចង់ គឺថានៅល្ងាចនេះយើងនឹងបញ្ចប់នូវការសាកសួរសាក្សី ហើយនិងអាននូវផ្នែកនៃដីកាដំណោះស្រាយនោះ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អង្គជំនុំជម្រះបានស្តាប់សំណើសុំរបស់ជនជាប់ចោទ នួន ជា ដែលបានធ្វើឡើងតាមរយៈមេធាវីការពារក្តីរបស់គាត់ សុំទៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយតាមរយៈប្រព័ន្ធសោតទស្សន៍ សម្រាប់រយៈពេលធ្វើសវនាការពេញមួយរសៀលថ្ងៃនេះ។ ដោយមានបញ្ហាសុខភាព មិនអាចអង្គុយតាមដានស្តាប់នៅក្នុងកិច្ចដំណើរការសវនាការនេះដោយផ្ទាល់បាន ហើយលះបង់សិទ្ធិមានវត្តមាននៅក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់។ អង្គជំនុំជម្រះយល់ព្រម និងអនុញ្ញាតឲ្យលោក នួន ជា ទៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំមួយ ស្ថិតនៅក្រោមសាលសវនាការនេះ

តាមរយៈឧបករណ៍សោតទស្សន៍ សម្រាប់រយៈពេលធ្វើសវនាការពេញមួយរសៀលថ្ងៃនេះ។

[១២:១២:០១]

អង្គជំនុំជម្រះតម្រូវឲ្យក្រុមមេធាវីការពារក្តី នួន ជា ប្រគល់មកឲ្យអង្គជំនុំជម្រះភ្លាមនូវពាក្យសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ ដោយមានចុះហត្ថលេខា ឬផ្តិតស្នាមម្រាមដៃជាក់ច្បាស់របស់លោក នួន ជា។

បង្គាប់ឲ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍ សម្រាប់ជនជាប់ចោទរូបនេះអាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនស្ថិតនៅក្រោមសាលសវនាការនេះ សម្រាប់រយៈពេលនៃកិច្ចដំណើរការសវនាការពេញមួយរសៀលថ្ងៃនេះ។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក នួន ជា និងលោក ខៀវ សំផន ទៅកាន់បន្ទប់ឃុំខ្លួនខាងក្រោម ដោយនៅរសៀលនេះឲ្យទុកលោក នួន ជា នៅក្នុងបន្ទប់ដែលរៀបចំជាស្រេចនូវឧបករណ៍សោតទស្សន៍ សម្រាប់គាត់អាចចូលរួម និងតាមដានកិច្ចដំណើរសវនាការពីចម្ងាយ។ ដោយឡែកលោក ខៀវ សំផន ឲ្យនាំខ្លួនគាត់មកកាន់បន្ទប់សវនាការនេះវិញ នៅរសៀលនេះឲ្យបានមុនម៉ោងមួយសាមសិបនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១២:១២ នាទី ដល់ម៉ោង ១៣:៣៣ នាទី)*

[១៣:៣៣:៤៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។ សូមអញ្ជើញ!

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** លោក មាស វឿន មុននឹងឈប់សម្រាកអាហារថ្ងៃត្រង់នេះ យើងមកដល់ចំណុចមួយដែលយើង -- នៅពេលដែល តាសឿង សុំឲ្យលោកទៅជួបគាត់ដើម្បីទៅភ្នំពេញជាមួយគ្នា។ ឥឡូវនេះខ្ញុំសូមនិយាយបន្តិចអំពីកិច្ចប្រជុំដែលលោកបានលើកឡើងនៅថ្ងៃទី០៤ តុលា នៅចន្លោះម៉ោង១៤:០៤នាទី ទៅម៉ោង ១៤:០៦នាទី ជាមួយកិច្ចប្រជុំជាមួយ ប៉ុល ពត នោះ។ បើសិនជាខ្ញុំមិនច្រឡំទេ គឺថានៅទីក្រុងភ្នំពេញ។ ហើយកាន់តែច្បាស់ជាងហ្នឹងទៅទៀតនោះ គឺថានៅវត្តឧណ្ណាលោម។ លោកបានចូលរួមប្រជុំ ហើយខ្ញុំសូមដកស្រង់សវនាការថ្ងៃទី០៤ តុលា នេះ។ លោកនិយាយដូចតទៅនេះ "ពេលខ្ញុំចេញពីកោះកុងមកភ្នំពេញ តាសឿង នៅទីហ្នឹងគាត់ជាលេខាកងពល ហើយបន្ទាប់មកទៀត យើងបានជួប ប៉ុល ពត នៅវត្តឧណ្ណាលោម"។ គេចោទសំណួរលោកដូចតទៅមុខនេះ "តើមានតែលោកហើយនិង តាសឿង ទេ ឬក៏មានអ្នកផ្សេងទៀតនៅពេលដែលលោកជួប ប៉ុល ពត នោះ?"។ ហើយលោកឆ្លើយដូចទៅនេះ "ខ្ញុំជួបមេកងពលផ្សេងទៀត ក៏ប៉ុន្តែខ្ញុំមិនដឹងថាអ្នកណា ជាអ្នកណានោះទេ។ ទាំងអស់គ្នានោះមានប្រហែលជា១២នាក់"។ សំណួរខ្ញុំដូចតទៅនេះ តើមេបញ្ជាការកងពលផ្សេងទៀតនោះដែលមកប្រជុំដែរនោះ ដោយសារគាត់ទាំងអស់គ្នាហ្នឹងទទួលការចាត់តាំងថ្មី ឬក៏មានមូលហេតុអីផ្សេងពីនេះទៀត?

[១៣:៣៦:៣៩]

**លោក មាស វឿន៖**

**ឆ៖** បាទ ខ្ញុំមកពីវាលរេញ មកភ្នំពេញ ហើយឲ្យពីរនាក់ បងសឿង ចូលកន្លែងលោក ប៉ុល ពត នៅវត្តឧណ្ណាលោម។ ក្នុងហ្នឹង គឺមានតែលោក ប៉ុល ពត ម្នាក់ឯងទេ។ ចូល ៗពេលចូលពេលនោះ ខ្ញុំឃើញ គ្រាន់ជាប្រហែលទេ ប៉ុន្តែខ្ញុំមិនស្គាល់គ្នានោះច្បាស់លាស់នោះទេ។ ប៉ុន្តែប្រហែលជាតំណាងកងពលផ្សេងៗនៅតាមព្រំដែនខាងកើតដែលមកជួបជុំនៅកន្លែងវត្តឧណ្ណាលោមនោះដែរ។ ពេលដែលជួបជុំនោះ ប៉ុល ពត មានផែនទីមួយផ្ទាំងដាក់ជាប់នឹងជញ្ជាំង ហើយរំពាត់គាត់មួយ គាត់ចង្អុលផែនទីប្រាប់ខ្ញុំ ហើយនិងអ្នកដែលនៅក្នុងចំណោមនោះ។

[១៣:៣៧:៥៣]

ដំបូង គាត់និយាយពីរឿងសភាពការណ៍ថា ខ្មាំងនៅតាមព្រំដែនខាងកើតដែលមានការវ៉ៃគ្នា ខ្លាំងមធ្យម។ កន្លែងខ្លះវ៉ៃខ្លាំង កន្លែងខ្លះវ៉ៃមធ្យម កន្លែងខ្លះគ្រាន់តែផ្ទុះរប៉េះរប៉ោះតាមព្រំដែនខាងកើត។ ក្នុងការគាត់ចង្អុលផែនទីប្រាប់ពីកន្លែងត្រង់នេះ ទៅកន្លែងត្រង់នោះក្នុងផែនទីហ្នឹង ប្រហែលជា១ ពីរម៉ោងប៉ុណ្ណឹងទេ អំពីសភាពការណ៍ខ្មាំងនោះ។ ហើយក៏កិច្ចការងារហ្នឹងក៏បញ្ចប់យ៉ាងឆាប់ដែរ។ ហើយបានចុងក្រោយបំផុត គាត់ប្រាប់ខ្ញុំថា "មិត្តទៅព្រះវិហារទៅ! ទៅមើលកន្លែងព្រះវិហារ តើគេចាប់ ឮថាគេចាប់ប្រជាជន ឬក៏ប្រជាជនអត់បាយអីហ្នឹង។ គ្រាន់តែទៅមើលគាត់ ហើយនិងក្តាប់ស្ថានការណ៍ភាពកន្លែងនោះយ៉ាងម៉េច អីយ៉ាងម៉េច? គាត់មិនប្រាប់ថា ឲ្យរាយការណ៍ទេ។ គ្រាន់តែប្រាប់អ៊ីចឹងហើយ។ គ្រាន់តែប្រាប់ថា ទៅមើល ដឹកនាំ ក្តាប់សភាពការណ៍កន្លែងនោះ"។ ខ្ញុំយល់បានប៉ុណ្ណឹងសិនបាទ។

[១៣:៣៩:៣០]

**ស៖** សូមអរគុណដែលបានឆ្លើយបំភ្លឺ។ បើសិនជាខ្ញុំយល់មិនច្រឡំទេ គឺថាការប្រជុំហ្នឹងធ្វើឡើងទៅក្នុងពីរដំណាក់កាល។ ទី១ គឺថាប្រជុំជាមួយនឹងមេកងពលផ្សេងៗទៀត ដែលពេលប្រជុំដើម្បីនិយាយពីស្ថានភាពនៅក្នុង -- យោធានៅក្នុងប្រទេស។ ហើយដំណាក់កាលទី២ គឺថាមានការពិភាក្សាសំណេះសំណាលជាមួយ ប៉ុល ពត រវាងជាមួយនឹងលោក។ ហើយដែលពេលនោះហើយដែលលោក ប៉ុល ពត និយាយអំពីបេសកកម្មពិសេសរបស់លោក។ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ ក្រោយមក គាត់និយាយប្រាប់ប៉ុណ្ណឹង ពេលខ្ញុំចេញទៅព្រះវិហារ។ ដូចខ្ញុំបញ្ជាក់ពីអម្បាញ់មិញអ៊ីចឹង។

**ស៖** តើ ប៉ុល ពត និយាយអំពីបេសកកម្មទៅស៊ើបអង្កេតនៅព្រះវិហារនោះ ពេលណា? ហើយលោក ប៉ុល ពត មានប្រាប់លោកថាទៅព្រះវិហារនោះសម្រាប់រយៈពេលប៉ុន្មានថ្ងៃ ឬប៉ុន្មានខែ ប៉ុន្មានឆ្នាំទេ?

**ឆ៖** បាទ គាត់មិនបានប្រាប់ថា ទៅប៉ុន្មានខែ ប៉ុន្មានថ្ងៃនោះទេ។ គាត់ប្រាប់ថាឲ្យទៅ អត់មានប្រាប់បញ្ជាក់ថាប៉ុន្មានថ្ងៃ គេអត់មានប្រាប់បញ្ជាក់ទេ។ គ្រាន់តែថាឲ្យទៅ។ ពេលដែលខ្ញុំទៅនោះ ទៅសំណាក់នៅសៀមរាបសិន ប្រហែលជា៣ថ្ងៃ បានខ្ញុំទៅព្រះវិហារ។ ប៉ុណ្ណឹង។

[១៣:៤១:២១]

**ស៖** ឥឡូវខ្ញុំសូមនិយាយអំពីប្រជុំនៅទីក្រុងភ្នំពេញនេះបន្តិចទៀត នៅពេលដែល ប៉ុល ពត

ពន្យល់ពីស្ថានភាពនៅព្រះវិហារដោយប្រាប់លោកថា មានមនុស្សដែលត្រូវបានគេចាប់ខ្លួន ហើយនិងមានអ្នកដែលអត់ឃ្លាន តើនៅពេលដែលគាត់បង្ហាញស្ថានភាពនេះទៅលោកនោះ តើគាត់នុំងទំនងជាមានព័ត៌មានលម្អិតដែរឬទេ ឬក៏គាត់មានសួរលោកថាស្ថានភាពនៅទីនោះយ៉ាងម៉េចដែរឬទេ? ខ្ញុំសូមបញ្ជាក់សំណួរខ្ញុំបន្ថែមទៀត នៅពេលគាត់ឲ្យបេសកកម្មនេះទៅលោក តើគាត់មានបានប្រាប់លោកថាសកម្មភាពហ្នឹងមិនធម្មតាទេ ហើយគាត់ចង់ដឹងពីមូលហេតុ ថាហេតុអ្វីបានស្ថានភាពហ្នឹងមិនល្អ?

**ផ៖** បាទ គាត់មិនមានឯកសារណាដែលមកអានប្រាប់ខ្ញុំច្បាស់នោះទេ គាត់និយាយតែមាត់ទទេទេ និយាយប្រាប់តែមាត់ទទេ។ តែគាត់មិនដឹងទទួលផែនការ ឬក៏រាយការណ៍ពីណាមុនក៏មិនដឹង ខ្ញុំក៏អត់បានដឹងដែរ។ គាត់ប្រាប់តែប៉ុណ្ណឹង។

**ស៖** លោកបាននិយាយមុននេះបន្តិចហ្នឹង គឺថា ប៉ុល ពត មិនបានសុំឲ្យលោករាយការណ៍នោះទេ។ សំណួរខ្ញុំ ដោយយោងលើបេសកកម្មរបស់លោកនេះ វាដូចជាមានភាពមិនៗសមហេតុផលនៅពេលដែលគាត់ឲ្យលោកទៅស៊ើបអង្កេត អ៊ីចឹងវាគួរតែថាពេលទៅដល់ព្រះវិហារនោះ គាត់គួរតែឲ្យលោកធ្វើរបាយការណ៍មកគាត់។ អ៊ីចឹងលោកអត់មានយល់អ៊ីចឹងទេ ពេលដែលលោកទៅជួបលោកប៉ុល ពត ពេលដែលគាត់ប្រគល់បេសកកម្មឲ្យលោកនោះ?

[១៣:៤៣:២៣]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។ នេះជាលើកទី២ហើយ ដែលសហភាតារបស់ខ្ញុំបានប្រើប្រាស់ពាក្យថា "បេសកកម្មចុះស៊ើបអង្កេតនៅព្រះវិហារ"។ លោកសាក្សីមិនបានប្រើប្រាស់ពាក្យនេះទេ។ ហើយកន្លងមក តាំងពីមុនរហូតមកដល់ក៏គាត់មិនដែលនិយាយថា ប៉ុល ពត បញ្ជូនឲ្យទៅស៊ើបអង្កេតដែរ។ គឺគាត់គ្រាន់តែបញ្ជាក់ថា ប៉ុល ពត បាននិយាយអំពីស្ថានភាពនៅខាងភាគខាងជើង នៅខាងឧត្តរ ប៉ុន្តែមិនបានប្រើពាក្យថា "បញ្ជូនឲ្យទៅមានបេសកកម្មស៊ើបអង្កេត" អ្វីនោះឡើយ។ ដូច្នេះខ្ញុំចង់ឲ្យសហភាតារបស់ខ្ញុំប្រើប្រាស់ឲ្យបានត្រឹមត្រូវនៅក្នុងសំណួររបស់គាត់។

[១៣:៤៤:២១]

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** លោក មាស វឿន លោកទើបតែស្ដាប់ការពន្យល់របស់សហព្រះរាជអាជ្ញា។ បើអ៊ីចឹងតើកម្មវត្ថុនៃការបេសកកម្មរបស់លោកដែល ប៉ុល ពត ផ្ដល់ឲ្យនៅថ្ងៃនោះៗ គឺទៅដើម្បីធ្វើអ្វី?

**លោក មាស វឿន៖**

**ឆ៖** បាទ គាត់ផ្ដល់ឲ្យខ្ញុំទៅក្ដាប់សភាពការណ៍នៅកន្លែងព្រះវិហារ។

[១៣:៤៥:០៤]

**ស៖** នៅសវនាការថ្ងៃទី០៤ តុលា ម៉ោង ១៤:០៨:០០ គេៗចោទសំណួរលោកដូចតទៅនេះ សំណួរ៖ “តើលោកទទួលបន្ទុកធ្វើអ្វីនៅព្រះវិហារ? ហេតុអ្វីបានជាលោកត្រូវទៅទីនោះ”? ចម្លើយរបស់លោក៖ “បាទ ជាបឋមគេឲ្យតាសឿង ទៅសៀមរាប ដើម្បីស៊ើបអង្កេតលើការឃុំខ្លួនមនុស្សមួយចំនួន ហើយការងារផ្ទាល់របស់ខ្ញុំនៅក្នុងខេត្តព្រះវិហារ គឺស៊ើបអង្កេតលើការចាប់ខ្លួន ហើយនិងការឃុំឃាំងខ្លួនមនុស្សមួយចំនួនដើម្បីរកការពិត។ លើសពីនេះទៅទៀត ខ្ញុំទទួលបន្ទុកក្នុងការបញ្ជូនទំនិញទៅព្រះវិហារ អីវ៉ាន់ទៅព្រះវិហារ។ ហើយជាក់លាក់ជាងហ្នឹងទៀត គឺថាដើម្បីផ្ទៀងផ្ទាត់ថាតើវត្ថុទាំងអស់នោះ អីវ៉ាន់ទាំងអស់នោះបានផ្ញើទៅដល់ព្រះវិហារដែរឬក៏អត់? អ៊ីចឹងសំណួរខ្ញុំនេះគឺថា ថាលោកហ្នឹងទទួលបន្ទុកខាងទៅស៊ើបអង្កេតនៅព្រះវិហារ អ៊ីចឹងតើមែនទេ?

[១៣:៤៦:១៩]

**ឆ៖** បាទ ទៅស៊ើបសភាពការណ៍ទាំងអស់ អាហ្នឹងខ្ញុំបានបញ្ជាក់ពីលើកមុនរួចមកហើយ។ ការ -- គាត់ប្រាប់ថា កន្លែងនុ៎ងគេចាប់ប្រជាជន ហើយកន្លែងហ្នឹងប្រជាជនអត់បាយហូបខ្លះ។ ហើយកន្លែងហ្នឹងដែលមានការភិតភ័យច្រើនដែរ ឯចំណែកដឹងសភាពការណ៍នោះហើយ ខ្ញុំមិនបានរាយការណ៍មក តាប៉ុល ពត ទេ ដោយសារតែៗ តាសឿង ប្រធាន ទៅជាមួយខ្ញុំដែរ ខ្ញុំអាចនឹងបញ្ជាក់ជាមួយនឹងតាសឿង ហើយក៏ តាសឿង គាត់អាចនឹងមកមើលផ្ទាល់នៅហ្នឹងកន្លែងនោះដែរ។ ដូច្នេះបើសិនណាជាការរាយការណ៍ផ្ទាល់ប្រហែលជា តាសឿង តំណាងឲ្យសេចក្ដីរាយការណ៍នេះទៅខាង ប៉ុល ពត។

**ស៖** សូមអរគុណដែលបានស្រាយបំភ្លឺ។ ឥឡូវ -- បន្តិចទៀតនេះ ខ្ញុំនឹងត្រឡប់ទៅសំណួរដែលខ្ញុំចោទសួរអម្បាញ់មិញនេះ នៅពេលដែល ប៉ុល ពត លោកនិយាយអំពីស្ថានភាពនេះ តើៗគាត់ឲ្យលោកស៊ើបអង្កេតនុ៎ង ដោយសារតែស្ថានភាពមិនធម្មតា ឬក៏យ៉ាងម៉េច? តើលោកយល់នៃបញ្ជារបស់គាត់យ៉ាងម៉េចដែរ ការណែនាំរបស់គាត់ហ្នឹង?

**ឆ៖** បាទ ការណែនាំរបស់គាត់ គាត់ប្រាប់ដូចខ្ញុំបញ្ជាក់អំមិញអ៊ីចឹង គាត់ឲ្យ -- ចំណុចដែលរាយការណ៍គាត់អត់ប្រាប់ឲ្យរាយមកខ្ញុំទេ តែគាត់បែបគាត់សំអាងទៅលើ តាសឿង ព្រោះ តាសឿងគាត់ទៅជាមួយខ្ញុំ។ គាត់ហៅខ្ញុំទៅជាមួយ។ ដូច្នេះ គាត់ក៏បញ្ជាក់ប្រាប់ថា ឲ្យទៅមើល ទៅស៊ើបមើលតើរឿងហ្នឹងវាពិតមែន ឬក៏មិនមែន ប៉ុណ្ណឹង។

[១៣:៤៨:៤១]

**ស៖** សូមអរគុណ។ ម្សិលមិញ នៅពេលដែលលោកឆ្លើយតបទៅនឹងសំណួរមួយរបស់លោកចៅក្រម ឡាវែន៍ លើស្ថានភាពនៅព្រះវិហារ លោកបាននិយាយអំពីទស្សនកិច្ចមួយដែលលោកបានធ្វើនៅឃ្លាំងមួយដែលមានមុង ភួយ ដែលខ្វះតស៊ូ។ សំណួរខ្ញុំសួរថាតើ មុង ភួយនោះជាសម្ភារៈដែលគេលោកឲ្យ លោកផ្ទៀងផ្ទាត់មើលថា តើមុង ភួយទាំងអស់ហ្នឹង ពេលដែលបញ្ជូនទៅហ្នឹងបញ្ជូនទៅដល់ទិសដៅឬក៏អត់? មែនទេ? គេសួរឲ្យលោកផ្ទៀងផ្ទាត់អ៊ីចឹងមែនទេ?

**ឆ៖** បាទ អ៊ីចឹងមែន។

**ស៖** បើសិនខ្ញុំយល់មិនច្រឡំទេ គឺថាវត្ថុទាំងអស់នោះផ្ញើចេញពីភ្នំពេញទៅ ភ្នំពេញជាអ្នកផ្ញើទៅមែនទេ?

**ឆ៖** បាទ របស់ទាំងអស់ហ្នឹងចេញពីភ្នំពេញទៅ តែមានក្រសួងគេអ្នកដឹកជញ្ជូន គេដឹកជញ្ជូនយកទៅឲ្យមុនដែលខ្ញុំទៅ មិនដឹងប៉ុន្មានខែ មិនដឹងទេ ប៉ុន្តែរបស់ទាំងអស់ហ្នឹងគឺដឹកជញ្ជូនយកទៅឲ្យខាងប្រជាជនព្រះវិហារហ្នឹង មុនដែលខ្ញុំទៅទាំងអស់ ទាំងក្រណាត់ ទាំងមុង ទាំងភួយ ទាំងអំបិលស្ករស អ្វីទាំងអស់ដែលសម្រាប់ប្រជាជននៅកន្លែងនោះ ដែល ពេលដែលខ្ញុំទៅហ្នឹងអត់បានដឹកស្អីទៅទេ។ ខ្ញុំទៅតែខ្លួនទទេ។

**ស៖** សូមអរគុណ។ លោកបានលើកឡើងអំពីការប្រជុំមួយដែលប្រព្រឹត្តឡើងនៅសៀមរាបដែលនៅក្នុងកិច្ចប្រជុំនេះ តាសឿង បាន -- ត្រូវបានចាត់តាំងជាអ្នកទទួលខុសត្រូវថ្មីនៅភូមិភាគឧត្តរ។ សំណួរខ្ញុំទាក់ទងនឹងព្រឹត្តិការណ៍នោះ គឺចង់សួរថា តើកិច្ចប្រជុំនោះប្រព្រឹត្តទៅនៅពេលណា? គឺថាក្រោយពីកិច្ចប្រជុំដែលប្រព្រឹត្តឡើងនៅភ្នំពេញជាមួយ ប៉ុល ពត ឬក៏យ៉ាងម៉េច?

[១៣:៥១:២០]

**ឆ៖** បាទ កាលប្រជុំនៅសៀមរាបហ្នឹងមាន តាសឿង តាម៉ុក តាប៉ុល ពត ហើយប្រហែលជាម៉ោង ប្រជុំប្រហែលជាម៉ោងប្រាំពីរព្រឹក។ ពេលនោះ ខ្ញុំអត់ -- គេមិនឲ្យនៅជិតទេ។ ឲ្យខ្ញុំនៅឆ្ងាយ

កន្លែងដែលខ្ញុំសម្រាក។

**ស៖** សំណួរខ្ញុំឥឡូវនេះ គឺខ្ញុំចង់ដឹងថា នៅពេលដែលលោកចាកចេញពី ប៉ុល ពត ក្រោយពីពេលប្រជុំនៅទីក្រុងភ្នំពេញ សួរថាតើលោកទៅសៀមរាបភ្លាម ឬក៏យ៉ាងម៉េច?

**ឆ៖** បាទ ប្រជុំហើយភ្លាម ចាប់ផ្ដើមរៀបចំចេញទៅតែម្ដង។

**ស៖** សូមបំភ្លឺមួយទៀតទាក់ទងទៅនឹងការកិច្ចប្រជុំនៅភ្នំពេញជាមួយ ប៉ុល ពត នុ៎ង តើ ប៉ុល ពត មានបាននិយាយពីករណីចាប់បងប្អូនថ្លៃរបស់លោក ខៀវ សំផន ដែរឬទេ? តើ ប៉ុល ពត មានលើកពីករណីហ្នឹងមកនិយាយដែរឬទេ នៅក្នុងកិច្ចប្រជុំនៅទីក្រុងភ្នំពេញ?

**ឆ៖** បាទ គ្មាន។ អត់មាននិយាយ។

[១៣:៥៣:១២]

**ស៖** បើដូច្នេះលោកចេញពីភ្នំពេញទៅសៀមរាបតែម្ដង ហើយការ -- កិច្ចប្រជុំដែល តាសឿង នោះចូលប្រជុំដែរនោះ តើប្រព្រឹត្តឡើងនៅពេលណា គឺថាក្រោយពេលដោះលែងបងថ្លៃលោក ខៀវ សំផន ឬក៏មុនពេលដោះលែងបងថ្លៃលោក ខៀវ សំផន?

**ឆ៖** បាទ ការប្រជុំមុន ហើយបានដោះលែងក្រោយ។ ដឹងរយៈប៉ុន្មានថ្ងៃខ្ញុំមិនចាំ។

**ស៖** ឥឡូវនេះ ខ្ញុំសូមនិយាយអំពីសេចក្ដីប្រកាសរបស់លោក ចម្លើយ -- E3/234 -- អ៎! 424 សូមទោស នៅសំណួរទី១១ ដែលលោកនិយាយអំពីកិច្ចប្រជុំនេះ។

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតបញ្ចាំងចម្លើយនេះទៅលើអេក្រង់ ERN ជាភាសាបារាំងគឺ 00455270, ជាភាសាខ្មែរគឺ 00418521, ERN ជាភាសាអង់គ្លេសគឺ 00421072។ សំណួរនេះ មានកត់លេខ។ អ៊ីចឹង ខ្ញុំសូមអានសំណួរ លេខសំណួរលោកសាក្សី។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត! សូមអញ្ជើញ!

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។

[១៣:៥៥:៣៤]

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** នៅក្នុងចម្លើយរបស់លោក លោកពន្យល់ដូចតទៅនេះ ខ្ញុំសូមដកស្រង់ទាំងស្រុងតែម្តងទៅស្រួលជាង “នៅពេលប្រជុំនៅសៀមរាប មានតា ប៉ុល ពត, តាម៉ុក, តាសែ និង តាសឿង ប៉ុន្តែខ្ញុំមិនបានចូលរួមប្រជុំទេ។ ក្រោយពីការប្រជុំ តាសឿង បានប្រាប់ខ្ញុំថា មានការផ្លាស់ប្តូរមេទាហាន និងផ្លាស់ប្តូរប្រធានភូមិភាគឧត្តរ។ នៅក្នុងរឿង តាសឿង មកធ្វើជាប្រធានភូមិភាគឧត្តរថ្មីនៅខេត្តសៀមរាប ចំណែកខ្ញុំឲ្យមកគ្រប់គ្រងតំបន់១០៣ ខេត្តសៀមរាប -- ខេត្តព្រះវិហារ”។ សំណួរខ្ញុំដូចតទៅនេះ តើតាសឿង ពន្យល់ថា លោកនោះត្រូវបានតែងតាំង ឲ្យធ្វើជាប្រធានតំបន់១០៣នោះ នៅពេលណា?

**លោក មាស វឿន៖**

**ឆ៖** បាទក្នុងពេលដែល តាសឿង ប្រជុំរួចហើយនោះ ពេលស្អែកឡើងបាន តាសឿង ប្រាប់ខ្ញុំថា ឲ្យខ្ញុំទៅទទួលតំបន់១០៣។ ហើយក៏ក្នុងនុ៎ង គាត់ប្រាប់ឲ្យខ្ញុំទៅ ហើយខ្ញុំមិនសូវដឹងផ្លូវទៅ គាត់ជូនខ្ញុំទៅដល់ស្រុករវៀង ក្នុងពេលដែលប្រជុំហើយរំលង១ថ្ងៃបាទ។

[១៣:៥៧:២២]

**ស៖** សូមអរគុណ។ ដូច្នេះនៅពេលដែលគាត់នាំលោកទៅនោះ តើលោកដឹងថា លោកនោះត្រូវបានតែងតាំងជាប្រធានតំបន់១០៣ ដែរឬទេ?

**ឆ៖** បាទ ខ្ញុំអត់ទាន់ថា -- គាត់អត់ប្រាប់ថា ឲ្យធ្វើប្រធាន ឬក៏ធ្វើអនុអីទេ គាត់ថាឲ្យទៅទទួលតំបន់១០៣ ប៉ុន្តែមិនដឹងថា ខ្ញុំធ្វើជាប្រធាន ឬក៏អ្នកណាបន្ថែមទៀត ខ្ញុំមិនដឹងដែរ ប៉ុន្តែឲ្យ -- គាត់ប្រាប់តែប៉ុណ្ណឹង ដឹងតែឲ្យខ្ញុំទៅទទួលតំបន់១០៣ តែម្នាក់ឯង។

**ស៖** ហើយលោកត្រូវទទួលមុខងារអ្វីដែរ នៅតំបន់១០៣នុ៎ង?

**ឆ៖** បាទ គាត់អត់បានប្រាប់ថា ជាមុខងារអ្វី។ គាត់អត់ទាន់បានប្រាប់ គាត់ប្រាប់ថាឲ្យទៅទទួលអីចឹងតែម្តង អត់ថា អ្នក ត្រូវទទួលធ្វើជាប្រធានតំបន់១០៣ ឬក៏អនុអី គាត់អត់បានប្រាប់ផង។

[១៣:៥៨:៥៤]

**ស៖** តើនៅពេលណាដែលលោកដឹងអំពី មុខងាររបស់លោកនៅពេលណាដែរ?

**ឆ៖** បាទ តែខ្ញុំអត់ដឹងថា នាទីខ្ញុំជា ពេលណាទេ រហូតដល់យួនវៃចូលស្រុកខ្មែរ អត់ដឹងជារហូត។

**ស៖** អីចឹងថា ខ្ញុំត្រូវយល់ថា លោកយល់ថា លោកជាប្រធានតំបន់១០៣ ហ្នឹងនៅខែមករា ឆ្នាំ

១៩៧៩ ឬក៏យ៉ាងម៉េច?

**ឆះ** បាទ គាត់ប្រាប់ កាលដែលឲ្យខ្ញុំទៅ មិន១៩៧៩ ទេ ១៩៧៨ និងក្នុងខែ៨ មិនទាន់ចូល៧៩ ទេ នៅប្រហែលជា៤ខែទៀត បានចូល៧៩។ ហើយគាត់មិនប្រកាសមុខតំណែងថាឲ្យខ្ញុំ ឲ្យជាទទួលយ៉ាងម៉េច ឬក៏មុខនាទីថា អ្នំ ឲ្យខ្ញុំធ្វើប្រធានតំបន់ ឬអនុតំបន់ទេ គាត់អត់បានប្រាប់អ៊ីចឹង រហូតដល់យួនវ៉ៃ។

[១៤:០០:៤៨]

**សះ** ខ្ញុំគិតថាប្រហែលយើងមិនយល់គ្នាហើយ ប្រជុំនៅសៀមរាបដែល តាសឿង ត្រូវបានតែងតាំងជាប្រធានភូមិភាគឧត្តរថ្មី។ តើការតែងតាំងគាត់ ជាប្រធានឧត្តរថ្មីនេះនៅពេលណាដែរ? លោកអាចបញ្ជាក់បានទេ?

**ឆះ** បាទ ការប្រជុំនៅសៀមរាបហ្នឹង ខ្ញុំមិនដឹងថ្ងៃខែទេ ប៉ុន្តែក្នុងខែ៨ហ្នឹង ក្នុងខែ៨ដែលខ្ញុំទៅ។ ខ្ញុំទៅដល់សៀមរាប ស្អែកឡើងចាប់ផ្ដើមប្រជុំ ប្រជុំបាន១ថ្ងៃ តាសឿង ប្រាប់ខ្ញុំៗ ស្អែកឡើងទៀតបាន តាសឿង ប្រកាសថា មិត្តឯងទៅ ថាត្រូវទៅព្រះវិហារ ទៅទទួលតំបន់ព្រះវិហារ ហើយគាត់នៅសៀមរាប គាត់ប្រាប់ប៉ុណ្ណឹង។ ប៉ុន្តែថ្ងៃ ខ្ញុំមិនបានចាំថ្ងៃ ដឹងតែខែ។

**សះ** សូមអរគុណ។ អ៊ីចឹងយើងនៅខែសីហា ឆ្នាំ១៩៧៨ ហើយលោកបានទៅព្រះវិហារនៅតំបន់១០៣។ ហើយពេលដែលលោកទៅទីនុ៎ង នៅខែសីហា ឆ្នាំ៧៨ ហ្នឹង លោកប្រាប់គេនៅទីនោះថាយ៉ាងម៉េច? លោកមានឋានៈអី?

**ឆះ** ខ្ញុំទៅដល់ក៏ខ្ញុំមិនបានប្រាប់បងប្អូននៅកន្លែង ប្រជាជននៅកន្លែងនោះ ខ្ញុំអត់បានប្រាប់ដែរ។ ខ្ញុំចេះតែដើរធ្វើការតាម ក្ដាប់សភាពការណ៍មើលតាមស្រុកអ៊ីចឹងទៅ ពីព្រោះខ្ញុំ គេអត់ប្រកាសប្រាប់ខ្ញុំថាខ្ញុំជាស្អី ក៏ខ្ញុំអត់បានប្រកាសប្រាប់គេដទៃទៀតដែរ។ ប៉ុន្តែគ្រាន់តែខ្ញុំថាមកស៊ើបការណ៍ មកចង់ដឹងពីការរស់នៅ ហើយចង់ដឹងពីរបស់របរដែលៗគេដឹកជញ្ជូនមកឲ្យប្រជាជនកន្លែងហ្នឹង ហើយខ្ញុំមិនដែលប្រកាសខ្លួនខ្ញុំថាឈ្មោះជាស្អីទេ ខ្ញុំអត់ទាន់បានប្រកាសប្រាប់គេទេ។

[១៤:០៣:១៦]

**សះ** សូមអរគុណ។ នៅពេលដែលលោកបានស៊ើបអង្កេតហើយ ទាក់ទងទៅនឹងស្ថានភាពហើយនិងរបស់របរនោះ ហើយតើលោកត្រូវបាន -- លោកត្រូវត្រឡប់សៀមរាបដើម្បីរាយការណ៍ឲ្យតាសឿង វិញ ឬក៏យ៉ាងម៉េច?

**ឆ៖** បាទ តាសឿង គាត់ចុះមកម្តងទៀត មកជួបខ្ញុំនៅរវៀងហ្នឹង ហើយខ្ញុំក៏រាយការណ៍ប្រាប់គាត់នៅហ្នឹងទៅ ខ្ញុំមិនបានសរសេរទេ។ ហើយគាត់មកដើម្បីចង់ដឹងសភាពការណ៍ហ្នឹងច្បាស់អ៊ីចឹង គាត់មកជួបខ្ញុំ ហើយខ្ញុំរាយការណ៍ប្រាប់អំពីស្ថានការណ៍រស់នៅរបស់ប្រជាជន ហើយអំពីការគេចាប់ប្រជាជននៅកន្លែងនុំង ហើយអំពីការឃុំឃាំងអ្នកទោសនៅស្រុករវៀង ហើយការអត់បាយ សំខាន់នៅប្រជាជននៅជាំខ្សាន្ត ហើយនិងនៅថាឡាបរិវ៉ាត់ហ្នឹង លំបាកផ្លូវដឹកជញ្ជូនយករបស់ឲ្យប្រជាជននៅកន្លែងនោះ។ ហើយពីមុនមិនទាន់មានផ្លូវអីត្រឹមត្រូវទេកន្លែងនោះ សុទ្ធតែព្រៃទាំងអស់។ គាត់ក៏យល់ពីសភាពការណ៍ហ្នឹងទៅ ហើយគាត់កត់ពីសភាពការណ៍ហ្នឹងទៅ ឯការរាយការណ៍របស់គាត់ទៅណាទៀត ខ្ញុំមិនបានដឹង។ គាត់ថារាយទៅខាងណា ខ្ញុំអត់បានដឹង គាត់មកសៀមរាបវិញមក។

[១៤:០៤:៥៤]

**ស៖** សូមអរគុណ។ អ៊ីចឹងបានន័យថា គាត់ជាអ្នកមក អ៊ីចឹង -- តើ តាសឿងហ្នឹងគាត់មកជួបលោកហ្នឹងរយៈពេលប៉ុន្មានក្រោយពេលដែលលោកមកដល់ខេត្តព្រះវិហារនេះ គាត់មកជួបលោកនោះ?

**ឆ៖** បាទ គាត់មកតែ១ថ្ងៃទេ។ គាត់មិនបានមកដេកនៅហ្នឹងទេ។ ១ថ្ងៃក្នុង ពេលដែលគាត់មកសាកសួរ គាត់មកម្តងហ្នឹង មកដឹងសភាពការណ៍ហ្នឹង។

**ស៖** ហើយគាត់មក១ថ្ងៃហ្នឹង ដើម្បីស្តាប់លោករាយការណ៍ហ្នឹង តើគាត់មកជួបលោកហ្នឹងថាលោកមកដល់ព្រះវិហារប៉ុន្មាន រយៈពេលប៉ុន្មានហើយបានគាត់មកជួបលោកនោះ? ២-៣ថ្ងៃ, ១អាទិត្យ, ១ខែ រយៈពេលប៉ុន្មាន ក្រោយពេលដែលលោកបានមកដល់ព្រះវិហារហើយនោះ? គាត់មកជួបលោកដើម្បីលោករាយការណ៍ហ្នឹង?

[១៤:០៦:០៨]

**ឆ៖** បាទ គាត់មកជួបខ្ញុំប្រហែលជា១អាទិត្យក្រោយមក។

**ស៖** សូមអរគុណដែលបានឆ្លើយបំភ្លឺ។ ឥឡូវនេះ ខ្ញុំសូមត្រឡប់មកនិយាយអំពីបញ្ហាដោះលែងបងថ្លៃរបស់លោក ខៀវ សំផន វិញម្តង។ នៅពេលដែលគេសួរលោកនៅថ្ងៃទី០៤ តុលា មុនម៉ោងដប់ពីរបន្តិច -- ម៉ោងដប់បួនបន្តិច។ លោកឆ្លើយថា "បន្ទាប់ពីបានដោះលែងគាត់ហើយ។ ខ្ញុំបានត្រឡប់ទៅព្រះវិហារវិញ។ ខ្ញុំមិនដឹងថានៅទីនោះមានរឿងអ្វីកើតឡើងទេក្រោយពេលដែលខ្ញុំចេញផុតទៅនោះ"។ សំណួរខ្ញុំដូចតទៅនេះ ខ្ញុំចង់ដឹងថា តើការដោះលែងបងថ្លៃរបស់លោក ខៀវ សំផន នេះ កើតមានឡើងមុនពេលត្រឡប់ទៅសៀម -- ទៅព្រះវិហារវិញក្រោយពីបានស៊ើបអង្កេតហើយ ឬក៏ក្រោយពេលហ្នឹង

ទៀត?

**ឆ៖** បាទ កាលមុន មុនខ្ញុំទៅព្រះវិហារហ្នឹង មិនទាន់ដោះលែង អំ! ដោះលែងហើយៗ បាន តាសឿង គាត់ជូនខ្ញុំទៅព្រះវិហារ។

**ស៖** បាទ ខ្ញុំយល់ស្រប។

**កញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំយល់ស្រប នៅក្នុងចម្លើយរបស់លោក E3/424 ខ្ញុំសូមអនុញ្ញាតបញ្ចាំងលើអេក្រង់ គឺចម្លើយ និងសំណួរទី២០។ លោកប្រធានសូមអនុញ្ញាតបញ្ចាំងលើអេក្រង់។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត!

[១៤:០៨:០៧]

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** សំណួរគេចោទសួរលោកនៅថ្ងៃនោះ គឺថា "តើអ្នកណាជាអ្នកដោះលែងបងថ្លៃរបស់លោក ខៀវ សំផន ឈ្មោះ យៀត ដែលឃុំខ្លួននៅមន្ទីរសន្តិសុខខេត្តសៀមរាប?"។ ចម្លើយ "គឺ តាសឿង ដែលទៅជួប ហើយនិងបញ្ជាឲ្យដោះលែង"។ សូមបញ្ចប់ការដកស្រង់។ សំណួរខ្ញុំដូចតទៅនេះ តើ លោក ឬក៏ តាសឿង ដែលបានទៅជួបបងថ្លៃលោក ខៀវ សំផន ហើយ ហើយប្រាប់ឲ្យគេដោះលែង គាត់?

**លោក មាស វឿន៖**

**ឆ៖** បាទ។ តែមុននឹង តាសឿង គាត់ទៅដោះ។ មុនដំបូងមិនទាន់ទៅដោះទេ គាត់ទៅទំនាក់ ទំនងជាមួយនឹងមានកន្លែងយោធាដែលគាត់ទៅស្គាល់ហ្នឹង។ ហើយបានគាត់ទៅស៊ើបមើល។ ស៊ើប មើលហើយបានត្រូវដោះលែង ដោះលែងបងថ្លៃលោក ខៀវ សំផន ហ្នឹងបាទ។

[១៤:០៩:៣០]

**ស៖** នៅពេលដែលលោកផ្តល់សក្ខីកម្មនៅទីនេះ គឺថាលោកបានឆ្លើយថា "លោកបានទទួលទូរ លេខពីលោក ខៀវ សំផន ដែលសុំឲ្យលោករាយការណ៍អំពីបងថ្លៃ -- គ្រួសារថ្លៃរបស់គាត់"។ ថ្ងៃទី៤ តុលា នៅម៉ោង១៤:១៤ នាទី ពេលដែលលោកឆ្លើយទៅសហព្រះរាជអាជ្ញា លោកឆ្លើយថា "លោកមិន ចាំកាលបរិច្ឆេទច្បាស់លាស់នោះទេ ក៏ប៉ុន្តែបានផ្ញើទូរលេខមួយដង"។ ខ្ញុំសូមដកស្រង់ "គាត់បានផ្ញើ

ទូរលេខឲ្យខ្ញុំ មកខ្ញុំមួយ ឲ្យខ្ញុំរាយការណ៍ថាតើយើងបានឃើញបងប្អូនគាត់ដែរឬទេ ឧទាហរណ៍ដូចជាពូគាត់ជាដើម”។ សំណួរខ្ញុំដូចតទៅនេះ នៅពេលដែលលោកទទួលទូរលេខនុ៎ង តើពេលនុ៎ងលោកនៅឯណា?

**ឆ៖** បាទ ខ្ញុំនៅព្រះវិហារ។

**ស៖** បើខ្ញុំយល់មិនច្រឡំទេ បើសិនជា ខៀវ សំផន ផ្ញើទូរលេខនេះទៅលោកនោះ គឺថាគាត់មិនដឹងពីស្ថានភាពរបស់ក្រុមគ្រួសារសាច់ថ្លៃរបស់គាត់នៅតំបន់១០៣ តើខ្ញុំយល់ហ្នឹងត្រឹមត្រូវដែរឬទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

[១៤:១១:១៦]

**លោក អាប់ឌុលឡាក់ ថារីក៖**

យើងសូមជំទាស់ចំពោះមេធាវីដែលបានស្នើសុំឲ្យសាក្សីធ្វើការទាយស្មានអំពីគំនិត ឬក៏អំពីការគិតរបស់លោក ខៀវ សំផន នៅពេលនោះ។ គឺថានៅពេលនោះ សាក្សីគាត់នៅខេត្តព្រះវិហារនៅឡើយ។

**ស្ស្ររដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** លោកសាក្សី តើលោកឯកភាពដែរឬទេ គឺថានៅក្នុងទូរលេខដែលលោកបានទទួលនោះ លោក ខៀវ សំផន បានសួរលោកថាលោកបានឃើញសមាជិកក្រុមគ្រួសាររបស់គាត់ដែរឬទេ?

**លោក មាស វឿន៖**

**ឆ៖** ក្នុងពេលដែលខ្ញុំទទួលសារលោក ខៀវ សំផន នុ៎ង គាត់មិនបាននិយាយអំពីប្អូនរបស់គាត់ទេ គាត់និយាយទៅលើម្ដាយ និងឪពុកគាត់ដែលចាស់ហើយ។ បាទ ប៉ុណ្ណឹងឯង។

**ស៖** នៅក្នុងសវនាការថ្ងៃទី ថ្ងៃដដែល គឺថ្ងៃទី នៅម៉ោង១៤:១៥ សឺហ្គុង នៅពេលដែលលោកឆ្លើយទៅសហព្រះរាជអាជ្ញា ទាក់ទងទៅនឹងប្រធានបទនៃទូរលេខរបស់លោក ខៀវ សំផន នេះ។ ខ្ញុំសូមដកស្រង់ដូចតទៅនេះ “គាត់គ្រាន់តែប្រាប់ខ្ញុំតែប៉ុណ្ណឹង គឺថាឲ្យមើលឲ្យគាត់ផង ហើយថាៗបើគាត់លំបាកឬទេ ឲ្យយកគាត់ទៅភ្នំពេញ។ ប៉ុន្តែស្ថានភាពនៅពេលនោះ គឺថាវាមានភាពច្របូកច្របល់ ហើយការទាក់ទងគ្នានោះដាច់គ្នាត្រឹមហ្នឹងទៅ”។ សំណួរខ្ញុំដូចតទៅនេះ នៅពេលដែលលោកទទួលសារហ្នឹងពីលោក ខៀវ សំផន ហ្នឹង តើលោកដឹងដែរ -- តើលោកមិនដឹងថាលោក ខៀវ សំផន មិនដឹងថាមាន

រឿងអីកើតឡើងចំពោះគ្រួសារគាត់នោះទេ អ៊ីចឹងហើយបានជាគាត់សុំឲ្យលោករកមើលក្រុមគ្រួសារគាត់នោះ អ៊ីចឹងមែនទេ?

**ឆ៖** បាទ អ៊ីចឹងហើយ។

**ស៖** លោកឆ្លើយថានៅពេលដែលលោកបានទទួលទូរលេខនេះ លោកនៅខេត្តព្រះវិហារ។ តើនៅកន្លែងដែលលោកទទួលទូរលេខនោះ ថាមន្ទីរទូរលេខដែលលោកបាននិយាយនៅក្នុងសវនាការនេះ ជាមន្ទីរដែល អ៊ុយ ហើយនិង អុល អ្នកធ្វើការទេ? ហើយគឺលោកទទួលទូរលេខហ្នឹងនៅមន្ទីរហ្នឹងមែនទេ?

[១៤:១៤:៣៧]

**ឆ៖** បាទ មន្ទីរហ្នឹងមិនមែនជាមន្ទីរត្រឹមត្រូវទេ។ មន្ទីររបស់ តាខឹម ។ គាត់មកទាំងប្តីប្រពន្ធគាត់មកសម្រាកកន្លែងហ្នឹង ហើយខ្ញុំក៏ទៅពីនេះទៅ ក៏សម្រាកហ្នឹងដែរ។ ឯមន្ទីរ -- ឯអ្នកវាយការណ៍ទូរលេខហ្នឹង អើយ ហើយ អុល ហ្នឹង ខ្ញុំដើរសួរគេទៅថា អើយ ហើយ អុល ហ្នឹងអ្នកកាន់សារទូរលេខ។ ហើយក៏ខ្ញុំយកគាត់មកសម្រាកនៅហ្នឹង។ ដូច្នេះការទទួលនៅហ្នឹងឯង។

**ស៖** សូមអរគុណ។ នៅសវនាការថ្ងៃទី០៤ តុលា ដដែលគឺថានៅម៉ោង ១៤:២៤:០០ លោកបានលើកឡើងដូចតទៅនេះ៖ "ខ្ញុំវាយការណ៍ទៅតែម្តងគត់ ទាក់ទងទៅនឹងស្ថានភាពឪពុកម្តាយក្មេករបស់គាត់ ហើយនិងគ្រួសារ។ ខ្ញុំធ្វើរាយការណ៍នេះទៅឲ្យគាត់ ហើយមានតែម្តងនេះទេដែលខ្ញុំរាយការណ៍នោះ។ ហើយបន្ទាប់មកទៀត មានការវាយប្រហារអំពីសំណាក់ទាហានវៀតណាមលើតាមផ្លូវដូច្នេះក្រោយមកក៏បាត់ទំនាក់ទំនងគ្នារហូត"។ នៅពេលដែលលោកឆ្លើយទៅមេធាវីដើមបណ្តឹងរដ្ឋប្បវេណីកាលពីម្សិលនេះ -- ម្សិលមិញនេះលោកបានឆ្លើយ ចន្លោះម៉ោង ០៩:៣៨:០០ ហើយនិងម៉ោង ០៩:៤២:០០ លោកឆ្លើយថា "មានបញ្ហាទំនាក់ទំនង"។ ខ្ញុំសូមដកស្រង់ទាំងស្រុងតែម្តង "គឺជាផ្នែកតែមួយគត់ដែលខ្ញុំបានសរសេរក្នុងរបាយការណ៍។ ហើយពុំមានរបាយការណ៍ផ្សេងទៀតនោះទេ ពីព្រោះថាវាដាច់ទំនាក់ទំនងដោយសារវៀតណាមវាយប្រហារ ហើយដាច់ខ្សែទូរស័ព្ទអស់ហើយ"។ នៅ -- ក្រោយមកទៀតនៅពេលដែលលោកឆ្លើយទៅនឹងសំណួររបស់ចៅក្រម ឡាវែន៍ ម្សិលមិញដដែលនេះ គឺលោកបានបញ្ជាក់ថា "នៅចន្លោះខែសីហា ឆ្នាំ១៩៧៨ -- ខែមករា ឆ្នាំ១៩៧៩ ពិបាកនឹងទាក់ទងជាមួយនឹងទីក្រុងភ្នំពេញ ពីព្រោះ -- ខ្ញុំសូមដកស្រង់ នៅម៉ោង ១៤:៤១:០០ "គឺថាទាក់ទងទូរស័ព្ទគ្នាមិនបាន"។

[១៤:១៧:១៤]

តាមចម្លើយរបស់លោកនេះ គឺថាសំណួរខ្ញុំដូចតទៅនេះ តើម៉ាស៊ីនទូរលេខដែលលោកនិយាយថា មានបញ្ហានោះ គឺជាម៉ាស៊ីនទូរលេខដែល អើយ ហើយនិង អុល ជាអ្នកគ្រប់គ្រងមែនទេ? លោកចង់និយាយអំពីម៉ាស៊ីនទូរលេខហ្នឹងឬយ៉ាងណា?

**ឆ៖** បាទ ចង់និយាយពីម៉ាស៊ីនទូរលេខហ្នឹង។

**ស៖** តើជាអ្នកបុគ្គលិកពីរនាក់នេះហើយ គឺថា អើយ ហើយនិង អុល នេះហើយដែលបាន -- ដែលប្រាប់លោកថាមានបញ្ហាទំនាក់ទំនងជាមួយទីក្រុងភ្នំពេញមែនទេ?

**ឆ៖** បាទ គាត់ប្រាប់ហើយបានខ្ញុំដឹងថា ទំនាក់ទំនង -- ពីព្រោះ អើយ ហើយ អុល តាំងពីជំនាន់នៅ តាហង្ស ឯនោះ។ ដល់ តាហង្ស គាត់ត្រូវអឺចឹងគាត់អត់មានការងារអីក៏ មិនស្រួលគេឃុំឃាំងគាត់ទៅ ខ្ញុំទៅដល់ហៅយកមកសួរសាកមក ហើយគាត់ចេះ ខ្ញុំឲ្យ អុល ហើយ អើយ គាត់ផ្ញើសារហ្នឹង បើមានសារអីយ៉ាងម៉េចទំនាក់ទំនងទៅភ្នំពេញយ៉ាងម៉េចហើយគាត់ដឹង ខ្ញុំយកគាត់មក។

[១៤:១៨:៥០]

**ស៖** ហើយនៅពេលដែលលោកស្នើសុំទៅគាត់នោះ តើគាត់ឆ្លើយមកលោកវិញយ៉ាងម៉េចដែរ?

**ឆ៖** បាទ អត់បានឆ្លើយទេ ដាច់ទាក់ទងអត់បានគ្នា។ អត់ឮគ្នា។

**ស៖** នៅក្នុងចម្លើយរបស់លោក គឺថាឯកសារ E3/424 នៅសំណួរ-ចម្លើយទី១៣ បាន --

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតបង្ហាញសំណួរចម្លើយនេះនៅលើអេក្រង់លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** នៅពេល ដែលលោកសម្ភាសដោយអ្នកស៊ើបអង្កេតរបស់សហចៅក្រមស៊ើបអង្កេតនោះ លោកបានឆ្លើយថា ខ្ញុំរាយការណ៍ទៅ ខៀវ សំផន តាមរយៈតេឡេក្រាម ក្នុងនោះខ្ញុំសរសេរទៅលើក្រដាសដោយដាក់ឈ្មោះខ្ញុំ ហើយនិងតំបន់១០៣ ដើម្បីផ្ញើទៅ ខៀវ សំផន បន្ទាប់មកខ្ញុំបញ្ជាឲ្យឈ្មោះ អុល ហើយនិងឈ្មោះ អើយ ឲ្យវាយសារទូរលេខនេះដើម្បីបញ្ជូនទៅ"។ បាទ សូមបញ្ចប់ការដកស្រង់ត្រឹមនេះ។ សំណួរខ្ញុំដូចតទៅនេះ៖ តើលោកដឹងថា របាយការណ៍ដែលលោកឲ្យ អើយ ហើយនិង អុល វ៉ៃនេះ តើដឹងថា ទូរលេខហ្នឹងបានផ្ញើចេញទៅទេ នៅពេលដែលលោកនិយាយអម្បាញ់មិញនេះថា មាន

បញ្ហាទំនាក់ទំនងនោះ?

**លោក មាស វឿន៖**

**ឆ៖** បាទ ក្នុងពេលដែលមានសារផ្ញើតបទៅវិញនុ៎ង អត់ឮ។ អើយ ប្រាប់ថា អត់ឮគ្មានទេ ពីព្រោះថា វាឮមិនច្បាស់ដឹងស្អីជាស្អី គាត់ប្រាប់ខ្ញុំអ៊ីចឹងមកក៏សារហ្នឹងត្រូវស្តុបចូលហ្នឹងសិនទៅ។

[១៤:២១:២៤]

**ស៖** សូមអរគុណ។ ខ្ញុំសូមបន្តពាក់ព័ន្ធទៅនឹងចម្លើយរបស់លោកទៀត គឺឯកសារ E3/424 លោកបានឆ្លើយនៅចំពោះមុខអ្នកស៊ើបអង្កេត នៅពេលនេះខ្ញុំសំដៅទៅដល់ចម្លើយសំណួរ១៨។

**កញ្ញា អង់តា ហ្គីសសេ៖**

ដូច្នេះ ខ្ញុំសូមការអនុញ្ញាតពីលោកប្រធានដើម្បីបញ្ចាំងសំណួរ-ចម្លើយលេខ១៨ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** នៅពេលនោះលោកបានឆ្លើយទៅនឹងសំណួរដែលគេសួរថា "មូលហេតុអ្វីបានជាលោកត្រូវរាយការណ៍ទៅ ខៀវ សំផន ហើយឲ្យរាយការណ៍ពីអ្វីខ្លះ?" ខ្ញុំសូមបញ្ជាក់ថា ខ្ញុំដឹងថា នៅក្នុងភាសាខ្មែរនោះ គឺពហុវចនៈ ឯកវចនៈនោះ គឺថាពិបាកបែងចែកណាស់ ហើយពិបាកបកប្រែណាស់។ ដូច្នេះជាភាសាបារាំងនោះគឺជាពហុវចនៈ លោកបានឆ្លើយថា "ពីព្រោះមានសារទូរលេខពី ខៀវ សំផន ផ្ញើមកឲ្យខ្ញុំថា ពេលមានស្ថានការណ៍អ្វីត្រូវរាយការណ៍ជូនគាត់"។ នេះគឺជាចម្លើយរបស់លោកដែលបានឆ្លើយជូនអ្នកស៊ើបអង្កេត ហើយបន្តទៅទៀត គឺថា "ខ្លឹមសាររបាយការណ៍នោះជាពហុវចនា -- ជាពហុវចនៈគឺរាយការណ៍អំពីជីវភាពប្រជាជនក្នុងសហករណ៍យ៉ាងម៉េចខ្លះ"។ ខ្ញុំសូមបញ្ចប់ត្រឹមប៉ុណ្ណោះសិន។

[១៤:២៣:១៥]

នៅពេលដែលយើងអានចម្លើយ ដែលលោកឆ្លើយជូនអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតនោះ យើងយល់បានថា លោកបានផ្ញើរបាយការណ៍ច្រើនមិនមែនតែមួយទេ ហើយអ្វីដែលលោកបានឆ្លើយកាលពីមុន ហើយនិងពីម្សិលមិញ ហើយនិងថ្ងៃហ្នឹងទៀតនេះ តើលោកអាចបញ្ជាក់ឲ្យបានច្បាស់ទេថា លោកបានផ្ញើរបាយការណ៍តែមួយទេ ឬក៏ផ្ញើច្រើន? ហើយតែមួយហ្នឹងផ្ញើមិនចេញទៀត តើលោកអាចបញ្ជាក់បានទេថា លោកបានផ្ញើរបាយការណ៍ច្រើន ឬក៏ផ្ញើតែមួយទេ?

**លោក មាស វឿន៖**

**ឆ៖** បាទ តាមខ្ញុំចាំ ខ្ញុំឃើញអង្គាល់ដែលសារទូរលេខផ្ញើមកខ្ញុំ លោក ខៀវ សំផន ផ្ញើមកខ្ញុំ គាត់សួរពីម្ដាយក្រុមគ្រួសារគាត់។ អាហ្នឹងគាត់បានសួរខ្ញុំអ៊ីចឹង ពីរឿងការ -- សភាពការណ៍អីផ្សេងៗ គាត់បានបញ្ជាក់តិចពីរឿងប្រជាជនដែរ។ តើប្រជាជនមានប៉ុន្មាន? ហើយមានបញ្ហាប៉ុណ្ណឹង។ ហើយក្នុងនុំងខ្ញុំក៏ចុះ -- ក៏សរសេរប្រាប់គាត់មកវិញ។ សរសេរប្រាប់គាត់មកវិញ រាយការណ៍ប្រាប់គាត់មកវិញ អំពីក្រុមគ្រួសាររបស់គាត់ ម្ដាយរបស់គាត់ ប្អូនរបស់គាត់ និងសភាពប្រជាជនការអត់ឃ្លានយ៉ាងម៉េចខ្លីៗ។ ហើយខ្ញុំសរសេរសារហ្នឹងមកវិញ តែសារនោះដល់ ឬមិនដល់អត់ឃើញគាត់ឆ្លើយតបមកវិញទេ។ ខ្ញុំបានបញ្ជាក់អ៊ីចឹងឯង បាទ។ ខ្ញុំចាំតែម្ដង ឲ្យរាយតែម្ដងប៉ុណ្ណឹង។

**ស៖** លោកទើបតែឆ្លើយប៉ុន្មាននាទីមុននេះថា លោកបានធ្វើរបាយការណ៍ ហើយលោកបានប្រាប់ឲ្យ អើយ និង អុល ផ្ញើ ហើយ អើយ និង អុល ហ្នឹងប្រាប់ថា មិនអាចផ្ញើចេញទេ ព្រោះមានបញ្ហាទំនាក់ទំនងគ្នា។ អ៊ីចឹងតើលោកនៅរក្សាចម្លើយហ្នឹងដដែលទេ?

**ឆ៖** បាទ ខ្ញុំរក្សាចម្លើយហ្នឹង ព្រោះអ្នកវាយសារទូរលេខហ្នឹងមិនបានគេទទួលហើយរក្សា -- វាយ ទៅបានខ្លះដាច់ខ្លះ នៅតាមបកប្រែហ្នឹង។ ប៉ុន្តែគាត់ទទួលបាន ឬមិនបានអាហ្នឹងអត់ឃើញគាត់ឆ្លើយតប ឯសារហ្នឹង ខ្ញុំទុកនៅកន្លែងខ្ញុំវិញខ្លះ មិនដឹងជាគាត់ទទួលបានប៉ុន្មាន អាហ្នឹងខ្ញុំអត់បាន -- គាត់អត់បានតបមកដែរ។

**ស៖** សូមអរគុណចំពោះការឆ្លើយបញ្ជាក់នេះ។ ឥឡូវនេះខ្ញុំចូលទៅនិយាយអំពីមុខងាររបស់លោកនៅតំបន់១០៣។ ដូច្នេះ ខ្ញុំចង់ដឹងថានៅពេលណាឲ្យប្រាកដ ដែលលោកដឹងថា លោកត្រូវបាន តាសឿង ចាត់តាំងឲ្យធ្វើប្រធានតំបន់១០៣?

**ឆ៖** ខ្ញុំមិនបានចាំថ្ងៃទេ ហើយគាត់ឲ្យគ្រាន់តែទទួលតំបន់១០៣ ឯថា ប្រធាន អនុ គាត់អត់បានប្រាប់ រហូតដល់យួនវៃចូលស្រុកខ្មែរ។

[១៤:២៧:២៥]

**ស៖** ខ្ញុំគិតថា យើងដូចជាយល់គ្នាមិនសូវត្រូវ។ តើលោកអាចបញ្ជាក់បានទេថា នៅពេលខេត្តសៀមរាបនោះ គេតែងតាំង តាសឿង ជាប្រធានភូមិភាគឧត្តរថ្មី តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ អាហ្នឹងគាត់បាន គាត់មិនប្រាប់ខ្លួនគាត់ទេ ក៏ប៉ុន្តែការគាត់ទទួលខុសត្រូវ គាត់ទៅទទួលហ្នឹងគឺទទួលភូមិ អូរ៉ែ តំបន់សៀមរាបហ្នឹង តែគាត់ប្រាប់ខ្លួនគាត់ថាគាត់ទទួលភូមិភាគ ហ្នឹងគាត់

អត់បានទាន់ប្រាប់នៅឡើយទេ។ ភូមិភាគថ្មីហ្នឹង គឺគាត់អត់បានប្រកាសប្រាប់ខ្ញុំថា "អ្ហ៎! ខ្ញុំទទួលភូមិភាគថ្មី" គាត់អត់បានប្រាប់ខ្ញុំទេ ប៉ុន្តែគាត់បានតែទទួលតំបន់ព្រះវិហារ អ៊ន៎! តំបន់សៀមរាបប៉ុណ្ណឹងនៅឡើយ។

[១៤:២៨:២៥]

**ស៖** មិនមានប្រាប់លោកជាផ្លូវការទេ ក៏ប៉ុន្តែលោកៗដឹង តើអ៊ីចឹងមែនទេ? ពីព្រោះថានៅក្នុងចម្លើយរបស់លោកដែលឆ្លើយជូនអ្នកស៊ើបអង្កេតនោះ លោកឆ្លើយថា លោកដឹងថាគាត់ជាប្រធាននៃភូមិភាគឧត្តរថ្មី។

**ឆ៖** ខ្ញុំគ្រាន់តែយល់ខ្លួនខ្ញុំថា ប្រហែលៗគាត់ថាទទួលអ៊ីចឹងមែនហើយ ពីព្រោះបើ ត្រូវគាត់ទៅទទួលកន្លែងហ្នឹង ព្រោះគាត់ត្រូវដកកងពលមួយចេញ កងពលនេ៎ -- ព្រោះតាម៉ុក គាត់ដកកងពលនៅឧត្តរចេញ ហើយគាត់ទទួលកងពលហ្នឹង ហើយក្នុងភូមិភាគហ្នឹង ខ្ញុំគ្រាន់តែបានយល់អ៊ីចឹងទេ ការផ្លាស់ប្តូរកងទ័ពហ្នឹងណា៎។

**ស៖** ចុះលោកផ្ទាល់ លោក មាស វឿន នៅតំបន់១០៣ តើលោកទៅនោះ មានកូនចៅ ជាកូនទាហានលោកទៅជាមួយ ទាំងកូនទាហានទេ?

**ឆ៖** បាទ ខ្ញុំទៅ កូនទាហានខ្ញុំប្រហែល១០នាក់ ទៅជាមួយ។

**ស៖** តើលោកត្រូវបំពេញភារកិច្ចយោធាដែរឬទេ នៅតំបន់១០៣?

**ឆ៖** បាទ ទៅដល់ពេលនោះ អត់មានកងទ័ព ទៅបំពេញភារកិច្ចខាងយោធា ខ្ញុំអត់បានបំពេញទេ កន្លែងនោះក្នុងរយៈ៤ខែហ្នឹង ខ្ញុំមិនបានត្រូវមានកងទ័ពមានអី ខ្ញុំទៅតែ១០នាក់ហ្នឹង ដើម្បីគ្រាន់តែស៊ើបការណ៍ស្តាប់សភាពការណ៍ ដូចខ្ញុំបានបញ្ជាក់លើកមុនអ៊ីចឹង វាអ៊ីចឹង។

[១៤:៣០:៣៤]

**ស៖** ហើយនៅក្នុងរយៈ៤ខែនោះ តើលោកធ្វើអ្វីខ្លះនៅក្នុងតំបន់១០៣នោះ?

**ឆ៖** បាទ ខ្ញុំអារឈើ ឱ្យបងប្អូនអារឈើធ្វើផ្ទះ ហើយនិងដើរអប់រំ ប្រជុំប្រជាជននៅតាមស្រុក ហើយនៅតាម -- ហ្នឹងហើយនៅតាមស្រុកខ្លះដែលអាចដើរទៅដល់ ស្រុកខ្លះមិនទាន់ដើរដល់គ្រប់ស្រុកនៅឡើយទេ ប៉ុន្តែផ្លូវវាឆ្ងាយ ដើរមិនទាន់បានគ្រប់ស្រុកផង។

**ស៖** លោកបានឆ្លើយថា តាសឿង បានមកជួបលោកក្នុងរយៈពេល១ថ្ងៃ នៅតំបន់១០៣ ហើយនៅក្នុងពេលជួប១ថ្ងៃនុ៎ង លោករាយការណ៍អំពីស្ថានភាពនៅព្រះវិហារជូន តាសឿង ក៏ប៉ុន្តែកាលពីម្សិល

មិញ នៅពេលដែលលោកឆ្លើយទៅនឹងសំណួររបស់ចៅក្រម ឡាវែន៍ លោកឆ្លើយថា "តាសឿង មកផ្ទះលោក នៅពេលដែលមានការរាយការណ៍ និយាយអំពីវៀតណាមវ៉ៃចូលភ្នំពេញ"។ ហើយកាលពីប៉ុន្មាននាទីមុននេះ លោកបានប្រាប់ថា "តាសឿង បានមកជួបលោកគឺថា បន្ទាប់ពីលោកបានមកដល់ព្រះវិហារបាន១អាទិត្យ"។ ប្រសិនបើយើងនិយាយអំពីវៀតណាមវ៉ៃចូលភ្នំពេញ គឺខែមករា ឆ្នាំ៧៩ គឺថាមិនមែនចុងឆ្នាំ៧៨ទេ។ ដូច្នេះមានន័យថា តាសឿង មកជួបលោកពីរដងនៅព្រះវិហារ តើអ៊ីចឹងមែនទេ? សូមលោកគិតមើលឡើងវិញទៅមើល?

**ឆ៖** បាទ អាលើកមុនគាត់ជូនខ្ញុំមកម្ដង អាហ្នឹងដែលខ្ញុំប្រាប់លោកម្ដង ដែលជូនខ្ញុំមកដល់ហើយមិនគាត់ទៅវិញ។ គាត់ទៅវិញ ក្រោយមកទៀតមក បានគាត់មកម្ដងទៀតពីរដង អាហ្នឹងខ្ញុំដឹងតែពីរដង ដែលគាត់មកជួបខ្ញុំនឹងអាកន្លែងផ្ទះរវៀងហ្នឹងពីរដង។ ពីរដងហ្នឹង ទទួលមានសភាព-ការណ៍វានេះ វាក្ដៅដែរហើយតាមមើល បានគាត់មកម្ដងទៀតហ្នឹង ពេលនុំងហើយដែលខ្ញុំរាយការណ៍ប្រាប់គាត់ខ្លះ ហើយនិងពេលនុំងហើយ ដែលខ្ញុំមានសារសម្រាប់ជូនទៅលោក ខៀវ សំផន បាទ។ ហ្នឹងគឺពីរដងអ៊ីចឹង គាត់មកពីរដង។

[១៤:៣៣:៤៦]

**ស៖** កាលពីម្សិលមិញ នៅពេលដែលលោកនិយាយអំពីការផ្សាយ នៅតាមវិទ្យុសំឡេងអាមេរិកលោកថា ពេលនុំងលោកស្ដាប់ឮគេផ្សាយថា "វៀតណាមវ៉ៃចូលភ្នំពេញ"។ អ៊ីចឹងតើពេលដែលលោកថាស្ដាប់ឮវ៉ៃចូលហ្នឹងពេលណា? ស្ដាប់ឮនៅពេលណា?

**ឆ៖** បាទ អាហ្នឹង ខ្ញុំមិនដឹង អត់ដឹងថ្ងៃ ខ្ញុំអត់ចាំថ្ងៃទេ។ អត់ចាំថ្ងៃខែទេ ថ្ងៃខ្ញុំស្ដាប់វិទ្យុអាមេរិកនោះ ហើយនៅពេលនុំងហើយ ដែល តាសឿង គាត់មកក្ដាប់សភាពការណ៍ផង ហើយគាត់មកសម្រាកខ្ញុំ១យប់ហ្នឹងកន្លែងហ្នឹង ហើយចំណុចត្រង់ហ្នឹងហើយ ដែលខ្ញុំបានប្រាប់ពីៗព័ត៌មានអាមេរិកាំងផ្សាយនុំងបាទ។

[១៤:៣៥:០២]

**ស៖** តើបន្ទាប់ពីការផ្សាយវិទ្យុហ្នឹងហើយនោះ តើរយៈពេលប៉ុន្មានពីការផ្សាយហ្នឹងដែលលោកចេញទៅព្រះវិហារ?

**ឆ៖** អាហ្នឹងខ្ញុំមកដល់ព្រះវិហារហើយ បានអាមេរិកាំងផ្សាយហ្នឹង។ ខ្ញុំមកដល់ព្រះវិហារហើយ បានខ្ញុំមកជួបគ្នាក្នុងព្រះវិហារហើយ កាលដែលផ្សាយហ្នឹង គឺផ្សាយថ្ងៃ តាសឿង មកជួបខ្ញុំ

ហ្នឹង។ មិនមែននៅសៀមរាបទេ នៅព្រះវិហារ តើ។

**ស៖** ខ្ញុំយល់ចំណុចនេះ ខ្ញុំចង់ដឹងទៀតថា បន្ទាប់ពីលោកស្ដាប់នុំងហើយនោះ តើប៉ុន្មាន ពេលប៉ុន្មានបន្ទាប់ពីហ្នឹងដែលលោកចាកចេញពីព្រះវិហារ?

**ឆ៖** បាទ ពេលដែលស្ដាប់បានព័ត៌មានហ្នឹងហើយ តាសឿង គាត់មកសៀមរាបវិញ ហើយខ្ញុំនៅត្រឹមព្រះវិហារនៅឡើយ។ ខ្ញុំមិនទាន់មានចាកចេញឯណា។ តាសឿង គាត់មកម្នាក់គាត់តើ មកសៀមរាបតើបាទ។

[១៤:៣៦:២៤]

**ស៖** កាលពីម្សិលមិញ នៅពេលដែលលោកឆ្លើយទៅនឹងសំណួររបស់ចៅក្រម ឡាវែន៍ ហើយនិងសំណួររបស់មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី លោកបានឆ្លើយថា "លោករក្សាចម្លើយមុនៗរបស់លោកគឺថាលោកមិនដែលធ្លាប់ឃើញ នួន ជា ឬ ខៀវ សំផន ក្នុងអំឡុងពេលដែលលោកស្នាក់នៅព្រះវិហារនោះទេ"។ ប្រសិនបើខ្ញុំស្ដាប់មិនច្រឡំទេ ក្នុងអំឡុងពេលដែលលោកបំពេញមុខងារនៅតំបន់១០៣ ថ្នាក់លើតែម្នាក់គត់ដែលលោកបានជួបនោះ គឺ តាសឿង តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ មានតែ តាសឿង ម្នាក់ហ្នឹង។

**ស៖** ឥឡូវនេះ ខ្ញុំចូលទៅចំណុចមួយផ្សេងទៀត ក៏ប៉ុន្តែពាក់ព័ន្ធទៅនឹងតំបន់១០៣ដដែល។ តើលោកអាចបញ្ជាក់បានទេថា តំបន់១០៣នេះស្ថិតនៅក្នុងភូមិភាគឧត្ដរថ្មី តើអ៊ីចឹងមែនទេ?

**ឆ៖** ខ្ញុំមិនដឹងថា -- កាលណោះ ខ្ញុំមិនដឹងថា ភូមិភាគឧត្ដរថ្មី មិនបានដឹងទេ។ ខ្ញុំប្រាប់ថា តំបន់នុំង តំបន់ស្វយ័ត។ តែក្នុងភូមិភាគឧត្ដរ ខ្ញុំមិនបានបញ្ជាក់ថា ភូមិភាគឧត្ដរ។ ហើយដឹងថា តំបន់ស្វយ័តគ្រប់គ្រងដោយលោក នួន ជា, ខៀវ សំផន។ ដូច្នេះក្នុងតំបន់ភូមិភាគឧត្ដរនោះ ខ្ញុំមិនបានដឹងថាយ៉ាងម៉េចទេ។ ខ្ញុំមិនបាន -- មិនច្បាស់កន្លែងត្រង់ហ្នឹងទេ។

[១៤:៣៨:២២]

**កញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំនឹងដក -- លោកប្រធាន ខ្ញុំមិនដឹងថា តើលោកប្រធានចង់ឈប់សម្រាក ឬក៏អនុញ្ញាតឲ្យខ្ញុំបន្តបង្ហាញនូវឯកសារជូនសាក្សី។ ដូច្នេះ តើខ្ញុំបន្តទៀត ឬក៏ត្រូវឈប់សម្រាកសិនលោកប្រធាន?

**ប្រធានអង្គជំនុំ៖**

៥មីនុតទៀត!

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ ដូច្នេះ ខ្ញុំសូមការអនុញ្ញាតពីលោកប្រធាន ដើម្បីបង្ហាញជូនសាក្សី នូវចម្លើយរបស់គាត់ គឺសំណួរចម្លើយលេខ១០ គឺឯកសារ E3/424 ដដែល។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** នេះជាចម្លើយដែលលោកបានឆ្លើយជូនអ្នកស៊ើបអង្កេត នៃការិយាល័យសហចៅក្រមស៊ើបអង្កេត។ អ្នកស៊ើបបានសួរលោកថា "ហេតុអ្វីបានជាលោកត្រូវថ្នាក់លើត្រូវផ្លាស់ឲ្យទៅខេត្តព្រះវិហារ?"។ លោកបានឆ្លើយថា "ដោយសារនៅតំបន់ព្រះវិហារ ជាតំបន់ស្វយ័ត ដែលគ្រប់គ្រងដោយមជ្ឈិមផ្ទាល់ មានតា នួន ជា និងតា ខៀវ សំផន គាត់ចុះផ្ទាល់ទៅតំបន់នោះ"។ នៅពេលដែលលោកឆ្លើយទៅនឹងសំណួររបស់សហព្រះរាជអាជ្ញា លោកថាមូលហេតុដែលលោកដឹងថាតា នួន ជា និង តា ខៀវ សំផន ចុះទៅតំបន់នោះ គឺថាលោកបានឃើញរូបថតរបស់ពួកគាត់នៅក្នុងមន្ទីរទូរលេខ។ តើលោកពិតជាបានឆ្លើយអ៊ីចឹងមែនទេ នៅក្នុងសវនាការនេះ?

**ឆ៖** បាទ ឃើញរូបថតគាត់នៅនឹងដី មិនមែននៅទូរលេខទេ។ រូបថតគាត់ហ្នឹង គាត់ធ្លាក់ពីជញ្ជាំងអីមករាត់រាយនៅដី។ ឯនៅកន្លែងមន្ទីរទន្លាប់ឯណោះទេ មិនមែននៅកន្លែងស្រុករវៀងទេ។ ជារូបថតរបស់ផងគាត់បាទ។ អ៊ីចឹងមែន រូបថតហ្នឹង។

**ស៖** ដូច្នេះ ខ្ញុំសូមបញ្ចប់ត្រឹមចំណុចនេះ ខ្ញុំ -- ប៉ុន្តែគឺថាមិនមែននៅក្នុងមន្ទីររបស់ អើយ និង អុល ទេ មែនទេ ដែលលោកឃើញរូបថតរបស់ ខៀវ សំផន និង នួន ជា នោះ?

[១៤:៤១:១៧]

**ឆ៖** បាទ នៅក្នុងមន្ទីរទន្លាប់ហ្នឹង ប៉ុន្តែ អើយ ហើយ អុល គាត់ចេញហើយ គាត់មិននៅហ្នឹងទៀតទេ។ កន្លែងហ្នឹងនៅគ្មានមនុស្សនៅទៀតទេ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកមេធាវី។ អរគុណសាក្សី។ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់សាក្សី និងមេធាវីប្រឹក្សារបស់គាត់ ហើយនិងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មនេះវិញនៅ

វេលាម៉ោងបី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៤២នាទី ដល់ម៉ោង ១៥:១១ នាទី)*

[១៥:១១:១២]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅមេធាវីអន្តរជាតិ ការពារក្តី ខៀវ សំផន ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

សូមអញ្ជើញ!

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** លោក មាស វឿន ឥឡូវយើងត្រឡប់ចូលមកបន្តទៅទៀត។ យើងនឹងត្រឡប់មកនិយាយអំពីតំបន់១០៣ វិញ ក៏ប៉ុន្តែមុននេះ ខ្ញុំចង់និយាយអំពីចំណុចមួយដែលខ្ញុំដូចជាមិនសូវយល់ច្បាស់។ នៅពេលដែលលោកនិយាយអំពីពេលដែល តាសឿង មកជួបលោកជាលើកទី២នៅព្រះវិហារ។ លោកបានពន្យល់ថា លើកទី១ គឺនៅពេលដែលគាត់នាំលោកមកពីដំបូង ហើយបន្ទាប់មកទៀត លើកទី២ ១សប្តាហ៍ក្រោយមកទៀត គាត់មកលើកទី២។ បន្ទាប់មកនៅពេលដែលខ្ញុំរំឭកអំពីចម្លើយរបស់លោកកាលពីម្សិលមិញ ពេលដែលលោកឆ្លើយទៅចៅក្រម ឡាវែន៍ អំពីវត្តមានរបស់គាត់ នៅពេលដែលវៀតណាមវ៉ៃចូលភ្នំពេញ លោកប្រាប់ថា លោកមិនចាំកាលបរិច្ឆេទច្បាស់លាស់។

[១៥:១២:៥៥]

ឥឡូវនេះ ខ្ញុំចង់ឲ្យលោកចងចាំឡើងវិញ ដោយអានផ្នែកមួយនៃចម្លើយរបស់លោកកាលពីម្សិលមិញ គឺសវនាការថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១២ គឺចន្លោះម៉ោង ០២:៣៨:០០ ទៅដល់ម៉ោង ០២:៣៩:០០

នាទី។ លោក មាស វឿន “តើលោកដឹងទេថា កងទ័ពយួន វ៉ៃចូលភ្នំពេញនៅពេលណា?” នេះជាសំណួរ ហើយបន្ទាប់មក លោកក៏បានឆ្លើយថា “កាលនោះ ខ្ញុំមិនបានដឹងថា វៀតណាមវ៉ៃចូលភ្នំពេញថ្ងៃប៉ុន្មាននោះទេ ក៏ប៉ុន្តែខ្ញុំបានបើកវិទ្យុស្ដាប់ ហើយប្រាប់ថា ថ្ងៃ០៦ មករា វៀតណាម វ៉ៃចូលភ្នំពេញ។ ពេលនុំង តាសឿង គាត់ដេកជាមួយខ្ញុំ ហើយខ្ញុំប្រាប់គាត់ថា បង វៀតណាមវ៉ៃចូលភ្នំពេញហើយ” សូមបញ្ចប់ការដកស្រង់។ ដូច្នេះ ម្សិលមិញនេះ គឺថាច្បាស់ណាស់។ លោកឆ្លើយថា “តាសឿង បានដេកជាមួយលោកមួយយប់ គឺថានៅពេលដែលវៀតណាមវ៉ៃចូលភ្នំពេញ”។ តើលោកនៅរក្សាចម្លើយត្រង់ចំណុចនេះទេ?

**លោក មាស វឿន៖**

**ឆ៖** បាទ ចម្លើយពីខ្ញុំមុន ខ្ញុំឆ្លើយអ៊ីចឹងហើយ ប៉ុន្តែមកដល់ដំណាក់ទី២ ខ្ញុំប្រហែលជាច្រឡំអាចម្លើយដែលសួរពីសៀមរាបមកព្រះវិហារ ហើយពីព្រះវិហារមកសៀមរាប។ ត្រង់ហ្នឹង ខ្ញុំច្រឡំចម្លើយហ្នឹងហើយ ព្រោះខ្ញុំពេលលោកសួរពីៗព្រះវិហារមកសៀមរាប។ អាហ្នឹងយើងឃើញថា ខ្ញុំប្រហែលជាច្រឡំចម្លើយនោះ ប៉ុន្តែរក្សាអាចម្លើយដែលខ្ញុំឆ្លើយពីវៀតណាមវ៉ៃចូលភ្នំពេញនោះ។ អាហ្នឹងខ្ញុំរក្សាចម្លើយហ្នឹងទុក។ ប៉ុន្តែអាចម្លើយដែលខ្ញុំឆ្លើយ ប្រហែលជាខ្ញុំច្រឡំអាចម្លើយហ្នឹង ហើយនិងសំណួរលោកសួរអម្បាញ់មិញហ្នឹង។

[១៥:១៥:១៤]

**ស៖** សូមអរគុណ។ សំណួររបស់ខ្ញុំគឺ ខ្ញុំចង់ដឹងថា តើនៅពេលលើកទី២ ឬក៏លើកទី៣ ដែលតាសឿង ជួបលោក ពេលដែលវៀតណាមវ៉ៃចូលហ្នឹង ពេលដែលគាត់ជួបលោកលើកទី២ ឬក៏លើកទី៣? ប្រសិនបើខ្ញុំសរុបឲ្យមើលឲ្យច្បាស់ទៅ គឺថាគាត់ជូនដំណើរលោកទៅព្រះវិហារដើម្បីឲ្យលោកចាត់ចែងការងារ ហើយបន្ទាប់មកទៀតមក មួយអាទិត្យក្រោយមកទៀត គាត់ក៏មកជួបលោកម្ដងទៀត។ គឺប្រហែលជានៅចន្លោះខែសីហា ខែកញ្ញា ឆ្នាំ៧៨។ ហើយប្រសិនបើពេលវិទ្យុអាមេរិកផ្សាយពីការវ៉ៃចូលភ្នំពេញរបស់វៀតណាមគាត់នៅជាមួយដែរ លោកដែរហ្នឹង ហ្នឹងមានន័យថាគាត់មកជួបលោកបីដងហើយ។ អ៊ីចឹងតើលោកអាចគិតមើលឡើងវិញមើល៍ តើលោកនៅចងចាំទេ គាត់បានមកជួបលោកបីដងមែនទេ?

[១៥:១៦:១២]

**ឆ៖** បាទ សំណួរហ្នឹងខ្ញុំច្រឡំ សំណួរពីវៀតណាមវ៉ៃហ្នឹងមួយ ហើយមកកណ្ដាល។ ហើយ

ខ្ញុំជម្រាបសាថ្មី។ លើកទី១ គាត់ -- ខ្ញុំមកដល់សៀមរាប គាត់ជូនខ្ញុំម្តង មកដល់ព្រះវិហារ ហើយគាត់អត់បានសម្រាកទេ គាត់ទៅវិញ។ ឯលើកទី២ បានគាត់មកម្តងទៀត ៗក្នុងពេលហ្នឹងហើយ ដែលខ្ញុំបានរាយការណ៍ អ៎! បានទទួលសារប្រាប់គាត់ពី លោក ខៀវ សំផន ប្រាប់ខ្ញុំហ្នឹង ហើយគាត់អត់ៗបានដេកទេដែរថ្ងៃហ្នឹង។ ហើយនិងគាត់ត្រឡប់ទៅវិញ ត្រឡប់ទៅលើកទី២។ បាទ ខ្ញុំច្រឡំអាហ្នឹងៗលើកទី២ អ៊ីចឹងហើយ លើកទី៣ អ៊ីចឹងហើយ។ ដល់លើកទី៣ ចុងក្រោយនេះ អាលើកទី៣ ចុងក្រោយនេះៗបានជា គាត់បានដេកមួយយប់។ អាហ្នឹងខ្ញុំច្រឡំអាសំណួរពីរហ្នឹង អាពីរកណ្តាល ហើយនិងអាខាងចុងបាទ។

**ស៖** សាក្សីការបញ្ជាក់របស់លោកនេះ ពិតជាមានប្រយោជន៍ខ្លាំងណាស់។ ឥឡូវនេះ ខ្ញុំចូលទៅនិយាយអំពីឋានៈនៃតំបន់១០៣ ជាកន្លែងដែលលោកនៅតាំងពីខែសីហា ឆ្នាំ៧៨ រហូតដល់ពេលវៀត-ណាមវ៉ៃចូល។ នៅពេលដែលលោកឆ្លើយទៅនឹងសហព្រះរាជអាជ្ញាអន្តរជាតិ ពេលដែលគាត់សួរលោកថាហេតុអ្វីបានជាតំបន់១០៣ ជាតំបន់ស្វយ័តក្រោយការដឹកនាំផ្ទាល់របស់ ខៀវ សំផន គឺជាសំណួររបស់សហព្រះរាជអាជ្ញា។ “បើតាមការយល់របស់លោក ថាតើ ខៀវ សំផន មានតួនាទីអ្វីដែរនៅពេលនោះ” ពេលសហព្រះរាជអាជ្ញាសួរលោក, លោកក៏បានឆ្លើយថា “តាមខ្ញុំដឹងតំបន់១០៣ ហ្នឹង គឺគាត់ទទួលគ្រប់គ្រងតំបន់១០៣ តាមឮប្រជាជនប្រាប់ខ្ញុំថា តំបន់ស្វយ័តនោះ តំបន់ហ្នឹងគេហៅថា តំបន់ស្វយ័ត ហើយតំបន់ហ្នឹងត្រូវរាយការណ៍ផ្ទាល់ទៅ ខៀវ សំផន។ កាលនុ៎ង គេហៅ ខៀវ សំផន ថាអ៊ំខៀវ សំផន។ ហើយបន្ទាប់មកទៀត សវនាការថ្ងៃទី០៤ តុលា នៅចន្លោះម៉ោងដប់បួន នៅចន្លោះម៉ោងប្រហែលជាម៉ោងពីរ លោកបានឆ្លើយថា “តំបន់ហ្នឹងស្វយ័ត ពីព្រោះថាដឹកនាំដោយ ខៀវ សំផន”។ នេះគឺជាចម្លើយរបស់លោកកាលពីថ្ងៃទី០៤ តុលា។ លោកឆ្លើយថា “បាទ ប្រជាជនធម្មតា ហើយអ្នកខ្លះនៅឈឺក្នុងមន្ទីរពេទ្យ ហើយចួនកាលប្រធានមន្ទីរពេទ្យគាត់ប្រាប់ដែរ ប៉ុន្តែខ្ញុំអត់ចាំឈ្មោះប្រធានមន្ទីរពេទ្យនោះទេ”។ សំណួរខ្ញុំៗ ចង់ដឹងថា ក្រៅពីប្រជាជនធម្មតានោះ តើមានអ្នកណាខ្លះផ្សេងទៀត ដែលប្រាប់លោកថា តំបន់១០៣ ស្ថិតនៅក្រោយការគ្រប់គ្រងរបស់ ខៀវ សំផន?

[១៥:១៩:៤៧]

**ផ៖** បាទ--

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប។ សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

[១៥:២០:០០]

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកចៅក្រម ខ្ញុំព្យាមមិនជំទាស់ទេ ក៏ប៉ុន្តែសហមេធាវី គឺនៅតែដកស្រង់ចេញពីប្រតិចារឹក ដោយជ្រើសរើសចំណុចមួយចំនួនតែប៉ុណ្ណោះ។ ចំណុចនេះគឺថា ខ្ញុំមិនចង់ជ្រៀតជ្រែកក្នុងការនាំមុខសាក្សីនោះទេ។ ដូច្នេះហើយគឺថា មេធាវីគួរតែអនុវត្តដូចគ្នា។ អ្វីដែលមេធាវីលើកឡើងនោះ គឺថាអង្គហេតុមួយចំនួនដែលវាមិនពេញលេញ។ សាក្សីបានលើកឡើងប្រភពព័ត៌មានមួយចំនួនរួចមកហើយ ហើយយើងអាចយល់តាមសំណួររបស់មេធាវីនេះ គឺថាមេធាវីគាត់ព្យាយាមឱ្យសំណួរទៅកាន់សាក្សី ហើយដោយលើកប្រភពមួយចំនួនឱ្យសាក្សីឆ្លើយតាម។ ដូច្នេះហើយ គឺវាមិនត្រឹមត្រូវនោះទេ។ ប្រតិចារឹកទំព័រ៨៥ ជាភាសាអង់គ្លេស ប្រតិចារឹកព្រាងនេះ គឺថាប្រហែលជាលើកឡើងនៅម៉ោងបីដប់ប្រាំនាទីពេលរសៀល ដែលក្នុងនោះមានការណែនាំមួយចំនួនដែលអង្គជំនុំជម្រះបានលើកឡើង។ ដូច្នេះហើយគឺថា ខ្ញុំស្នើសុំឱ្យមេធាវីនេះ កុំឱ្យមានការនាំមុខទៅកាន់សាក្សីចំពោះភស្តុតាដែលគាត់ចង់ចោទសួរ។

**កញ្ញា អង់តា ហ្គីសសេ៖**

*(គ្មានការបកប្រែ)*

[១៥:២១:២១]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញសហមេធាវីជាតិ មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

**លោក ពេជ អង្គ៖**

បាទ សូមអរគុណលោកប្រធាន។ សូមគោរពលោកលោកប្រធាន លោក លោកស្រីចៅក្រម និងភាគីសាធារណជនសាជាថ្មី។ សំណួរនេះ គឺជាសំណួរច្រំដែល សាក្សីបានឆ្លើយរួចហើយអំពីអ្នកណាខ្លះដែលផ្តល់ព័ត៌មានពាក់ព័ន្ធទៅនឹងអ្នកៗអំពីបញ្ហាលោក ខៀវ សំផន ទំនាក់ទំនងរបស់គាត់ជាមួយនឹងតំបន់១០៣។ ដោយនិយាយថា រហូតទៅដល់ប្រធានមន្ទីរពេទ្យក៏បានផ្តល់ព័ត៌មានទៅដល់គាត់ដែរ។

សូមអរគុណលោកប្រធាន។ នេះជាសំណួរច្រំដែល។

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំសូមឆ្លើយតបដោយខ្លី។ ការសួរចម្លើយ -- ការសួរសំណួរទាំងស្រុងរបស់ខ្ញុំ គឺផ្អែកទៅលើតម្រូវការ សូមឱ្យមានការបំភ្លឺលោកចំណុចមួយចំនួន។ ដូច្នេះ ជាការយល់ខុសហើយដែល

បញ្ជាក់ថា ខ្ញុំព្យាយាមធ្វើឲ្យសាក្សីយល់ខុស ពាក់ព័ន្ធទៅនឹងសម្រង់ដែលខ្ញុំធ្វើនោះ គឺខ្ញុំដកចេញនូវសម្ដីផ្ទាល់របស់សាក្សីតែម្ដងនៅក្នុងប្រតិចារឹក។ ប្រសិនបើសាក្សីចង់បញ្ជាក់បន្ថែម គាត់អាចបញ្ជាក់បន្ថែមបាន ប៉ុន្តែទាំងអស់នេះ គឺជាចម្លើយរបស់គាត់ផ្ទាល់។ ខ្ញុំសូមបន្ថយល្បឿនបន្តិច ពីព្រោះថានៅពេលខ្ញុំនិយាយលឿនពេកទៅអាចមានបញ្ហា។

ដូច្នេះ ខ្ញុំសូមបញ្ជាក់ជូនលោកប្រធានថា ខ្ញុំគ្រាន់តែដកស្រង់នូវសម្ដីរបស់សាក្សីដែលបានឆ្លើយនៅក្នុងសវនាការ ដែលយើងទាំងអស់គ្នាបានចូលរួម ហើយខ្ញុំមិនបានព្យាយាមឲ្យសាក្សីយល់ខុសអ្វីនោះទេ។ ខ្ញុំតែងតែផ្ដល់ឱកាសឲ្យគាត់ក្នុងការគាត់ពន្យល់ ឬក៏បំភ្លឺបន្ថែមនូវចំណុចណាមួយដែលខ្ញុំមិនសូវយល់ច្បាស់។ នេះជាទម្លាប់ធ្វើរបស់ៗខ្ញុំ។ ខ្ញុំមិនទាន់ចប់នូវខ្សែគំនិតរបស់ខ្ញុំទេ។ ខ្ញុំសួរសំណួរដំបូងៗហើយខ្ញុំបន្តទៅទៀត។ ដូច្នេះក្នុងករណីណាក៏ដោយ គឺខ្ញុំមិនធ្វើឲ្យសាក្សីមានការភ័ន្តច្រឡំនោះទេ។

ដូច្នេះ ខ្ញុំសូមការអនុញ្ញាតពីលោកប្រធាន ដើម្បីឲ្យខ្ញុំបន្តសួរសំណួរតទៅទៀត។

[១៥:២៣:៣០]

**ប្រធានអង្គជំនុំ៖**

សេចក្ដីជំទាស់ និងសំអាងហេតុនៃសេចក្ដីជំទាស់មិនសមស្រប។ អង្គជំនុំជម្រះត្រូវការស្ដាប់នៅចម្លើយតបរបស់សាក្សី ចំពោះសំណួរចុងក្រោយរបស់មេធាវីការពារក្ដីលោក ខៀវ សំផន។

សាក្សីឆ្លើយតបនឹងសំណួរចុងក្រោយអម្បាញ់មិញនេះ!

**លោក មាស វឿន៖**

**ឆ៖** សូមលោកបញ្ជាក់ម្ដងទៀត សំណួរ ខ្ញុំភ្លេច។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** មិនជាបញ្ហាអ្វីទេលោកសាក្សី ខ្ញុំអាចបញ្ជាក់ម្ដងទៀតបាន។ ខ្ញុំសួរលោកចង់ដឹងថា ក្រៅពីប្រជាជនធម្មតា ដែលលោកបានឆ្លើយកាលពីថ្ងៃទី០៤ តុលា នៅក្នុងសវនាការនេះ តើមានអ្នកណាខ្លះផ្សេងទៀត ដែលបានប្រាប់លោកថា តំបន់១០៣ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់លោក ខៀវ សំផន?

[១៥:២៤:២៩]

**ឆ៖** បាទ ក្នុងការដែលបញ្ជាក់ថា តំបន់ស្វយ័ត ការគ្រប់គ្រងរបស់លោក ខៀវ សំផន នោះប្រជាជនភាគច្រើន ដែលគាត់យល់ពីការគ្រប់គ្រងរបស់លោក ខៀវ សំផន នៅកន្លែងនោះមានមន្ទីរកន្លែងពេទ្យគាត់ប្រាប់ខ្ញុំដែរ។ ហើយមន្ទីរខាងស្រុកនៅខាងឆែប គាត់ប្រាប់ខ្ញុំដែរ ហើយនិងប្រជាជនខ្លះ

ដែលគាត់ចាស់ៗ ខ្ញុំសួរទៅក៏គាត់ប្រាប់ខ្ញុំដែរ។ ដូច្នេះ ក្នុងតំណាងដែលប្រាប់ហ្នឹងគឺ ទី១ ប្រជាជន, ទី២ គឺក្នុងមន្ទីរពេទ្យ ហើយទី៣ មានស្រុកខ្លះ ជាស្រុកឆែប គាត់ប្រាប់ខ្ញុំ។ ក្នុងឈ្មោះនោះ ខ្ញុំមិនដឹងមិនចាំឈ្មោះគាត់ទេ វាយូរហើយ គាត់ -- ខ្ញុំមិនអាចចាំឈ្មោះបានទេបាទ។

**ស៖** លោកសាក្សី លោកឆ្លើយសំណួរហើយ។ ខ្ញុំចង់សួរប៉ុន្តែលោក ដូចបានជាឆ្លើយទៅហើយ អ៊ីចឹងខ្ញុំបន្តទៅមុខទៀត។ តើលោកដឹងឈ្មោះបដិវត្តរបស់លោក ខៀវ សំផន ដែរឬទេ?

**ផ៖** បាទ ដឹងគេហៅឈ្មោះក្នុងបដិវត្តរបស់គាត់ ឈ្មោះ បងហែម។

[១៥:២៦:២២]

**ស៖** តើលោកដឹងទេថា នៅពេលណាដែរ ដែលគេហៅគាត់ថា បងហែម នោះ? ខ្ញុំសួរសំណួរបែបនេះ ពីព្រោះថា នៅក្នុងចម្លើយរបស់លោកនោះ លោកឆ្លើយថា “ប្រជាជននៅក្នុងតំបន់លោកហៅថា អ៊ំ ខៀវ សំផន”។ ដូច្នេះ ខ្ញុំចង់ដឹងថាតើនៅពេលណា ដែលគេហៅគាត់ថា បងហែម នោះ?

**ផ៖** ហៅ បងហែម ហ្នឹងគាត់តាំងពីឆ្នាំ១៩៦៧ មក។ គេហៅ បងហែម អ៊ីចឹង។

**ស៖** សូមអរគុណលោក មាស វឿន។ ដោយសារតែលោកលើកឡើងអំពីចម្លើយរបស់មនុស្សមួយចំនួនដែលបានប្រាប់លោកអំពីឋានៈរបស់ ខៀវ សំផន ហើយនិងឋានៈរបស់តំបន់១០៣។

**កញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំចង់សូមការអនុញ្ញាតពីលោកប្រធាន ដើម្បីផ្តល់ជូនដល់សាក្សីរូបនេះ នូវឯកសារមួយដែលជាចម្លើយរបស់សាក្សី TCW-548 ដែលឯកសារនេះត្រូវបានប្រើដោយសហព្រះរាជអាជ្ញារួចមកហើយកាលពីគាត់សួរសំណួរនោះ។ ដូច្នេះ ខ្ញុំចង់ឲ្យគាត់ពិនិត្យមើលឃ្លាមួយ។ ដូច្នេះ ខ្ញុំសូមការអនុញ្ញាតផ្តល់ឯកសារក្រដាសជូនដល់សាក្សី ពីព្រោះខ្ញុំមិនអាចសុំបញ្ចាំងលើអេក្រង់បានទេ ដោយសារតែបញ្ហារក្សាការសម្ងាត់ចំពោះសាក្សីរូបនេះ។ ដូច្នេះ សូមមន្ត្រីតុលាការជួយយកឯកសារជាក្រដាស ផ្តល់ជូនទៅដល់សាក្សីរូបនេះ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីមេធាវី យកជូនសាក្សីពិនិត្យ។

**កញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំសូមបញ្ជាក់ជូនភាគី និងសាក្សីថា ផ្នែកពាក់ព័ន្ធនៃឯកសារនេះគឺ សំណួរ-ចម្លើយទី១៥។

[១៥:២៨:៣៧]

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ខ្ញុំសូមរំឭកថា លោកសាក្សី សូមលោកកុំបញ្ជាក់ឈ្មោះសាក្សីរូបនេះ ដែលមាននៅក្នុងឯកសារនេះ ពីព្រោះថា យើងត្រូវការរក្សាការសម្ងាត់។ ខ្ញុំចង់ត្រឡប់មកនិយាយអំពី ពាក់ព័ន្ធនឹងតំបន់និងភូមិភាគឧត្តរថ្មី។ នៅក្នុងឯកសារនេះ គឺថានៅចម្លើយ សំណួរ-ចម្លើយ១៥ គឺមានសួរថា "តើភូមិភាគឧត្តរថ្មីមានតំបន់ប៉ុន្មាន? ហើយមានឈ្មោះអ្វីខ្លះ? ហើយមានស្រុកប៉ុន្មាន? មានឈ្មោះអ្វីខ្លះ?" លោកសាក្សីនោះ គាត់បានឆ្លើយថា "បើតាមខ្ញុំដឹង ភូមិភាគឧត្តរថ្មី មានតំបន់១០៣ តំបន់១០៦ និងតំបន់កំពង់ធំនៃភូមិភាគឧត្តរចាស់"។ សំណួររបស់ខ្ញុំគឺ ខ្ញុំចង់សួរលោកថា តើលោកមាននៅចងចាំអំពីតំបន់និងស្រុកនៃភូមិភាគឧត្តរថ្មី នៅសម័យនោះទេ?

**លោក មាស វឿន៖**

**ឆ៖** បាទ ការដែលខ្ញុំទៅដល់ហ្នឹង ខ្ញុំមិនបានដឹងថា ភូមិភាគឧត្តរមានប៉ុន្មានទេ។ ខ្ញុំមិនទាន់ចាំច្បាស់ មិនដឹងជាខេត្តណាខ្លះ ប៉ុន្តែដែលខ្ញុំទៅសំដៅហ្នឹង ដឹងថាខេត្តព្រះវិហារហ្នឹង ១០៣ហ្នឹង ដឹងថាតំបន់ស្វយ័ត ក៏ប៉ុន្តែនៅក្នុងភូមិភាគឧត្តរហ្នឹង ខ្ញុំមិនបានដឹងថាខេត្តណាទេ ព្រោះខ្ញុំទៅដំបូង។ អ៊ីចឹងខ្ញុំមិនបានចាំច្បាស់លាស់ផងបាទ។

**ស៖** សូមអរគុណ។

[១៥:៣០:៣០]

**កញ្ញា អង់តា ហ្គីសសេ៖**

ពាក់ព័ន្ធទៅនឹងបញ្ហានៃឋានៈតំបន់ស្វយ័ត១០៣។ ខ្ញុំសូមការអនុញ្ញាតពីលោកប្រធាន ដើម្បីផ្តល់ជូនសាក្សីនូវចម្លើយរបស់សាក្សី TCW-637 គឺឯកសារលេខ E3/425។ ដូចគ្នាដែរ ដើម្បីរក្សាការសម្ងាត់នោះ ខ្ញុំសូមផ្តល់ឯកសារជាក្រដាសជូនសាក្សីរូបនេះ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីមេធាវី យកជូនសាក្សីពិនិត្យ។

*(មន្ត្រីរដ្ឋបាលតុលាការយកឯកសារជូនសាក្សី)*

[១៥:៣១:២៩]

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ខ្ញុំសូមជម្រាបជូនសាក្សី ហើយនិងភាគីទាំងអស់ថា ផ្នែកដែលពាក់ព័ន្ធដែលខ្ញុំចង់បង្ហាញជូននោះ គឺចម្លើយ សំណួរ-ចម្លើយលេខ១ របស់សាក្សី TCW-637។ ចម្លើយទី១នេះ គឺវែងណាស់ដូច្នេះ គឺថាប្រហែលជានៅពាក់កណ្ដាលចម្លើយ។ គាត់បានឆ្លើយអំពីសកម្មភាពរបស់គាត់ ហើយគាត់ក៏បាននិយាយអំពីឋានៈនៃតំបន់១០៣។ គាត់បាននិយាយថា "ក្រោយមកតំបន់ស្វយ័ត១០៣ ត្រូវបានថ្នាក់លើបញ្ចូលទៅក្នុងភូមិភាគឧត្តរថ្មី នៅក្នុងអំឡុងឆ្នាំ១៩៧៧"។ លោកសាក្សី សាក្សីរូបនោះ គាត់ក៏រស់នៅព្រះវិហារដែរ ហើយគាត់ឆ្លើយថា "ភូមិភាគ -- សូមទោស គឺតំបន់១០៣ ជាតំបន់ស្វយ័ត ហើយនៅក្នុងឆ្នាំ១៩៧៧ ត្រូវបានថ្នាក់លើបញ្ចូលទៅក្នុងភូមិភាគឧត្តរថ្មី"។ លោកសាក្សី តើលោកនឹកឃើញទេអំពីស្ថានភាពបែបនេះដែលកើតមាននៅឆ្នាំ១៩៧៨ នោះ?

[១៥:៣៣:១៦]

**លោក មាស វឿន៖**

**ឆ៖** បាទ នេះខ្ញុំអត់បានដឹងដែរ ពេលគាត់ប្រកាសនេះ។ ហើយក៏ខ្ញុំមិនស្គាល់ឈ្មោះហ្នឹងផង។

**ស៖** ឥឡូវនេះ ខ្ញុំចង់ដឹងថា តើនៅក្នុងក្របខ័ណ្ឌនៃការប្រព្រឹត្តិទៅនៃតំបន់ នៃភូមិភាគ ហើយនិងការទំនាក់ទំនងគ្នារវាងមជ្ឈិមនោះ តើគេមានវិធានអ្វីខ្លះ ដើម្បីទាក់ទងគ្នាតាមទូរលេខនោះ?

**ឆ៖** នេះ ខ្ញុំមិនដឹងកិច្ចការងាររបស់គេនោះទេ ព្រោះខ្ញុំអត់បានដឹង។

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតផ្ដល់ជូនឯកសារចុងក្រោយ គឺធ្វើដូចឯកសារមុនពីរដែរគឺសូមការអនុញ្ញាតផ្ដល់ជូនសាក្សីរូបនេះនូវឯកសាររបស់សាក្សី TCW-695 ឯកសារលេខ E3/411។ ដូច្នេះខ្ញុំសូមការអនុញ្ញាតពីលោកប្រធាន ដើម្បីផ្ដល់ជូនឯកសារក្រដាសជូនសាក្សី។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីមេធាវីយកជូនសាក្សីពិនិត្យ!

**កញ្ញា អង់តា ហ្គីសសេ៖**

ដើម្បីឱ្យភាគទាំងអស់គ្នាបានយល់ច្បាស់នោះគឺ ឯកសារមួយនេះអត់មានដាក់លេខសំណួរចម្លើយទេ។ សូមអភ័យទោសលោកប្រធាន ខ្ញុំកំពុងតែពិនិត្យមើលលេខ ERN ដែលខ្ញុំភ្លេចដាក់ភ្ជាប់

ជាមួយនឹងឯកសារនេះ។ លោកប្រធានឥឡូវនេះខ្ញុំរកឃើញហើយ ERN ជាភាសាបារាំងគឺ 0424036, ERN ជាភាសាខ្មែរ 00373510, ERN ជាភាសាអង់គ្លេស 00390077។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** សម្រាប់ជាព័ត៌មានលោកសាក្សី ឯកសារនេះគឺជាចម្លើយរបស់សាក្សីមួយរូបដែលជាប្រធានផ្នែកទូរលេខ។ នៅក្នុងឯកសារនោះ គាត់ឆ្លើយថា "តំបន់នីមួយៗមានផ្នែកទូរលេខរៀងៗខ្លួន។ ប្រសិនបើតំបន់ចង់ផ្ញើទូរលេខចេញទៅតំបន់ផ្សេងទៀត សារនេះដំបូងឡើយត្រូវឆ្លងតាមភូមិភាគសិន"។ តើចម្លើយនេះធ្វើឲ្យលោកយល់ច្បាស់ទេ បើធៀបទៅនឹងកន្លែងដែលលោករស់នៅនោះ ឬមួយក៏អត់ លោកមិនដឹងអ្វីទេនៅពេលដែលស្តាប់នូវចម្លើយនេះរួចហើយនោះ?

[១៥:៣៦:៥២]

**លោក មាស វឿន៖**

**ឆ៖** បាទ អ៊ីចឹងមែន ត្រូវឆ្លងតាមភូមិភាគមែន។

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណចំពោះការឆ្លើយបញ្ជាក់នេះ។ លោកប្រធាន ខ្ញុំអស់សំណួរហើយ សូមបញ្ចប់ការសួរសំណួរត្រឹមនេះ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញ!

**កញ្ញា អង់តា ហ្គីសសេ៖**

បាទ លោកប្រធាន សហភាតារបស់ខ្ញុំ ថាខ្ញុំដូចជាមិនសូវសមរម្យទេ ដែលថាមិនបានប្រាប់ពី -- អរគុណដល់សាក្សី។ ដូច្នេះ ខ្ញុំតាំងនាមឲ្យក្រុមមេធាវី ខៀវ សំផន សូមអរគុណសាក្សីដែលបានផ្តល់ពេលវេលាឆ្លើយតប ហើយសូមឲ្យលោកត្រឡប់ទៅផ្ទះវិញប្រកបដោយសុវត្ថិភាព។

[១៥:៣៧:៥៥]

**ប្រធានអង្គជំនុំ៖**

លោក មាស វឿន ការស្តាប់សក្ខីកម្មរបស់លោករហូតដល់ពេលនេះបានចប់ហើយ។ ហើយវត្តមានរបស់លោកនៅ អ.វ.ត.ក នេះលែងមានភាពចាំបាច់ទៀតហើយ។ លោកអាចវិលត្រឡប់ទៅលំនៅដ្ឋានរបស់លោក ឬក៏គោលដៅដែលលោកមានបំណងចង់ទៅបានហើយ។ អង្គជំនុំជម្រះសូមថ្លែងអំណរ

គុណចំពោះលោកដែលបានអញ្ជើញមកផ្តល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះរយៈពេល៣ថ្ងៃកន្លងមកនេះ ប្រកបដោយការអត់ធ្មត់ ហើយនិងខិតខំអស់ពីសមត្ថភាព។ សក្ខីកម្មរបស់លោកនឹងអាចរួមវិភាគទានក្នុងការស្វែងរកការពិតនៃរឿងក្តីនេះ។ សូមលោក មាស វឿន ជួបតែសំណាងល្អ និងធ្វើដំណើរវិលត្រឡប់ទៅវិញប្រកបដោយសុវត្ថិភាព។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងមន្ត្រីនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនសាក្សីរូបនេះវិលត្រឡប់ទៅលំនៅដ្ឋានរបស់គាត់ ឬក៏ទីកន្លែងដែលជាគោលដៅដែលគាត់មានបំណងចង់ទៅ។

ហើយលោក មាស វឿន និងមេធាវីប្រឹក្សាសាក្សីអាចអញ្ជើញចាកចេញពីបន្ទប់សវនាការបានហើយ!

*(សាក្សីចាកចេញពីបន្ទប់សវនាការ)*

[១៥:៣៩:២១]

បាទ ជាសវនាការបន្តនេះ អង្គជំនុំជម្រះនឹងធ្វើនីតិវិធីនៃការអាននូវបណ្តាលកថាខណ្ឌមួយចំនួនដែលពាក់ព័ន្ធទៅនឹងអង្គហេតុនៃការសម្លាប់អតីតទាហាន និងមន្ត្រីរដ្ឋការរបប លន់ នល់ នៅទួលពោធិ៍ជ្រៃ ហើយការអនុវត្តនេះ គឺអនុវត្តតាមវិធាន៨៩ស្ទួន កថាខណ្ឌ១ នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឯកសារពាក់ព័ន្ធគឺ ដីកាដំណោះស្រាយ ឯកសារអនុស្សរណ: E163/5 ហើយឯកសារឧបសម្ព័ន្ធ E124/7.3។

នៅពេលនេះ អង្គជំនុំជម្រះចាត់តាំងលោកស្រី សែ កុលវុឌ្ឍី ដែលជាក្រឡាបញ្ជីសវនាការរបស់អង្គជំនុំជម្រះដំបូង ឡើងអាននូវកថាខណ្ឌមួយចំនួនដែលមាននៅក្នុងដីកាដំណោះស្រាយ ទាក់ទងទៅនឹងអង្គហេតុ ដូចបានជម្រាបជូនខាងលើ គឺអាននូវកថាខណ្ឌពី២០៥ ដល់ ២០៩ កថាខណ្ឌ៦៩៨ ដល់៧១១ កថាខណ្ឌ៩៧៥ ដល់៩៧៧, កថាខណ្ឌ១១០៥ ដល់ ១១១៣ និងពីកថាខណ្ឌ១១៩១ ដល់ ១១៩៣។

សូមអញ្ជើញលោកស្រី សែ កុលវុឌ្ឍី!

[១៥:៤១:១៥]

**ក្រឡាបញ្ជី៖**

ឃ) វិធានផ្សេងៗ ដែលបានធ្វើឡើងប្រឆាំងនឹងក្រុមជាក់លាក់នានា

កថាខណ្ឌ២០៥៖ គោលនយោបាយមួយនៅ ក្នុងចំណោមគោលនយោបាយទាំងប្រាំដែលត្រូវ

បានអនុវត្តសម្រេចបាន និងការពារបដិវត្តន៍សង្គមនិយម គឺដាក់ចេញរាល់វិធានការ ជាពិសេសប្រឆាំងនឹងក្រុមជាក់លាក់នានា។ សកម្មភាពនេះ បានប៉ះពាល់ដោយផ្ទាល់ ឬដោយប្រយោលដល់ក្រុមមនុស្សជាច្រើននៅក្នុងប្រទេសកម្ពុជានាសម័យនោះ។ សាលក្រមស៊ើបអង្កេត ត្រូវបានប្ដឹងអំពីអំពើទាក់ទងនឹងក្រុមជនជាតិចាម ជនជាតិវៀតណាម និងពុទ្ធសាសនិក ព្រមទាំងអតីតអ្នករដ្ឋការនៃរបបសាធារណខ្មែរ ដូចជា មន្ត្រីយោធា និងក្រុមគ្រួសាររបស់ពួក។ អំពើទាំងនេះ ត្រូវបានប្រព្រឹត្តដោយបក្សកុម្មុយនីស្តកម្ពុជានៅទីកន្លែងផ្សេងគ្នានៃប្រទេសកម្ពុជា ចាប់ពីមុនឆ្នាំ១៩៧៥ ដែលជាដំណាក់កាលដំបូងនៃការត្រួតត្រារបស់បក្សកុម្មុយនីស្តកម្ពុជាទៅលើទឹកដីមួយផ្នែក និងបន្តយ៉ាងហោចណាស់ រហូតដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩។

[១៥:៤២:២៣]

កថាខណ្ឌ២០៦៖ សហចៅក្រមស៊ើបអង្កេតត្រូវបានប្ដឹងអំពីអំពើនានា ដែលបានប្រព្រឹត្តប្រឆាំងនឹងជនជាតិចាម នៅក្នុងភូមិភាគកណ្ដាល ភូមិភាគបូព៌ា និងភូមិភាគពាយ័ព្យ ប្រឆាំងនឹងជនជាតិវៀតណាម នៅក្នុងខេត្តស្វាយរៀង និងខេត្តព្រៃវែង ភូមិភាគបូព៌ា និងក្នុងអំឡុងពេលនៃការចូលលុកលុយនៅប្រទេសវៀតណាម។ ការប្រឆាំងចំពោះពុទ្ធសាសនិកនៅទូទាំងកម្ពុជាប្រជាធិបតេយ្យ និងការប្រឆាំងនឹងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ក្នុងអំឡុងនៃការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ។ ព្រឹត្តិការណ៍ចុងក្រោយនេះ បង្កើតបានជាឧទាហរណ៍មួយក្នុងចំណោមឧទាហរណ៍យ៉ាងច្រើននៃអំពើប្រឆាំងទៅនឹងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ។

[១៥:៤៣:១៤]

កថាខណ្ឌ២០៧៖ គោលដៅមួយក្នុងចំណោមគោលដៅផ្សេងទៀត នៃគោលនយោបាយនេះ គឺការបង្កើតឡើងនៅសង្គមមួយដែលមិនមានសាសនា រួបរួមគ្នា ដោយមិនមានការបែងចែកវណ្ណៈ តាមរយៈការលុបបំបាត់ចោលភាពខុសគ្នារវាងជនជាតិ ជាតិ សាសនា សង្គម និងវប្បធម៌។ គោលដៅនេះត្រូវបានបញ្ជាក់ដោយឯកសាររបស់បក្ស ទាក់ទិននឹងវណ្ណៈ។ ក្នុងឆ្នាំ១៩៧៤ អត្ថបទមួយ និពន្ធដោយប៉ុល ពត ដែលបានផ្សព្វផ្សាយនៅក្នុងទស្សនាវដ្ដីទង់បដិវត្តបានបង្ហាញថា “មានវណ្ណៈពិសេសមួយនៅក្នុងសង្គមកម្ពុជាដែលរួមមាន៖ ទាហាន ប៉ូលិស និងលោកសង្ឃ”។ តាមរយៈសៀវភៅកំណត់ហេតុរបស់កម្មាភិបាល និងដោយបានយោងទៅតាមអត្ថបទខាងលើនេះ បញ្ជាក់ថា ជនជាតិភាគតិចទាំងអស់ក៏ត្រូវបានចាត់ទុកថា ជាផ្នែកនៃប្រភេទវណ្ណៈពិសេសនេះផងដែរ។ វណ្ណៈផ្សេងៗទៀត ដូចជា ពួកសក្តិ

ភូមិ ពួកនាយទុន និងពួកអភិជន ក៏ត្រូវបានគេហាមឃាត់ផងដែរ។ ក្នុងខែកញ្ញា ឆ្នាំ១៩៧៥ ការអនុវត្តគោលដៅនេះ មានការវិវត្តន៍ ទៅមុខ នៅពេលដែលបក្សកុម្មុយនីស្តកម្ពុជាបានប្រកាសពីការលុបបំបាត់វណ្ណៈទាំងនេះ និងវណ្ណៈដោយឡែកពិសេស ដោយបានបញ្ជាក់ថា គឺមានតែវណ្ណៈកម្មករ និងកសិកម្មប៉ុណ្ណោះ ដែលមានអត្ថិភាព ហើយថា វណ្ណៈទាំងអស់ដទៃទៀត ត្រូវបានរំលាយបញ្ចូលនៅក្នុងវណ្ណៈទាំងពីរនេះ។ នៅពេលនោះ រើសភ្លាមៗ បន្ទាប់ពីនោះមក វិទ្យុផ្សាយចេញពីទីក្រុងភ្នំពេញ បានធ្វើការបញ្ជាក់ចុងក្រោយអំពីព្រះសង្ឃ ជនជាតិចាម និងជនជាតិភាគតិចដទៃទៀត។ ទោះបីជារដ្ឋអំណាចបក្សជាន់ខ្ពស់បន្តនិយាយរហូតដល់ឆ្នាំ១៩៧៦ អំពីចំនួនប្រជាជនកម្ពុជាដែលរួមបញ្ចូលនូវអ្នកដែលមិនមែនជាសញ្ជាតិខ្មែរយ៉ាងណាក៏ដោយ បក្សកុម្មុយនីយកម្ពុជាបានប្រកាសជាផ្លូវការនៅខែសីហា ឆ្នាំ១៩៧៧ ថា "ការលុបបំបាត់ និងការដាក់បញ្ចូលគ្នានៃជនជាតិភាគតិចគឺដូចដែលយើងអាចនិយាយថា ជាប្រទេសមួយដែលមាន៩៩ ភាគរយ ខ្មែរ។ គោលដៅមួយនៃគោលនយោបាយនេះ គឺដើម្បីលុបបំបាត់ខ្លាំង និងដើម្បីបំផ្លាញទាំងស្រុង ឬមួយផ្នែកនៃក្រុមទាំងនោះតែម្តង"។ វិធានការដែលបានធ្វើឡើងប្រឆាំងនឹងក្រុមជាក់លាក់នានា គឺត្រូវបានយកចិត្តទុកដាក់ ជាពិសេសក្នុងកិច្ចប្រឹងប្រែងរបស់បក្សកុម្មុយនីស្តកម្ពុជាដែលថា "យើងខំធ្វើយ៉ាងម៉េចឲ្យតែចំណេញដល់បដិវត្តន៍"។

[១៥:៤៦:០៥]

<u>កាលបរិច្ឆេទ និងការចូលរួម</u>

កថាខណ្ឌ២០៨៖ វិធានការដែលបានធ្វើឡើងប្រឆាំងនឹងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ គឺកើតចេញពីគោលនយោបាយដែលមានមុនឆ្នាំ១៩៧៥ មកម្ល៉េះ។ ហើយបានបន្តយ៉ាងហោចណាស់រហូតដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩។ នាខែកុម្ភៈ ឆ្នាំ១៩៧៥ ការប្រកាសជាសាធារណៈអំពីចេតនាក្នុងការសម្លាប់ឥស្សរជនជាន់ខ្ពស់នៃរបបសាធារណរដ្ឋខ្មែរ បន្ទាប់ពីបានទទួលជ័យជម្នះត្រូវបានបន្តធ្វើបន្ទាប់ពីមានសេចក្តីសម្រេចសម្ងាត់មួយឲ្យសម្លាប់មន្ត្រីជាន់ខ្ពស់របស់របបសាធារណរដ្ឋខ្មែរ ដោយផ្អែកលើមូលដ្ឋានថា "គឺសម្រេចធ្វើម៉េចកុំឲ្យពួកហ្នឹង វាងើបឡើងប្រឆាំងបដិវត្តន៍បាន"។

កថាខណ្ឌ២០៩៖ ក្នុងពេលមានការជម្លៀសប្រជាជនពីទីក្រុងភ្នំពេញ អតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ជាពិសេសមន្ត្រីជាន់ខ្ពស់ត្រូវបានគេកំណត់មុខសញ្ញា ដើម្បីចាប់ខ្លួន និងសម្លាប់ចោល"។ ភស្តុតាងក៏បានបង្ហាញថា "ក្រុមនេះត្រូវបានគេកំណត់មុខសញ្ញាផងដែរ នៅពេលផ្លាស់ទីលំនៅរបស់ប្រជាជនពីទីប្រជុំជនផ្សេងៗ និងជាបន្តបន្ទាប់នៅទូទាំងប្រទេស។ ជាពិសេស នៅក្នុងភូមិភាគពាយ័ព្យ

និងភូមិភាគនិរតីដូចដែលបានលើកឡើងនៅក្នុងផ្នែកស្តីអំពីការកត់សម្គាល់ឃើញអំពីអង្គហេតុ នៃឧក្រិដ្ឋកម្មក្នុងដីកាដំណោះស្រាយនេះ”។

<u>កន្លែងសម្លាប់មនុស្សទួលពោធិ៍ជ្រៃ</u>

*<u>ទីតាំង និង ការបង្កើត</u>*

កថាខណ្ឌ៦៩៨៖ កន្លែងសម្លាប់មនុស្សទួលពោធិ៍ជ្រៃបានចាប់ផ្តើមដំណើរការនៅចុងខែមេសា ឆ្នាំ១៩៧៥ រហូតដល់អំឡុងឆ្នាំ១៩៧៧ តែពុំជាប់ជាប្រចាំទេ។ ហើយដែលអំឡុងពេលនោះ មានការសម្លាប់ជាទ្រង់ទ្រាយធំលើអតីតទាហាន និងប្រជាជនស៊ីវិលជាច្រើននាក់។

[១៥:៤៨:១៥]

កថាខណ្ឌ៦៩៩៖ ទួលពោធិ៍ជ្រៃមានទីតាំងស្ថិតនៅលើដីទួលមួយ នៅជិតត្រើយខាងលិចបឹងទន្លេសាប ក្បែរភូមិដីស្ងិត ឃុំស្រែស្តុក ស្រុកកណ្តៀង ខេត្តពោធិ៍សាត់។ យោងតាមប្រព័ន្ធ កំណត់ទីតាំងភូមិសាស្ត្ររដ្ឋបាលរបស់បក្សកុម្មុយនីស្តកម្ពុជា ទួលពោធិ៍ជ្រៃស្ថិតនៅក្នុងស្រុកកណ្តៀរតំបន់៧ នៃភូមិភាគពាយ័ព្យ។

កថាខណ្ឌ៧០០៖ កន្លែងសម្លាប់មនុស្សទួលពោធិ៍ជ្រៃ ជាអតីតបន្ទាយទាហាន លន់ នល់ ហៅថា “បន្ទាយភូមិពោធិ៍” នៅចម្ងាយប្រមាណប្រហែលជា៤គីឡូម៉ែត្រពីទួលពោធិ៍ជ្រៃមានបឹងមួយដែលជាទីកន្លែងសម្លាប់មនុស្សផងដែរ ដោយគេបានឃើញសាកសពត្រូវបានបោះចូលទៅក្នុងនោះ។

<u>ដំណើរការប្រព្រឹត្តទៅ</u>

*<u>រចនាសម្ព័ន្ធគ្រប់គ្រង និងបុគ្គលិក</u>*

កថាខណ្ឌ៧០១៖ មូល សម្បត្តិ ហៅ តាញឹម ហៅ រស់ ញឹម ហៅ មូល អ៊ុន ជាលេខាគណៈភូមិភាគពាយ័ព្យរហូតដល់មានការចាប់ខ្លួនគាត់ ដោយពួកកម្មាភិបាលមកពីភូមិភាគនិរតីនៅពាក់កណ្តាល ឆ្នាំ១៩៧៨ នៅពេលនោះ តាម៉ុក ឡើងធ្វើជាលេខាភូមិភាគពាយ័ព្យជំនួសគាត់។ គង់ សុផល ហៅ តាកឺ ជាអនុលេខាភូមិភាគពាយ័ព្យនេះ ហើយគាត់ត្រូវបានចាប់ខ្លួន និងបញ្ជូនទៅមន្ទីរស-២១ នៅក្នុងខែវិច្ឆិកា ឆ្នាំ១៩៧៨។

កថាខណ្ឌ៧០២៖ តាខ្លែង គឺជាមេបញ្ជាការកងពលភូមិភាគពាយ័ព្យដែលបានវាយយកខេត្តពោធិ៍សាត់។ ភី ជាលេខាស្រុកកណ្តៀង និង សាន ជាអនុលេខា។ ម៉ៅ ជាសមាជិកគណៈស្រុកកណ្តៀង។ សុត ហៅ កែ គឹមហួត ជាលេខាតំបន់លេខា៧ និង តួយ ជាអនុលេខា។ សុត ទំនងជាត្រូវ

បានចាប់ខ្លួន និងបញ្ជូនទៅមន្ទីរស-២១ នៅក្នុងខែកក្កដា ឆ្នាំ១៩៧៧ ហើយ តូយ ក៏ដូចគ្នាផងដែរ។

កថាខណ្ឌ៧០៣៖ យោងតាមសក្ខីកម្មជាច្រើននៅក្នុងឆ្នាំ១៩៧៦ មានការប្រជុំជាទៀងទាត់រវាងកម្មាភិបាលជាន់ខ្ពស់បក្សកុម្មុយនីស្តកម្ពុជាដែលក្នុងនោះមាន៖ លេខាគណៈភូមិភាគ គណៈតំបន់ គណៈស្រុក ព្រមទាំងមេកងតាមឃុំ និងប្រធានសហករណ៍ផងដែរ។ មានសាក្សីលើកឡើងថា នួន ជា បានកោះប្រជុំពីរ ឬបីលើក និងបានរៀបចំផែនការបោសសម្អាតខ្មាំងផ្ទៃក្នុង ដែលរួមមាន៖ ការដាក់ឈ្លបនៅតាមស្រុកដើម្បីឲ្យរាយការណ៍មកគណៈស្រុក និងគណៈតំបន់ជាដើម។ ផ្អែកលើរបាយការណ៍ទាំងនេះ គណៈតំបន់នឹងធ្វើការចាប់ខ្លួនមនុស្សនៅតាមស្រុក និងតាមឃុំ។ សក្ខីកម្មរបស់សាក្សីនោះ ក៏បានបញ្ជាក់ឡើងផងដែរ អំពីការចូលរួមដោយផ្ទាល់របស់ នួន ជា ក្នុងកិច្ចប្រជុំទាំងនោះ។

[១៥:៥១:២១]

<u>ការចាប់ ការបញ្ជូនខ្លួន និងការសម្លាប់នៅទួលពោធិ៍ជ្រៃ</u>

កថាខណ្ឌ៧០៤៖ កន្លែងសម្លាប់មនុស្សទួលពោធិ៍ជ្រៃបានដំណើរការចាប់ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៧ ហើយទំនងជាមានការសម្លាប់ចំនួនយ៉ាងច្រើនក្នុងអំឡុងពេលនោះ។

<u>អតីតមន្ត្រី និងអ្នករដ្ឋការនៃរបប លន់ នល់</u>

កថាខណ្ឌ៧០៥៖ បន្ទាប់ពីការដួលរលំទីក្រុងភ្នំពេញភ្លាម កម្មាភិបាល និងកងទ័ពបក្សកុម្មុយនីស្តកម្ពុជាបានវាយចូល និងកាន់កាប់ខេត្តពោធិ៍សាត់ និងតំបន់ជុំវិញទួលពោធិ៍ជ្រៃ។ ខេត្តពោធិ៍សាត់ត្រូវបានកាន់កាប់ទាំងស្រុងដោយកម្មាភិបាល និងកងទ័ពបក្សកុម្មុយនីស្តកម្ពុជា នៅថ្ងៃទី១៩ ខែមេសា ឆ្នាំ១៩៧៥ ហើយក្នុងប៉ុន្មានថ្ងៃភ្លាមៗបន្ទាប់ពីនោះ ក៏មានការកោះប្រជុំអភិបាលខេត្តពោធិ៍សាត់ ទាហាន អ្នករដ្ឋការនៃអតីតរដ្ឋាភិបាល លន់ នល់ នៅសាលាខេត្តពោធិ៍សាត់។

កម្មវត្ថុនៃកិច្ចប្រជុំនោះគឺ ការអញ្ជើញមកទទួលអង្គការនៅទួលពោធិ៍ជ្រៃ កងទ័ពបក្សកុម្មុយនីស្តកម្ពុជាត្រូវបានដាក់ពង្រាយនៅជុំវិញសាលាខេត្ត ដើម្បីកុំឲ្យអ្នកចូលរួមលួចរត់គេច។

[១៥:៥២:៤៤]

កថាខណ្ឌ៧០៦៖ សាក្សីបានបញ្ជាក់ថា អតីតមន្ត្រីរដ្ឋការទាំងអស់របស់របប លន់ នល់ ត្រូវបានកោះហៅឲ្យទៅប្រជុំ។

កថាខណ្ឌ៧០៧៖ អ្នកមានវត្តមាននៅក្នុងកិច្ចប្រជុំនោះមាន តាញឹម និង តាកន គណៈភូមិភាគពាយ័ព្យ និង តាសុត គណៈតំបន់៧។ ក្រៅពីនេះ តាតូយ ដែលជាអនុលេខាតំបន់៧ (លុប) ដែលជា

អនុលេខាស្រុកកណ្ដៀង និងតាម៉ៅ ដែលមកទីគណៈស្រុកកណ្ដៀងក៏មានវត្តមាននៅក្នុងពេលនោះដែរ។ អតីតកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា ម្នាក់បានលើកឡើងថា តាញឹម និង តាសុត បានដាក់បញ្ជាថា ពួកទាហាន និងប៉ូលិសជំនាន់ លន់ នល់ ឲ្យតែអ្នកណាមានពាក់ស័ក្តិត្រូវតែយកទៅសម្លាប់ចោលទាំងអស់ បើទុកពួកអ្នកទាំងនេះ អាចនឹងមានការរើបម្រះនៅថ្ងៃក្រោយ។ ដូច្នេះ ត្រូវតែសម្លាប់ចោលឲ្យអស់។ កងទ័ពដែលនាំយកទាហាន និងប៉ូលិសទាំងនោះទៅសម្លាប់ មានតែកងទ័ពភូមិភាគ និងកងទ័ពតំបន់ទេ។

[១៥:៥៣:៥៣]

កថាខណ្ឌ៧០៨៖ ជនរងគ្រោះគ្រប់គ្នាបានមកដល់សាលាខេត្តពោធិ៍សាត់ ដោយស្ម័គ្រចិត្ត មានការប៉ាន់ប្រមាណថា មានមនុស្សប្រហែល ៣.០០០នាក់ បានមកក្នុងបរិវេណសាលាខេត្ត ដើម្បីចូលរួមនៅក្នុងការប្រជុំ។

កថាខណ្ឌ៧០៩៖ ជនរងគ្រោះត្រូវបានកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា បំភាន់ដោយប្រាប់ថាពួកគេនឹងត្រូវយកទៅរៀនសូត្រ បន្ទាប់មកទើបអាចធ្វើសមាហរណកម្ម ចូលក្នុងជួរកងទ័ពជាមួយឋានន្តរស័ក្តិដដែល ឬខ្ពស់ជាង។ ដំណឹងនេះបានផ្សាយទៅកាន់ហ្វូងមនុស្ស តាមរយៈឧគ្ឃោសនាសព្ទ។ ហេតុដូចនេះ ហើយបានជាអតីតទាហាន និងអ្នករដ្ឋការ លន់ នល់ បានចាកចេញពីអង្គប្រជុំដោយក្តីរីករាយ និងគ្មានការព្រួយបារម្ភបន្ទាប់ពីស្តាប់ឮការសន្យានេះ។ ហើយពួកគេក៏ត្រូវបានប្រាប់ផងដែរថាពួកគេនឹងបានចូលគាល់សម្តេចព្រះ នរោត្តម សីហនុ បន្ទាប់មកជនរងគ្រោះត្រូវបានដឹកជញ្ជូនតាមឡានធំៗទៅកាន់បន្ទាយទាហាន នៅទីកន្លែងសម្លាប់ទួលពោធិ៍ជ្រៃ។ ឡាននីមួយមានផ្ទុកមនុស្សប្រហែលពី៣០ ទៅ៤០នាក់។ ពេលនោះមិនមានឡានគ្រប់គ្រាន់ ដើម្បីដឹកជញ្ជូនជនរងគ្រោះតែមួយជើងនោះទេដូច្នេះ គេត្រូវធ្វើការដឹកជញ្ជូនជាច្រើនជើង។ ប្រតិបត្តិការខាងលើត្រូវបានធ្វើដោយកងទ័ពវរៈតំបន់២០១ និងទាហានវរៈ២៤ របស់ភូមិភាគពាយ័ព្យ។ មានការលើកឡើងផងដែរ តាខ្លែង ក៏បានចូលរួមដោយផ្ទាល់ក្នុងប្រតិបត្តិការនេះ។

[១៥:៥៥:៣៦]

កថាខណ្ឌ៧១០៖ ជនរងគ្រោះត្រូវបានសម្លាប់ភ្លាមៗនៅពេលទៅដល់។ កងទ័ពបក្សកុម្មុយនីស្តកម្ពុជា បានចំណាយពេលពេញមួយថ្ងៃក្នុងការបាញ់សម្លាប់ជនរងគ្រោះ គឺតាំងពីពេលព្រឹករហូតដល់ពេលល្ងាច។

កថាខណ្ឌ៧១១៖ សាកសពជនរងគ្រោះត្រូវបានគេកប់នៅក្នុងរណ្ដៅរួមជាច្រើន ហើយរណ្ដៅនីមួយៗមានសាកសពជាច្រើន និងមានទំហំប្រហែលជា១០ម៉ែត្របួនជ្រុង។ គេបានប្រើប៊ុលដូស៊័រ ដើម្បីកប់សាកសពជនរងគ្រោះ ដែលគរជាគំនរលើគ្នា។ ឯកសណ្ឋានទាហាន លន់ នល់ ត្រូវបានគេរកឃើញនៅជិតរណ្ដៅសាកសពនោះ។ ជនរងគ្រោះត្រូវបានគេចងស្លាបសេក ដាក់ដៃទៅក្រោយ និងចង់ភ្ជាប់គ្នាជាជួរ។ សាកសពជនរងគ្រោះប្រឡាក់ទៅដោយឈាម និងមានស្នាមគ្រាប់ ដែលខ្លះត្រូវបាន ត្រូវបាញ់ចំក្បាល និងខ្លះទៀតចំដើមទ្រូង។ សាក្សីបានប៉ាន់ប្រមាណថា មានសាកសពជនរងគ្រោះប្រមាណជា ២.០០០ ទៅ ៣.០០០នាក់។

<u>ក្រុមមនុស្សជាក់លាក់ផ្សេងៗ</u>

កថាខណ្ឌ៨៧៥៖ តាមរយៈតួនាទី និងមុខងារផ្សេងៗ នៅក្នុងបក្សកុម្មុយនីស្តកម្ពុជា នួន ជា បានចូលរួមក្នុងវិធានការនានា ដែលកំណត់មុខសញ្ញាក្រុមជាក់លាក់មួយចំនួន។

កថាខណ្ឌ៨៧៦៖ ក្នុងឋានៈជាសមាជិកពេញសិទ្ធិ នៃគណៈមជ្ឈិម និងគណៈអចិន្ត្រៃយ៍ នួន ជា បានចូលរួមក្នុងការបង្កើតឯកសាររបស់បក្ស ចុះនៅខែកញ្ញា ឆ្នាំ១៩៧៥ ដែលកំណត់ថា មានវណ្ណៈតែមួយគត់ គឺវណ្ណកម្មករ និងកសិករ ហើយថា វណ្ណៈផ្សេងៗទៀតត្រូវតែបញ្ចូលទៅក្នុងវណ្ណៈទាំងពីរនេះ។

[១៥:៥៧:២៦]

<u>ការប្រព្រឹត្តលើអតីតមន្ត្រីរដ្ឋការរបបសាធារណរដ្ឋខ្មែរ</u>

កថាខណ្ឌ៨៧៧៖ ក្រុមមនុស្សនេះ ត្រូវបានកំណត់ជាគោលដៅជាក់លាក់នៅពេលដែល នួន ជា ជាអនុលេខាគណៈមជ្ឈិមបក្ស និងជាសមាជិកពេញសិទ្ធិគណៈអចិន្ត្រៃយ៍។ នៅក្នុងមហាសន្និបាតមួយនៅទីក្រុងភ្នំពេញ នាខែឧសភា ឆ្នាំ១៩៧៥ នួន ជា បានពន្យល់ថា អតីតទាហាន និងមន្ត្រីរដ្ឋការរបស់របប លន់ នល់ មិនឲ្យឋិតនៅក្នុងក្របខ័ណ្ឌកម្លាំងរបស់របបថ្មីទេ។ នៅក្នុងចម្លើយសារភាពមន្ទីរស-២១ និងដែលត្រូវបានបញ្ជូនទៅ នួន ជា យ៉ាងហោចណាស់ ក៏មានចម្លើយសារភាពរបស់មនុស្សម្នាក់ ក្នុងចំណោមនោះត្រូវបានគេជឿជាក់ថា ជាប្រជាជនថ្មីដែលបានបម្រើការឲ្យរបប លន់ នល់។ យ៉ាងហោចណាស់ នួន ជា បានទទួលទូរលេខមួយដែលកំណត់អតីតមន្ត្រីរបបសាធារណរដ្ឋខ្មែរ ថាជាខ្មាំង។

<u>ក្រុមនុស្សជាក់លាក់</u>

កថាខណ្ឌ១១០៥៖ តាមរយៈតួនាទីផ្សេងៗរបស់គាត់ នៅក្នុងបក្សកុម្មុយនីស្តកម្ពុជា អៀង សារី បានចូលរួមក្នុងសកម្មភាព ដែលកំណត់មុខសញ្ញាក្រុមជាក់លាក់មួយចំនួន។

កថាខណ្ឌ១១០៦៖ ក្នុងឋានៈជាសមាជិកពេញសិទ្ធិ នៃគណៈមជ្ឈិម និងគណៈអចិន្ត្រៃយ៍ អៀង សារី ប្រហែលជាបានចូលរួមបង្កើតឯកសារបក្ស ចុះខែកញ្ញា ឆ្នាំ១៩៧៥ ដែលបង្ហាញថា វណ្ណៈមានតែពីរទេគឺ កម្មករ និងកសិករ ហើយវណ្ណៈផ្សេងទៀត ត្រូវបានបញ្ចូលទៅក្នុងវណ្ណៈទាំងពីរនោះ។

[១៥:៥៩:១៣]

<u>ការប្រព្រឹត្តលើអតីតមន្ត្រីរដ្ឋការសាធារណរដ្ឋខ្មែរ</u>

កថាខណ្ឌ១១០៧៖ ក្រុមនេះត្រូវបានកំណត់ជាមុខសញ្ញាខណៈពេលដែល អៀង សារី មានឋានៈជាសមាជិកពេញសិទ្ធិ នៃគណៈអចិន្ត្រៃយ៍។

កថាខណ្ឌ១១០៨៖ វាមិនទំនងជាថា អៀង សារី បានចូលរួមដោយផ្ទាល់ក្នុងសមាជជាតិលើកទី២ របស់ហ្វុង នៅខែកុម្ភៈ ឆ្នាំ១៩៧៥ ដែលដឹកនាំដោយ ខៀវ សំផន ហើយនាពេលសមាជនោះ មានការទាមទារឲ្យសម្លាប់ជនក្បត់ប្រាំពីររូប ក្នុងទីក្រុងភ្នំពេញ។ ក៏ប៉ុន្តែក្នុងខែបន្ទាប់មកនៅឯពិធីជប់លៀងក្នុងទីក្រុងប៉េកាំង អៀង សារី បានពន្យល់អ្នកដែលចូលរួមថា "សមាជជាតិលើកទី២ ត្រូវបានរៀបចំឡើងនៅកម្ពុជានាពេលថ្មីៗនេះ"។ តាមរយៈនេះ អៀង សារី បានគាំទ្រការអំនាវពាវឲ្យមានការសម្លាប់ជនក្បត់ទាំងប្រាំពីររូបខាងលើ។

កថាខណ្ឌ១១០៩៖ តាមរយៈការទទួលទូរលេខ អៀង សារី បានដឹងអំពីការប្រហារជីវិតអតីតមន្ត្រី និងយោធារបស់របប លន់ នល់ នៅពាសពេញប្រទេសកម្ពុជា ដែលអ្នកទាំងនោះត្រូវបានចោទថាមាននិន្នាការជាមួយសកម្មភាពខ្មាំង។ ជាឧទាហរណ៍ក្នុងខែមីនា ឆ្នាំ១៩៧៨ អៀង សារី បានទទួលទូរលេខមួយ ដែលមានខ្លឹមសារថា "នៅរដូវប្រាំងនេះ ខ្មាំងដែលនៅសេសសល់ វាងើបក្បាលឡើងវិញ ហើយធ្វើសកម្មភាពប្រឆាំងយើងនៅតាមបណ្តាលការដ្ឋានផ្សេងៗ។ ពួកខ្មាំងនៅសេសសល់ទាំងនេះ វាទាក់ទងជាមួយនឹងពួកប៉ូលិស ទាហាន និងពួករដ្ឋការ។ ពួកទាំងនេះវាបន្លំធ្វើជាប្រជាជនថ្មី ក្រោយពីវាធ្វើសកម្មភាពប្រឆាំងយើង។ ទើបយើងស្គាល់មុខវាច្បាស់។ ទន្ទឹមនឹងនេះ យើងក៏បោសសំអាតវាជាខ្សែសង្វាក់។ មកដល់ថ្ងៃនេះ ពួកប៉ូលិស ទាហាន និងរដ្ឋការមួយចំនួនបានរត់បាត់ ក្រោយពីយើងបោសសំអាតចំនួនប្រមាណជាង២០ក្បាល និងមានវិធានការបន្តរកចាប់ខ្លួនពួកនេះតទៅទៀត"។

[១៦:០១:៣៣]

កថាខណ្ឌ១១១០៖ ក្នុងខែកញ្ញា ឆ្នាំ១៩៧៥ អៀង សារី បាននិយាយនៅក្នុងបទសម្ភាសន៍ថា មន្ត្រីរបប លន់ នល់ បានចូលរួមក្នុងការបង្កបង្កើនផលកសិកម្ម ហើយពួកគេត្រូវបានប្រើដោយរដ្ឋា

ភិបាលបក្សកុម្មុយនីស្តកម្ពុជានៅពេលអ្នកទាំងនោះស្មោះត្រង់។ ទាក់ទងនឹងវាសនានៃអតីតនាយករដ្ឋមន្ត្រី ឡុង បូរ៉េត។ អៀង សារី និយាយថា "ស្លាប់ ឬរស់គាត់គឺជាជនក្បត់ ហើយត្រូវបានកាត់ទោសដោយប្រជាជន និងសភា" ២ខែក្រោយមក ក្នុងខែវិច្ឆិកា ឆ្នាំ១៩៧៥ គាត់ទទួលស្គាល់នៅចំពោះមុខអ្នកកាសែតបរទេសថា ឡុង បូរ៉េត និងសិរិមតៈ ត្រូវបានសម្លាប់។

កថាខណ្ឌ១១១១៖ ក្នុងខែឧសភា ឆ្នាំ១៩៧៧ អៀង សារី បាននិយាយថា អតីតមន្ត្រីរបប លន់ នល់ ដែលជាឧក្រិដ្ឋជនដ៏គ្រោះថ្នាក់ត្រូវបានយកទៅកាត់ទោស។ ហើយគាត់ឲ្យដឹងថា អ្នកឯទៀតបានចូលរួមក្នុងមហាជនឥឡូវនេះ និងកំពុងធ្វើការតាមសហករណ៍នៅទូទាំងប្រទេសកម្ពុជា។ គាត់បានបដិសេធថា ពួកគេមិនត្រូវបានយកទៅដាក់នៅតាមមន្ទីរឃុំឃាំងនានាទេ។ គាត់បាននិយាយអំពីព្រឹត្តិ-ការណ៍មួយដែលបានជួបនៅពេលគាត់បានទៅពិនិត្យមើលសហករណ៍ថា កសិករម្នាក់ចង់សម្លាប់អតីតវរសេនីយ៍ត្រីម្នាក់ដែលបានធ្វើការនៅក្នុងសហករណ៍នោះដែរ។ ប៉ុន្តែជននោះត្រូវបានជួយជីវិតពីព្រោះគាត់បានកែខ្លួនបានល្អ បន្ទាប់ពីរំដោះរួចមក។

[១៦:០៣:១៩]

កថាខណ្ឌ១១១២៖ ក្នុងខែមេសា ឆ្នាំ១៩៧៨ អៀង សារី បានសរសេរសំបុត្រមួយច្បាប់ផ្ញើឲ្យអគ្គលេខាអង្គការសហប្រជាជាតិ ដែលក្នុងនោះគាត់បាននិយាយថា អតីតមន្ត្រីរដ្ឋការរបស់រដ្ឋាភិបាលមុន កំពុងតែធ្វើការជាមួយប្រជាជននៅតាមសហករណ៍នានា ហើយគ្រប់គ្នាមានសិទ្ធិស្មើៗគ្នា។

កថាខណ្ឌ១១១៣៖ ក្នុងខែធ្នូ ឆ្នាំ១៩៩៦ អៀង សារី បាននិយាយនៅក្នុងបទសម្ភាសន៍មួយថា គាត់មិនបានដឹងឮអ្វីទាំងអស់អំពីផែនការសម្លាប់ទាហាន ព្រមទាំងមន្ត្រីរដ្ឋការ លន់ នល់ ទេក្នុងអំឡុងពេលមានការជម្លៀសអ្នកទាំងនោះចេញពីភ្នំពេញ។ គាត់បាននិយាយថា សេចក្តីសម្រេចប្រហារជីវិតមន្ត្រីទាំងនោះ ត្រូវបានអនុវត្តក្នុងអំឡុងថ្ងៃទី២០ ខែមេសា ឆ្នាំ១៩៧៥ ដែលនៅពេលនោះ គាត់មិនមានវត្តមាននៅក្នុងប្រទេសកម្ពុជាទេ។ គាត់បាននិយាយផងដែរថា សេចក្តីសម្រេចក្នុងការប្រហារជីវិតក្រុមមនុស្សទាំងនោះ ព្រមទាំងជម្លៀសប្រជាជនចេញពីទីក្រុង គឺដោយសារតែគេបានរកឃើញថា មានអាវុធនៅក្នុងផ្ទះមន្ត្រីយោធាទាំងនោះ ដែលមានការលើកឡើងថា ពួកនោះកំពុងរៀបចំធ្វើរដ្ឋប្រហារ។

<u>ក្រុមមនុស្សជាក់លាក់ផ្សេង</u>

កថាខណ្ឌ១១៩១៖ តាមរយៈតួនាទីផ្សេងៗនៅក្នុងបក្សកុម្មុយនីស្តកម្ពុជា ខៀវ សំផន បានចូលរួមនៅក្នុងសកម្មភាពកំណត់មុខសញ្ញាក្រុមជាក់លាក់ផ្សេងៗ។

កថាខណ្ឌ១១៩២៖ ក្នុងនាមជាសមាជិកគណៈមជ្ឈិម ខៀវ សំផន អាចបានចូលរួមនៅក្នុងការបង្កើតឯកសារបក្សនៅខែកញ្ញា ឆ្នាំ១៩៧៥ ដែលបានបញ្ជាក់យ៉ាងច្បាស់ថា មាននៅសល់តែវណ្ណៈកម្មករ និងកសិករប៉ុណ្ណោះ ហើយថាវណ្ណៈផ្សេងទៀតត្រូវបានរំលាយចូលទៅក្នុងវណ្ណៈទាំងពីរនេះ។ ដូច្នេះ នៅចុងឆ្នាំ១៩៧៥ ខៀវ សំផន បានពន្យល់ទៅកាន់និស្សិតមួយក្រុមដែលវិលត្រឡប់មកប្រទេសកម្ពុជាថា ពេលនេះមានវណ្ណៈតែពីរប៉ុណ្ណោះនៅកម្ពុជា គឺវណ្ណៈកម្មករ និងកសិករ។ ខៀវ សំផន បានលើកឡើងអំពីទ្រឹស្តីនេះក្នុងអំឡុងខែធ្នូ ឆ្នាំ១៩៧៥ នៅក្នុងសមាជជាតិ ដែលពេលនោះរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យត្រូវបានអនុម័តជាផ្លូវការ។ ខៀវ សំផន បានថ្លែងខ្លឹមសារជាគន្លឹះនៅក្នុងសុន្ទរកថាចំពោះមុខកម្មករ និងកសិករ ដែលជាអ្នកតំណាងរបស់វណ្ណៈទាំងពីរនេះ ដោយបានសង្កត់ធ្ងន់ថា រដ្ឋធម្មនុញ្ញបានធានាថាប្រទេសជាតិត្រូវបានដឹកនាំដោយ “កម្មករ និងកសិករ ជាអ្នកមើលការខុសត្រូវ” លើប្រព័ន្ធការងារសមូហភាពក្នុងវិស័យកសិកម្ម និងវិស័យផ្សេងទៀត។ ខៀវ សំផន បានយល់ស្របចំពោះការហាមឃាត់នៅក្នុងរដ្ឋធម្មនុញ្ញប្រឆាំងនឹងសាសនា ដែលត្រូវបានចាត់ទុកថាជាប្រតិកិរិយា ដោយបានអធិប្បាយថា សត្រូវរបស់ប្រទេសជាតិកំពុងព្យាយាមប្រើប្រាស់ “សាសនាជាខែល” ដើម្បីប្រឆាំងនឹងប្រទេសជាតិ ហើយត្រូវតែប្រឆាំងតាមគ្រប់មធ្យោបាយ “ទោះបីជាត្រូវលះបង់អ្វីក៏ដោយ”។ ដូច្នេះ ខៀវ សំផន បានគាំទ្រជាទូទៅចំពោះការអនុវត្តគោលនយោបាយនេះ និងបានចូលរួមអនុវត្តផងដែរ។ ខៀវ សំផន បានធ្វើសេចក្តីថ្លែងការណ៍ទាំងនេះស្របពេលដែលបក្សកុម្មុយនីស្តកម្ពុជាបានអះអាងចេតនារបស់ខ្លួនក្នុងការលុបបំបាត់រាល់ជនជាតិភាគតិច និងក្រុមផ្សេងៗ។

[១៦:០៧:០២]

<u>ការប្រព្រឹត្តលើអតីតអ្នករដ្ឋកាលរបបសាធារណរដ្ឋខ្មែរ</u>

កថាខណ្ឌ១១៩៣៖ ដូចដែលបានរៀបរាប់ខាងលើ នៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ១៩៧៥ ខៀវ សំផន បានចេញសេចក្តីប្រកាសព័ត៌មានមួយក្នុងនាមរណសិរ្សរួបរួមជាតិកម្ពុជា និងក្នុងឋានៈរបស់គាត់ជាប្រធានសមាជជាតិនៃរណសិរ្សនេះ។ ខៀវ សំផន បានរាយការណ៍ថា រណសិរ្សរួបរួមជាតិកម្ពុជាបានធ្វើសមាជរបស់ខ្លួនក្នុងរយៈពេល២ថ្ងៃ ហើយបានដាក់ចេញនូវសេចក្តីសម្រេចស្តីពីបញ្ហាផ្សេងៗមួយចំនួន។ ខៀវ សំផន លើកឡើងពី “ពួកក្បត់ទាំងប្រាំពីរនាក់នៅក្នុងទីក្រុងភ្នំពេញ ... លន់ នល់, សិរិមតៈ, សឺង ង៉ុកថាញ់, ចេង ហេង, អ៊ិន តាំ, ឡុង បូរ៉េត, និង ស្វស្តែន ហ្វែណង់ដែស” ដែលត្រូវសម្លាប់ចោល។ ក្នុងចំណោមឈ្មោះទាំងប្រាំពីរនាក់ខាងលើ មានតែ ឡុង បូរ៉េត និង សិរិមតៈ ទេ ដែលនៅក្នុងប្រទេស។

សិរិមត: បានប៉ុនប៉ងរត់គេចខ្លួនក្នុងស្ថានទូតបារាំង ប៉ុន្តែក្រោយមកត្រូវបានប្រគល់ទៅឲ្យបក្សកុម្មុយនីស្តកម្ពុជា។ អ្នកទាំងពីរត្រូវបានបក្សកុម្មុយនីស្តកម្ពុជាសម្លាប់ ហើយ អៀង សារី ក៏បានអះអាងដូចគ្នានេះដែរ។ ខៀវ សំផន បានធ្វើសេចក្តីថ្លែងការជាសាធារណៈជាច្រើនផ្សេងៗទៀតអំពី "ក្រុមបនក្បត់ លន់ នល់"។

[១៦:០៨:៣៩]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកស្រី សែ កុលវុឌ្ឍី។ ហើយទន្ទឹមនេះ អង្គជំនុំជម្រះក៏សូមបញ្ជាក់បន្ថែមដែរថាបណ្តាអង្គហេតុដែលបង្ហាញនៅក្នុងបណ្តារកថាខណ្ឌទាំងឡាយ ដែលពាក់ព័ន្ធទៅនឹងអង្គហេតុការសម្លាប់អតីតទាហាន និងមន្ត្រីរដ្ឋការរបប លន់ នល់ នៅទួលពោធិ៍ជ្រៃ ហើយនិងកថាខណ្ឌមួយចំនួនដែលពាក់ព័ន្ធ ដែលអានដោយក្រឡាបញ្ជីសវនាការលោកស្រី សែ កុលវុឌ្ឍី អម្បាញ់មិញនេះ អង្គជំនុំជម្រះសម្រេចបញ្ចូលទៅផ្នែកមួយនៃៗអង្គហេតុដែលអង្គជំនុំជម្រះលើកយកមកធ្វើសវនាការវគ្គ៣ នៃសំណុំរឿង០០២/០១។ ការធ្វើដូច្នេះដើម្បីសម្រួលដល់ការរៀបចំនូវកាលវិភាគសម្រាប់រក្សាកិច្ចដំណើរការនាពេលអនាគត។

បាទ ឥឡូវនេះដល់ពេលសមល្មមនឹងសម្រាកហើយ ប៉ុន្តែមុននឹងសម្រាកថ្ងៃនេះ អង្គជំនុំជម្រះសម្រេចប្រកាសនៅសេចក្តីសម្រេចរបស់ខ្លួនអំពីអាកប្បកិរិយារបស់លោកមេធាវី អ៊ីយ៉ានូហ្ស៊ី។ នៅពេលនេះអង្គជំនុំជម្រះសម្រេចទៅលើការអធិប្បាយច្រំដែលៗ និងមានលក្ខណៈប្រមាថដល់សេចក្តីសម្រេចនានារបស់ខ្ញុំ ក៏ដូចជាសេចក្តីសម្រេចនានារបស់អង្គជំនុំជម្រះ។ ព្រមទាំងការកត់សម្គាល់ផ្ទាល់ខ្លួនមួយចំនួនកាលពីព្រឹកមិញរបស់លោកមេធាវី អ៊ីយ៉ានូហ្ស៊ី ដែលជាមេធាវីម្នាក់ក្នុងចំណោមមេធាវីអន្តរជាតិរបស់លោក នួន ជា។

ការកត់សម្គាល់នានារបស់ខ្លួននេះ គឺជាដកស្រង់ចេញពីបទភ្លេងរបស់ រ៉ូដ្ឋី និង ហែម មីស្តែនដែលលោកមេធាវីបានធ្វើឡើងនៅមុនពេលឈប់សម្រាកពិសាត្រង់ថ្ងៃ នៅថ្ងៃនេះ។ ដែលជាកាយវិការប្រមាថផ្ទាល់ខ្លួន ដល់អង្គជំនុំជម្រះ ដោយអត្ថាធិប្បាយទាំងនេះ និងការសួរនាំអំពីសេចក្តីសម្រេចនានារបស់អង្គជំនុំជម្រះ គឺជាការមិនគោរពក្រមសីលធម៌វិជ្ជាជីវៈ ដែលមេធាវីត្រូវគោរព ទាំងនៅទីនេះក៏ដូចនៅតុលាការផ្សេងទៀតផងដែរ។

[១៦:១០:៥៨]

អង្គជំនុំជម្រះធ្លាប់បានព្រមានមេធាវី អ៊ីយ៉ានូហ្ស៊ី រួចហើយ កាលពីពេលមុន ចំពោះអាកប្បកិរិយាដែលមិនអាចទទួលយកបាននេះ។ អង្គជំនុំជម្រះនឹងបញ្ជូនពាក្យប្ដឹងនេះ ទៅគណៈមេធាវីដែលមេធាវីរូបនេះ ជាសមាជិក ហើយនិងស្នើឲ្យគណៈមេធាវីនោះ ពិចារណាលើពាក្យប្ដឹងនេះ រួមជាមួយនឹងការប្ដឹងដែលបានចេញពីពេលមុន ដែលអង្គជំនុំជម្រះបានសម្រេចចំពោះគាត់។

កិច្ចដំណើរការសវនាការថ្ងៃនេះ ដល់ពេលត្រូវសម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ។ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃពុធ ទី១០ ខែតុលា ឆ្នាំ២០១២ ចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹក។

សវនាការនៅថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងផ្ដល់ឱកាសជូនទៅជនជាប់ចោទ នួន ជា ដើម្បីធ្វើការការកត់សម្គាល់ ឬក៏ធ្វើសេចក្ដីថ្លែងតបទៅនឹងបណ្ដាកថាខណ្ឌនៃអង្គហេតុចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយ ហើយអង្គជំនុំជម្រះបានកំណត់យកមកធ្វើសវនាការវគ្គ៣ នៃសំណុំរឿង០០២/០១ គឺរួមបញ្ចូលទាំងអង្គហេតុទីតាំងសម្លាប់អតីតទាហាន និងអ្នករដ្ឋការរបប លន់ នល់ និងកថាខណ្ឌដែលពាក់ព័ន្ធនៅទួលពោធិ៍ជ្រៃផងដែរ។ ហើយនិងជាបន្ត គឺអង្គជំនុំជម្រះនឹងធ្វើការសវនាការដាក់ឯកសាររបស់អង្គជំនុំជម្រះ ឬរបស់ភាគី ដែលជាការបញ្ចប់សវនការវគ្គ២ នៃសំណុំរឿង០០២/០១ ហើយសូមភាគី និងសាធារណជនជ្រាប។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទទាំងពីររូប នួន ជា និងលោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ ហើយនិងឲ្យនាំខ្លួនគាត់មកកាន់បន្ទប់សវនាការនេះវិញ នៅព្រឹកថ្ងៃស្អែក ឲ្យបានមុនម៉ោងប្រាំបួន។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៦:១៣ នាទី)*